BIC Bank



របាយការណ៍ប្រចាំឆ្នាំ ២០១៩

BIC Bank

របាយការណ៍ប្រចាំឆ្នាំ ២០១៩

មាតិកា

០៦	សាររបស់ប្រធានក្រុមប្រឹក្សាភិបាល
០៧	ចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២០
០៨	ព័ត៌មានអំពីធនាគារ
១០	បេសកកម្ម / ចក្ខុវិស័យ / គុណតម្លៃស្នូល
១២	រចនាសម្ព័ន្ធធនាគារ
១៦	ព័ត៌មានហិរញ្ញវត្ថុ និងប្រតិបត្តិការសង្ខេប
២១	ព័ត៌មានសំខាន់ៗអំពីអាជីវកម្ម
២២	សមិទ្ធផលឆ្នាំ២០១៩
២៣	ក្រុមប្រឹក្សាភិបាល
២៦	កំណើន និងការអភិវឌ្ឍ

ក. ការពង្រឹងការថែទាំអតិថិជន
ខ. ការអភិវឌ្ឍនិយោជិត
គ. ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចធនាគារ
ឃ. ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន
ង. សេវាធនាគារឌីជីថល
ច. ការដាក់ឱ្យដំណើរការផលិតផលប័ណ្ណ
ឆ. ការពង្រីកបណ្តាញសាខា
ជ. ការរៀបចំម៉ាកសញ្ញាថ្មី
ញ. ទំនួលខុសត្រូវសង្គមរបស់ធនាគារ

៥៥	របាយការណ៍ហិរញ្ញវត្ថុនិង របាយការណ៍របស់សវនករឯករាជ្យ

ខ្ញុំមានជំនឿចិត្តទៅលើភាពធន់នៃចំនួន

ប្រជាជនវ័យក្មេង

ដែលប្រកបទៅដោយផ្នត់

គំនិតនវានុវត្តន៍

និងដែលបានខិតខំខ្នះខ្នែងជា
បន្តបន្ទាប់ ដើម្បីពង្រីកសមត្ថភាព
និងការប្រកួតប្រជែងកាន់តែល្អ



សាររបស់
ប្រធានក្រុមប្រឹក្សាភិបាល

ទិដ្ឋភាពក្នុងឆ្នាំ និងទស្សនវិស័យឆ្ពោះទៅមុខ

ឆ្នាំ២០១៩ បាននាំមកនូវព្រឹត្តិការណ៍ដ៏រំជើបរំជួលថ្មីមួយទៀតសម្រាប់វិស័យធនាគារនៅទូទាំងពិភពលោក ទាំងមូល ដែលបានជំរុញដោយដៃគូប្រកួតប្រជែងនាំមុខដោយបច្ចេកវិទ្យា ការប្រែប្រួលនៃឥរិយាបថរបស់អ្នកប្រើប្រាស់ និងការប្រែប្រួលនិន្នាការម៉ាក្រូសេដ្ឋកិច្ច ជាដើម។ ទោះជាស្ថិតនៅក្នុងបរិបទដែលវិស័យនេះទទួលរងឥទ្ធិពលពីកត្តាខាងក្រៅក្តី សេដ្ឋកិច្ចកម្ពុជា និងវិស័យធនាគារនៅតែបន្តមានកំណើនឆ្ពោះទៅមុខ ដោយសម្រេចបាននូវកំណើនផលិតផលក្នុងស្រុកសរុបពិត (ផសស) ចំនួន ៧% នៅក្នុងឆ្នាំ២០១៩ នេះបើយោងតាមរបាយការណ៍ស្តីពីចក្ខុវិស័យសេដ្ឋកិច្ចពិភពលោករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដែលបានចេញផ្សព្វផ្សាយកាលពីខែមេសា ឆ្នាំ២០២០ កន្លងទៅ។

ជាការពិតណាស់ របាយការណ៍ដដែលនេះបានចាប់ផ្តើមដំពូកដំបូងរបស់ខ្លួនដោយ "ការបិទប្រទេសទ្រង់ទ្រាយធំ" ដែលត្រូវបានរំពឹងថានឹងក្លាយទៅជាកត្តាដ៏មានឥទ្ធិពលយ៉ាងខ្លាំងបំផុតដែលនឹងធ្វើឱ្យបញ្ហាដែលយើងនឹងប្រឈមនៅឆ្នាំខាងមុខ និងឆ្នាំជាបន្តបន្ទាប់ទៀតកាន់តែមានស្ថានភាពធ្ងន់ធ្ងរខ្លាំងឡើង។ ខណៈដែលយើងទាំងអស់គ្នាសុទ្ធតែមើលឃើញច្បាស់ហើយថាសេដ្ឋកិច្ចបានកំពុងតែរងផលប៉ះពាល់រួចទៅហើយ និងបន្តទទួលរងផលប៉ះពាល់កាន់តែខ្លាំងថែមទៀតនាពេលខាងមុខនេះ ខ្ញុំមានជំនឿចិត្តទៅលើភាពធន់នៃចំនួនប្រជាជនវ័យក្មេង ដែលប្រកបទៅដោយផ្នត់គំនិតនវានុវត្តន៍ និងដែលបានខិតខំខ្នះខ្នែងជាបន្តបន្ទាប់ដើម្បីពង្រីកសមត្ថភាព និងប្រកួតប្រជែងកាន់តែល្អប្រសើរថែមទៀតនោះ ខ្ញុំផ្ទាល់ខ្លួនយល់ឃើញថាទាំង ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក និងព្រះរាជាណាចក្រកម្ពុជាសុទ្ធតែមានជំនឿនេះដូចគ្នា ហើយកត្តានេះបានផ្តល់នូវក្តីសង្ឃឹមដល់រូបខ្ញុំអ្វីៗនឹងមានភាពល្អប្រសើរឡើងវិញជាក់ជាមិនខាននាពេលអនាគត។

ចក្ខុវិស័យសេដ្ឋកិច្ច

យោងតាមរបាយការណ៍បឋមស្តីពីចក្ខុវិស័យសេដ្ឋកិច្ចពិភពលោករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបានចេញផ្សព្វផ្សាយខែមេសា ឆ្នាំ២០២០ បានព្យាករណ៍ថាកំណើនផលិតផលក្នុងស្រុកសរុបពិត (ផសស) នឹងធ្លាក់ចុះមកនៅត្រឹម -១,៦% នៅក្នុងឆ្នាំ២០២០ ហើយនឹងមានកំណើនឡើងវិញរហូតដល់ ៦% នៅក្នុងឆ្នាំ២០២១។ ដោយមានការធ្លាក់ចុះយ៉ាងខ្លាំងបំផុតបើធៀបទៅនឹងឆ្នាំមុនដែលកម្ពុជាសម្រេចបាននូវអត្រាកំណើន ផសស ពិតប្រាំឆ្នាំចន្លោះចាប់ពី ៧% ដល់ ៧,៥% ចាប់តាំងពីឆ្នាំ២០១៧ មក សេចក្តីណែនាំ និងការព្យាករណ៍សម្រាប់ឆ្នាំខាងមុខនេះ នឹងត្រូវបញ្ជាក់យ៉ាងច្បាស់ ជាពិសេស នៅឆមាសទីមួយនៃឆ្នាំ២០២០ នេះ។ ខណៈដែលខ្សែច្រវ៉ាក់ និងប្រព័ន្ធផ្គត់ផ្គង់សកលបានកំពុងតែជួបផលវិបាក និងស្ថិតនៅក្រោមសម្ពាធស្រាប់ហើយនោះ របាយការណ៍នេះបានព្យាករណ៍ថានឹងមានផលប៉ះពាល់ដោយផ្ទាល់កាន់តែខ្លាំងថែមទៀត ដោយសារតែផលប៉ះពាល់ដែលកើតមានលើវិស័យទេសចរណ៍ ដែលបច្ចុប្បន្នជាផលិតផលក្នុងស្រុកសរុបលំដាប់លេខរៀងទីប្រាំ។ ដោយមានទស្សនវិស័យថា កត្តាជំរុញកំណើនសេដ្ឋកិច្ចប្រពៃណីនៃការពង្រីកវិស័យនាំចេញរហ័ស និងភាពមិនច្បាស់លាស់នៃតម្រូវការក្នុងស្រុកដ៏រឹងមាំ ការបន្តរក្សាស្ថិរភាពរបស់វិស័យធនាគារ និងហិរញ្ញវត្ថុនាពេលថ្មីៗនេះ គឺជាធាតុដ៏សំខាន់ដើម្បីស្តារឱ្យបានទូលំទូលាយនូវគ្រប់វិស័យទាំងអស់។

សេចក្តីសង្ខេបអំពីអាជីវកម្ម

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក សម្រេចបាននូវសមិទ្ធផលគួរជាទីពេញចិត្តនៅក្នុងឆ្នាំ២០១៩ មិនត្រឹមតែក្នុងន័យសមិទ្ធផលហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ខ្លួនប៉ុណ្ណោះនោះទេ តែក៏ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មរបស់យើង និងសមត្ថភាពក្នុងការបំពេញតាមតម្រូវរបស់អតិថិជន និងអ្នកប្រើប្រាស់ផងដែរ។ នៅផ្នែកប្រតិបត្តិការជួរមុខ ឆ្នាំ២០១៩ គឺជាឆ្នាំដែល ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក បានដាក់ចេញនូវសេវាធនាគារអនឡាញ ជាផ្នែកដែលមានការកែលម្អជាបន្តបន្ទាប់ ហើយក៏ជាឆ្នាំដែលធនាគាររបស់យើងបានប្រកាសថាសម្រេចបានលើសផែនការផងដែរ។ ធនាគារក៏បានដាក់ឱ្យប្រើប្រាស់ផងដែរនូវកាត ATM ធនាគាររបស់ខ្លួន ហើយក៏កំពុងទន្ទឹងរង់ចាំត្រៀមដាក់ឱ្យប្រើប្រាស់នូវសេវាកម្ម និងដំណោះស្រាយជាច្រើនទៀតនាពេលខាងមុខនាប់ៗនេះ ទាំងតាមបច្ចេកវិទ្យាឌីជីថល និងនៅតាមសាខា ក៏ដូចជានៅទីតាំងផ្តល់

សេវាកម្មផ្ទាល់នានាផងដែរ។ ចំណែកឯនៅផ្នែកប្រតិបត្តិការជួរក្រោយវិញ យើងបានដាក់ឱ្យប្រើប្រាស់ជាបណ្តើរៗនូវប្រព័ន្ធធនាគារស្នូលថ្មីនៅពេញមួយឆ្នាំ២០១៩ តែម្តង ហើយជាថ្មីម្តងទៀត យើងនឹងបន្តធ្វើទំនើបកម្ម និងធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់ដើម្បីពង្រីកសមត្ថភាពផ្តល់សេវាកម្ម និងលទ្ធភាពជារួមរបស់យើង ខណៈដែលផ្តោតការយកចិត្តទុកដាក់លើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់យើង ព្រមទាំងធានានូវសុវត្ថិភាព និងលក្ខណៈពិសេសខ្ពស់បំផុត និងល្អបំផុតនៅក្នុងវិស័យនេះ។ នៅដើមឆ្នាំ២០២០ យើងពិតជាមានសេចក្តីសោមនស្សរីករាយជាខ្លាំងដែលបើកដំណើរការសាខាធនាគារទីពីររបស់យើង (និងជាសាខាដំបូងគេដែលស្ថិតនៅក្រៅទីក្រុងភ្នំពេញ) ដោយដាក់ដំណើរការសាកល្បងនៃសាខានៅក្រុងព្រះសីហនុ ហើយយើងនឹងបន្តពង្រីកសាខារបស់យើងឱ្យកាន់តែខិតទៅជិតអតិថិជនរបស់យើង ពោលគឺ ទាំងនៅទីក្រុងភ្នំពេញ ឬនៅតាមបណ្តាខេត្តផ្សេងៗនៅទូទាំងប្រទេសទាំងមូលតែម្តង។

សមិទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ

នៅពេញក្នុងមួយឆ្នាំការិយបរិច្ឆេទដំបូងនៃប្រតិបត្តិការ នៅក្នុងរយៈពេល ១២ ខែ បិទបញ្ជីនៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ធនាគារ បានមាន

ចំណូលសុទ្ធចំនួន

១,១៤ លានដុល្លារអាមេរិក

(ឆ្នាំ២០១៨៖ ប្រាក់ខាតសុទ្ធចំនួន ៨៧៤,០០០ ដុល្លារអាមេរិក) ដោយប្រាក់ចំណេញដុលមុនពេលកាត់ពន្ធចំនួន ១,៤៧ លានដុល្លារអាមេរិក (ឆ្នាំ២០១៨៖ ប្រាក់ខាតដុលចំនួន ១,០៥ លានដុល្លារអាមេរិក)។

នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ ប្រាក់ចំណូលប្រតិបត្តិការរបស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក បានកើនឡើងដល់

៥,៥៥ លានដុល្លារអាមេរិក

(ឆ្នាំ២០១៨៖ ៥៦២.០០០ ដុល្លារអាមេរិក) ហើយអាចបង្កើនផលបត្រកម្ចី និងប្រាក់បញ្ញើសរុបរហូតដល់ ៦៧,៧៧ លានដុល្លារអាមេរិក (ឆ្នាំ២០១៨៖ ៣៦,១១ លានដុល្លារអាមេរិក) និង ១២០.២៤ លានដុល្លារអាមេរិក (ឆ្នាំ២០១៨៖ ១៧,៩៧ លាន) រៀងគ្នា។

ទ្រព្យសកម្មសរុបមានចំនួន

១៩៧,៩១ លានដុល្លារអាមេរិក

(ឆ្នាំ២០១៨៖ ៩២,៥៦ លានដុល្លារអាមេរិក) ដោយមានទ្រព្យម្ចាស់របស់ភាគហ៊ុនិកកើនឡើងរហូតដល់ ៧៥,២៧ លានដុល្លារអាមេរិក (ឆ្នាំ២០១៨៖ ៧៤,១៣ លាន) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។ អនុបាតឥណទានមិនដំណើរការធៀបនឹងឥណទានសរុបនៅតែស្ថិតក្នុងអត្រា 0% (ឆ្នាំ២០១៨៖ 0%)។

សមិទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ

ការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងពេលនេះ បណ្ឌិត Sathit Limpongpan បានចាកចេញពីតំណែងរបស់លោកជាប្រធានក្រុមប្រឹក្សាភិបាល ដែលនឹងត្រូវជំនួសដោយលោក យឹម លក្ខណ៍ ប៉ុន្តែលោកក៏នឹងនៅបន្តបំពេញការងារនៅក្នុងក្រុមប្រឹក្សាភិបាលដដែល។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងដ៏ស្មោះស្ម័គ្រអស់ពីចិត្តរបស់លោកនៅក្នុងការជួយធនាគារនៅក្នុងអំឡុងពេលដែលលោកកាន់តំណែងជាប្រធានក្រុមប្រឹក្សាភិបាល ហើយយើងក៏រង់ចាំធ្វើការងារជាមួយលោកនៅក្នុងអំឡុងពេលដែលលោកនឹងបន្តបម្រើការងាររបស់លោកនៅក្នុងក្រុមប្រឹក្សាភិបាលផងដែរ។

ការផ្តោតលើអនាគតរបស់ធនាគារ

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក គឺជាធនាគារមួយរបស់ក្រុមហ៊ុន BIC Group (“គ្រុប”) ដែលជាក្រុមហ៊ុនវិនិយោគយ៉ាងសកម្មនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នៅក្នុងវិស័យធនាគារ អចលនទ្រព្យ ថាមពល និងហិរញ្ញវត្ថុ។

ដោយសារកម្ពុជាជាទីផ្សារមួយនៅក្នុងចំណោមទីផ្សារដែលគួរឲ្យទាក់ទាញជាងគេបំផុតដែលគ្របធ្វើប្រតិបត្តិការ យើងនឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់យើងថែមទៀតដើម្បីបង្កើនប្រតិបត្តិការ សេវាកម្ម និងសមត្ថភាពប្រកួតប្រជែងរបស់យើង។ ចំណុចសំខាន់ៗដែលនឹងនៅតែជាចំណុចផ្តោតសំខាន់នៃអាជីវកម្មរបស់យើង គឺផ្នែកនានានៃហេដ្ឋារចនាសម្ព័ន្ធទាំងមូល ដែលយើងផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើវិស័យឌីជីថល សុវត្ថិភាព និងការកសាងសាមគ្គីភាព។ ផ្នែកនេះនឹងពង្រឹងជាពិសេសទៅលើការផ្តល់ជូនសេវាកម្មរបស់យើងទៅកាន់អតិថិជន និងភ្ញៀវរបស់យើង។

ផ្នែកសំខាន់មួយទៀតដែលយើងនឹងផ្តោតទៅលើ គឺផ្នែកទីផ្សារមូលធន ដោយផ្តែកទៅលើបទពិសោធន៍របស់ក្រុមការងារធនាគាររបស់យើងនៅក្នុងផ្នែកទីផ្សារមូលធនក្រៅប្រទេស ដោយប្រើប្រាស់អាជីវកម្មគ្រុបរបស់យើង ក៏ដូចជាដៃគូពាក់ព័ន្ធ និងបច្ចេកវិទ្យាទាំងនោះ ដើម្បីផ្តល់នូវដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត នៅក្នុងផ្នែកធានាវ៉ាប់រង់ធនាគារ សាជីវកម្ម ការរួមបញ្ចូលគ្នា និងការទិញយកក្រុមហ៊ុន និងវិស័យធនាគារឯកជន។

សេចក្តីថ្លែងអំណរគុណ

តាងនាមឱ្យធនាគារ ប៊ី.អាយ.ស៊ី ខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាល មន្ត្រី និងបុគ្គលិកទាំងអស់របស់ធនាគារជាតិនៃកម្ពុជា ដែលបានផ្តល់ឱវាទ និងការគាំទ្រនានា ហើយជាពិសេសគឺស្ថិរភាពរូបិយវត្ថុដែលកម្ពុជាសម្រេចបាននាពេលកន្លងមក ដែលពេលបច្ចុប្បន្ននេះក្លាយជាចំណុចដ៏សំខាន់ខ្លាំងបំផុតជាងពេលណាៗទាំងអស់ក្នុងអំឡុងពេលនេះ។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជន និងដៃគូអាជីវកម្មដ៏មានតម្លៃទាំងអស់ដែលបានគាំទ្រ និងផ្តល់ទំនុកចិត្តយ៉ាងមុតមាំមកលើធនាគាររបស់យើង ហើយយើងនឹងខិតខំប្រឹងប្រែងពង្រឹងទំនាក់ទំនងនេះឱ្យកាន់តែមានភាពរឹងមាំ និងមានភាពស៊ីជម្រៅនៅក្នុងឆ្នាំខាងមុខដ៏លំបាកនេះ ខណៈដែលយើងនឹងខិតខំពង្រីកវិសាលភាពសេវាកម្ម និងបន្តផ្តល់ផលិតផលថ្មីៗជូនអតិថិជនឱ្យកាន់តែសម្បូរបែបថែមទៀត។

ជាចុងក្រោយ ខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណចំពោះសមាជិកក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងធនាគារ និងបុគ្គលិក ទីប្រឹក្សាក៏ដូចជាភាគហ៊ុនិកទាំងអស់របស់យើង ដែលខិតខំប្រឹងប្រែងបំពេញការងារសម្រាប់ធនាគាររបស់យើង។ ខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំថាធនាគាររបស់យើងនឹងបន្តទទួលបានការគាំទ្រឥតងាករេបន្ថែមទៀតនាឆ្នាំខាងមុខ។

ដោយក្តីគោរពរាប់អាន



យឹម លក្ខណ៍

ប្រធានក្រុមប្រឹក្សាភិបាល

ប្រទេសកម្ពុជាចក្ខុវិស័យ ឆ្នាំ២០២០

កម្ពុជា គឺជាទិសដៅវិនិយោគដ៏គួរឱ្យទាក់ទាញសម្រាប់ក្រុមហ៊ុន ដែលមានបំណងចង់ពង្រីកអាជីវកម្មរបស់ខ្លួននៅក្នុងតំបន់អាស៊ី។ បច្ចុប្បន្នកម្ពុជាមានគោលដៅរក្សាតំណែងនៅក្នុងទីផ្សារសេដ្ឋកិច្ចសកល។

គិតត្រឹមត្រីមាសទី៤ ឆ្នាំ២០១៩ សកម្មភាពសេដ្ឋកិច្ចកម្ពុជានៅតែអាចរក្សាកំណើនខ្ពស់ ដោយសារមានកំណើនដ៏ខ្លាំងក្លានៃការផ្តល់កម្ចីឥណទានសម្រាប់ការទ្រទ្រង់ដល់តម្រូវការក្នុងស្រុក និងលំហូរចូលនៃមូលធនពីសំណាក់វិនិយោគិនចិន ដែលបានជួយទ្រទ្រង់ដល់វិស័យសំណង់ដែលកំពុងតែមានសកម្មខ្លាំង។ ទោះជាយ៉ាងនេះក្តីស្ថានភាពដ៏ល្អមួយនេះបានប្រែជាអប្បអ្ហរខ្លាំងនៅឆ្នាំ២០២០ ដោយសារតែការផ្ទុះឡើងនូវជំងឺវីរុសកូរ៉ូណា (កូវីដ19) ដែលបានបង្កផលប៉ះពាល់អវិជ្ជមាន និងបានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងដំណាំ។ ការធ្លាក់ចុះចំនួនភ្ញៀវទេសចរយ៉ាងគំហុក បានធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើសេដ្ឋកិច្ចកម្ពុជា ដែលកន្លងមកបានពឹងផ្អែកទៅលើចំណូលចំនួនជិតប្រាំភាគនៃ ផសស ពីវិស័យទេសចរណ៍នេះ ហើយនេះក៏ជាការបន្ថែមសម្ពាធកាន់តែខ្លាំងថែមទៀតទៅលើគណនីចរន្តដែលកំពុងតែមានឱនភាពខ្លាំងស្រាប់ផងនោះ។ រាជរដ្ឋាភិបាលបានប្រកាសដាក់ចេញនូវវិធានការជាច្រើន ដែលមានទំហំទឹកប្រាក់សរុបចំនួន ២.0 ប៊ីលានដុល្លារអាមេរិក ក្នុងគោលបំណងស្តារស្ថានភាពសេដ្ឋកិច្ច ដែលបានថមថយខ្លាំងដោយសារតែវីរុសនេះឱ្យមានភាពល្អប្រសើរឡើងវិញ។ ចំណុចគួរឱ្យចាប់អារម្មណ៍មួយទៀតគឺ គម្រោងក្នុងការអភិវឌ្ឍទំនប់វារីអគ្គិសនីថ្មីនៅលើដងទន្លេមេគង្គ ត្រូវបានផ្អាកដំណើរការរយៈពេល ១០ ឆ្នាំ ដែលការណ៍នេះធ្វើឱ្យកម្ពុជាពឹងផ្អែកកាន់តែខ្លាំងថែមទៀតទៅលើការនាំចូលថាមពលអគ្គិសនីពីប្រទេសឡាវ។

បរិយាកាសវិនិយោគ

បរិយាកាសវិនិយោគនៅក្នុងប្រទេសកម្ពុជា មានការជំរុញខ្ពស់ដោយសារតែភាពទាក់ទាញសម្រាប់ការវិនិយោគផ្ទាល់ពីបរទេស ហើយកម្ពុជាក៏មានច្បាប់វិនិយោគបើកចំហខ្លាំង ព្រមទាំងផ្តល់ការលើកទឹកចិត្តជាច្រើនថែមទៀតដល់វិនិយោគិនផងដែរ។ ចំណុចពិសេសមួយទៀត គឺកម្ពុជាមានទីតាំងក៏ស្ថិតនៅជិតរោងចក្រផលិតនៅក្នុងប្រទេសថៃ និងវៀតណាម ក៏ដូចជាទីផ្សារចិនផងដែរ ដែលចំណុចពិសេសទាំងនេះ បង្ហាញថា កម្ពុជាគឺជាប្រទេសដែលអាចផ្តល់ឱកាសវិនិយោគដ៏ល្អឥតខ្ចោះ។

តំបន់សេដ្ឋកិច្ចពិសេស (SEZ) របស់កម្ពុជាផ្តល់នូវទីតាំងដ៏ល្អឥតខ្ចោះសម្រាប់ការវិនិយោគបរទេស ជាពិសេស នៅតាមតំបន់ព្រំដែន និងសម្រាប់រោងចក្រផលិតនាំចេញតែម្តង។ ការលើកលែងពន្ធលើប្រាក់ចំណេញរហូតដល់ទៅប្រាំបីឆ្នាំ និងការលើកលែងពន្ធលើប្រាក់ចំណេញបន្ថែមទៀត ប្រសិនបើវិនិយោគិនយកប្រាក់ចំណេញទាំងនោះទៅវិនិយោគនៅក្នុងប្រទេសនេះ គឺជាការលើកទឹកចិត្តខ្លះៗនៅក្នុងចំណោមការលើកទឹកចិត្តគួរឱ្យទាក់ទាញផ្សេងទៀតសម្រាប់វិនិយោគិន។ ហើយកម្ពុជា ក៏ផ្តល់ការលើកលែងពន្ធ និងអាករទាំងស្រុងចំពោះការនាំចូល និងនាំចេញសម្រាប់ឧស្សាហកម្មភាគច្រើនផងដែរ។

កម្ពុជាក៏អនុញ្ញាតឱ្យក្រុមហ៊ុនបរទេសមានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួន ១00 ភាគរយផងដែរនៅក្នុងវិស័យភាគច្រើន។ ច្បាប់វិនិយោគកម្ពុជាក៏ផ្តល់នូវបទប្បញ្ញត្តិដែលគ្រប់គ្រងទៅលើកិច្ចការពារការវិនិយោគពីតម្លៃនិយ័តកម្ម និងជាតូបនីយកម្ម។

កិច្ចព្រមព្រៀងដែលកម្ពុជាបានចុះជាមួយនឹងអង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប បានចូលជាធរមាននៅដើមឆ្នាំ២០១៨ ដែលទទួលស្គាល់សុពលភាពប្រកាស

នីយបត្រតក្កកម្មសហភាពអឺរ៉ុបនៅក្នុងប្រទេសកម្ពុជា។ កិច្ចព្រមព្រៀងនេះអនុញ្ញាតឱ្យមានការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មតែមួយ ដែលអាចប្រើប្រាស់នៅសហភាពអឺរ៉ុបកម្ពុជា និងប្រទេសហត្ថលេខីផ្សេងទៀត។ តាមរយៈកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនសហភាពអឺរ៉ុបអាចការពារនវានុវត្តន៍របស់ខ្លួនបានកាន់តែងាយស្រួល ខណៈ ដែលខ្លួនធ្វើការផលិតនៅក្នុងប្រទេសកម្ពុជា សម្រាប់លក់នៅលើទីផ្សារអាស៊ី។

សេដ្ឋកិច្ចកម្ពុជាចក្ខុវិស័យ ឆ្នាំ២០២០

នៅក្នុងឆ្នាំ២០២០ កំណើនសេដ្ឋកិច្ចកម្ពុជាចាប់ផ្តើមធ្លាក់សន្ទុះថមថយ ស្របពេលដែលសេដ្ឋកិច្ចចិនដែលជាដៃគូពាណិជ្ជកម្មដ៏ធំរបស់ខ្លួនក៏មានការធ្លាក់ចុះដែរហើយនេះក៏ឆ្លុះបញ្ចាំងពីការថមថយនៃលទ្ធភាពនាំចូលទៅក្នុងទីផ្សារអឺរ៉ុបផងដែរ។ ការផ្ទុះឡើងនៃជំងឺរលាកសួតថ្មីបង្កដោយ

វីរុសកូរ៉ូណា គឺជាហានិភ័យចម្បងធ្វើឱ្យសេដ្ឋកិច្ចធ្លាក់ចុះនាឆ្នាំខាងមុខ ដោយសារតែការបាត់បង់ចំណូលពីវិស័យ ទេសចរណ៍ និងពាណិជ្ជកម្មមានការថមថយ ខណៈដែលវិភាជន៍ថវិកាឡើងវិញសម្រាប់ប្រយុទ្ធប្រឆាំងនឹងវីរុស នេះទំនងជានឹងប្រមូលយ៉ាងច្រើនចេញពីការវិនិយោគក្នុងស្រុក។ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងមានអត្រាកំណើនចំនួន ៦,៦% នៅក្នុងឆ្នាំ២០២០។

ដោយបញ្ហាប្រឈមមួយចំនួន ដូចជា ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងលទ្ធភាពដែលប្រទេសនេះអាចនឹងត្រូវដកចេញពីគោលនយោបាយ "អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ" របស់សហភាពអឺរ៉ុប ដែលនៅតែមិនទាន់អាចដោះស្រាយបាន វិស័យកាត់ដេរនឹងនៅតែជាកម្លាំងចលករជំរុញដ៏ចម្បងនៃសេដ្ឋកិច្ចក្នុងឆ្នាំ២០២០។ វិស័យផលិតផ្សេងទៀតអាចមើលឃើញពីភាពទាក់ទាញរបស់កម្ពុជាសម្រាប់ខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួនផងដែរ។ វិស័យ ទេសចរណ៍ កសិកម្ម និងធនធាន ផ្តល់នូវសក្តានុពលចម្បង ប៉ុន្តែកំពុងតែត្រូវការការវិនិយោគបន្ថែមទៀតដើម្បីឱ្យវិស័យទាំងនេះអាចមានសមត្ថភាពប្រកួតប្រជែងខ្ពស់នៅក្នុងទីផ្សារសកល។

តើគួរតែវិនិយោគនៅក្នុងប្រទេសកម្ពុជាដែរឬទេនៅក្នុងឆ្នាំ២០២០?


កម្ពុជាផ្តល់ឱកាសជាច្រើនសម្រាប់ការចូលរួមពីសំណាក់វិនិយោគិន។ បរិយាកាសវិនិយោគបើកចំហ កម្លាំងពលកម្មប្រាក់ឈ្នួលទាប និងទីតាំងស្ថិតនៅជិតទីផ្សារធំបំផុតនៅក្នុងពិភពលោក ក៏គាំទ្រដល់ការលើកទឹកចិត្តផ្នែកវិនិយោគផងដែរ។ ការការពារប្រកាសនីយបត្រតក្តកម្មសហភាពអឺរ៉ុប និងកំណើនទំនុកចិត្តទៅលើហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស ជាពិសេសតំបន់សេដ្ឋកិច្ចពិសេស ធ្វើឱ្យកម្ពុជាកាន់តែមានភាពទាក់ទាញសម្រាប់ការបង្កើតរោងចក្រផលិត លើសពីវិស័យកាត់ដេរទៅទៀត។ ការកាត់បន្ថយថ្លៃដើមផលិតកម្ម តាមរយៈការទាញយកធនធានដោយខ្លួនឯង ក៏ជាកត្តាជួយគាំទ្រដល់ឧស្សាហកម្មផ្នែកលើធនធាននៅក្នុងប្រទេសនាពេលអនាគតដ៏ខ្លីខាងមុខនេះផងដែរ។

ព័ត៌មានអំពីធនាគារ

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក គឺជាធនាគារពាណិជ្ជ បានបង្កើតឡើង និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារនេះបានបង្កើតឡើងនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយស្របតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងទទួលបាន អាជ្ញាប័ណ្ណយោងតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ("NBC") ហើយ ធនាគារ ទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ និងបាន ចាប់ផ្តើមដំណើរការអាជីវកម្មរបស់ខ្លួននៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ ផងដែរ។

ធនាគារចូលរួមយ៉ាងសកម្មនៅគ្រប់ទិដ្ឋភាពនៃធុរកិច្ចធនាគារទាំងអស់ និងបានផ្តល់ សេវាហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៀតផង។

រចនាសម្ព័ន្ធភាគទុនិក



ទីស្នាក់ការកណ្តាល និងសាខាមេរបស់ធនាគារមានទីតាំងស្ថិតនៅ

អគារលេខ ៤៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រ កម្ពុជា។

ធនាគារនេះត្រូវបានបង្កើតឡើងរួមគ្នាដោយ

ក្រុមហ៊ុន Asia Investment and Finance Services Sole Co., Ltd នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្រុមហ៊ុន Paradise Investment Co., Ltd. នៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន Prime Street Advisory Co., Ltd នៃព្រះរាជាណាចក្រថៃ។ ក្រុមហ៊ុន Asia Investment and Financial Services Sole Co., Ltd. នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក៏ជាភាគទុនិករបស់ធនាគារ BIC Bank Lao Co., Ltd. ផងដែរ។

បេសកកម្ម

ដើម្បីក្លាយជាដៃគូហិរញ្ញវត្ថុក្នុងស្រុកដ៏ល្អបំផុត យើងត្រូវតែមានភាពឆ្លាតវៃ និងភាពរហ័សរហួនជាងគេក្នុងការផ្តល់អត្ថប្រយោជន៍កាន់តែសម្បូរបែបថែមទៀតជូនដល់អតិថិជនរបស់យើង តាមរយៈការផ្តល់ដំណោះស្រាយមានភាពច្នៃប្រឌិត និងជាក់ស្តែង ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនទាំងអស់។ យើងក៏បានប្តេជ្ញាចិត្តខ្ពស់ក្នុងការបង្កើតអត្ថប្រយោជន៍សម្រាប់អតិថិជន និងភាគទុនិកទាំងអស់របស់យើង ហើយនឹងខិតខំប្រឹងប្រែងកែលម្អសេវាធនាគាររបស់យើងជាប់ជាប្រចាំផងដែរ តាមរយៈការវិនិយោគជាបន្តបន្ទាប់ទៅលើផ្នែកធនធានមនុស្ស គំនិតច្នៃប្រឌិតថ្មី និងបច្ចេកវិទ្យា។ យើងពង្រឹងទំនាក់ទំនងភាពជាដៃគូជាមួយនឹងអតិថិជនរបស់យើង តាមរយៈការគោរពគ្នាទៅវិញទៅមក បើកចំហស្មោះត្រង់ និងការយល់ដឹងអំពីតម្រូវការរបស់អតិថិជន។

ចក្ខុវិស័យ

មានគោលបំណងក្លាយជាធនាគារដៃគូដ៏ល្អបំផុត តាមរយៈការផ្តល់សេវាបុគ្គលល្អបំផុតទៅតាមតម្រូវការរបស់អតិថិជនម្នាក់ៗ និងការផ្តល់ផលិតផល និងដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតដោយប្រើបច្ចេកវិទ្យាទំនើប ដើម្បីបំពេញតាមតម្រូវការ និងការរំពឹងទុករបស់អតិថិជន។

ទស្សនវិស័យ

ទស្សនៈចំពោះអតិថិជន៖

- ផ្តល់សេវាល្អបំផុត និងសេវាធនាគារមានសុវត្ថិភាពដល់អតិថិជន។
- បំពេញតាមតម្រូវការសេវាធនាគារ និងហិរញ្ញវត្ថុជូនអតិថិជន។

ទស្សនៈចំពោះបុគ្គលិក៖

- ធនធានមនុស្សគឺជាទ្រព្យសកម្មដ៏ល្អបំផុតរបស់យើង ដូច្នេះយើងបានផ្តោតការយកចិត្តទុកដាក់យ៉ាងសំខាន់ទៅលើការអភិវឌ្ឍធនធានមនុស្សរបស់យើង។ ដំណើរការអភិវឌ្ឍន៍ធនធានមនុស្សដ៏សកម្ម គឺជាកត្តាបង្កើនឧត្តមភាពប្រកួតប្រជែងរបស់យើង។


ទស្សនៈចំពោះសហគមន៍៖


- គាំទ្រដល់គោលនយោបាយ និងគោលបំណងរបស់រាជរដ្ឋាភិបាល និងចូលរួមចំណែកអភិវឌ្ឍសហគមន៍ ក៏ដូចជាប្រទេសជាតិទាំងមូលឱ្យមានការរីកចំរើន។

ទស្សនៈចំពោះភាគទុនិក៖

- បង្កើតគុណតម្លៃភាគទុនិកកម្រិតខ្ពស់ និងផលរបរនិរន្តរភាពលើទ្រព្យសកម្ម។

រចនាសម្ព័ន្ធធនាគារ




ក្រុមប្រឹក្សាភិបាល
នាយកប្រតិបត្តិ
គណៈកម្មាធិការសវនកម្ម
នាយកប្រតិបត្តិប្រតិបត្តិការ
គណៈកម្មាធិការឥណទាន
ប្រធានផ្នែកសវនកម្មផ្ទៃក្នុង
ប្រធានគ្រប់គ្រងជាន់ខ្ពស់
ផ្នែកប្រតិបត្តិការ
ផ្នែកឥណទាន
ផ្នែកលក់ និងទីផ្សារ
ផ្នែកសវនកម្មផ្ទៃក្នុង
CSA
សាខាខេត្តព្រះសីហនុ

ព័ត៌មានហិរញ្ញវត្ថុ និងប្រតិបត្តិការសង្ខេប

លទ្ធផលប្រតិបត្តិការ (000 ដុល្លារអាមេរិក)	**ឆ្នាំហិរញ្ញវត្ថុ ២០១៩**
ចំណូលប្រតិបត្តិ	៥.៥៤៨
ចំណេញ / (ខាត) មុនបង់ពន្ធ	១.៤៦៦
ចំណេញ / (ខាត) សុទ្ធសម្រាប់ឆ្នាំនេះ	១.១៣៩
ទិន្នន័យតារាងតុល្យការគន្លឹះ (000 ដុល្លារអាមេរិក)	១៩៧.៩១៣
ទ្រព្យសកម្មសរុប	៦៧.៧៧១
ឥណទាន និងបុរេប្រទានដល់អតិថិជន	១២២.៦៤៨
ទ្រព្យអសកម្មសរុប	១២០.២៣៧
ប្រាក់បញ្ញើរបស់ធនាគារ និងអតិថិជន	៧៥.០០០
មូលធនភាគទុនិក	៧៥.២៦៥
ទ្រព្យម្ចាស់របស់ភាគទុនិក	
អនុបាតហិរញ្ញវត្ថុ (%)	១,០០%
ផលលើទ្រព្យសកម្ម (ROA)	២,០០%
ផលលើមូលធន (ROE)	១១១៣%
អនុបាតសាច់ប្រាក់ងាយស្រួល	៥៧%
អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ	0%
ការគ្រប់គ្រងទុន	
អនុបាតសោធនភាព (%)	៤៥%

ព័ត៌មានសំខាន់ៗ អំពីអាជីវកម្មឆ្នាំ២០១៩

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក គឺជាធនាគារពាណិជ្ជថ្មីមួយ នៅក្នុងប្រទេសកម្ពុជា ដែលបំពេញតម្រូវការស្តង់ដារបស់អតិថិជនតាមរយៈការផ្តល់ដំណោះស្រាយមានភាពច្នៃប្រឌិត និងជាក់ស្តែង។ ធនាគាររបស់យើង ចូលរួមចំណែកលើកកម្ពស់ស្តង់ដារជីវភាពរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសតាមរយៈការផ្តល់សេវាធនាគារពេញលេញ ដោយផ្អែកលើមូលដ្ឋានហិរញ្ញវត្ថុរឹងមាំ ដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ ការអនុវត្តច្បាប់ និងតម្លាភាព។

យើងពង្រឹងភាពជាដៃគូជាមួយនឹងអតិថិជនរបស់យើង តាមរយៈការធ្វើការងារប្រកបដោយការគោរពគ្នាទៅវិញទៅមក បើកចំហ ស្មោះត្រង់ និងការយល់អំពីតម្រូវការរបស់អតិថិជន។

សេវាអតិថិជន

យើងផ្តល់សេវាល្អបំផុត និងសេវាធនាគារមានសុវត្ថិភាពដល់អតិថិជន ដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុរបស់អតិថិជន។

ផលិតផល និងសេវាកម្ម

ប្រាក់បញ្ញើ៖

- គណនីសន្សំ
- គណនីចរន្ត
- គណនីចរន្ត Active
- គណនីប្រាក់បញ្ញើមានកាលកំណត់
- គណនីបញ្ញើមានកាលកំណត់កំណើខ្ពស់

ឥណទាន៖

- ឥណទានអាជីវកម្ម
- ឥណទានគេហដ្ឋាន
- ឥណទានបុគ្គល
- ឥណទានវិបារូបន៍

សេវាកម្ម៖

- ការផ្ទេរប្រាក់ក្នុងប្រទេស និងក្រៅប្រទេស
- ការប្តូរប្រាក់
- ហិរញ្ញប្បទានពាណិជ្ជកម្ម

បណ្តាញ៖

- ម៉ាស៊ីន ATM
- សេវាធនាគារតាមអ៊ីនធឺណិត


2019
2018

សមិទ្ធផលឆ្នាំ២០១៩

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក សម្រេចបាននូវសមិទ្ធផលមួយចំនួនគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងការដាក់ប្រាក់បញ្ញើ ឥណទាន និងការបើកគណនី។ ក្នុងនាមជាធនាគារថ្មីមួយក្នុងប្រទេសកម្ពុជា ដែលជាប្រទេសមួយដែលមានធនាគារពាណិជ្ជជាច្រើនសុទ្ធសឹងតែមានភាពរឹងមាំខ្លាំងក្លាលើផ្នែកសេវាធនាគារឌីជីថលនោះ ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ក៏បានបង្ហាញនូវសក្តានុពលរបស់ខ្លួន តាមរយៈការមានចំណែកទីផ្សារ ស្របពេលដែលដំណើរការធ្វើឌីជីថលកម្ម និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងទៀតកំពុងតែអនុវត្តផងដែរ។

ឥណទាន

កំណើនឆ្នាំ ២០១៩ នៅក្នុងផលបត្រឥណទានសម្រាប់ធនាគារ ដែលមានសមតុល្យឥណទានចុះបញ្ជីសរុបចំនួន

៦៧,៧៧
លានដុល្លារអាមេរិក
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

កំណើនឥណទានដែលមានកម្រិតខ្ពស់ជាងការរំពឹងទុកនេះ គឺអាចសម្រេចបានដោយសារតែកត្តាសំខាន់ៗមួយចំនួនដូចជា ការកើនឡើងនូវតម្រូវការក្នុងទីផ្សារ ដោយសារតែស្ថានភាពសេដ្ឋកិច្ចនៅក្នុងឆ្នាំ២០១៩ មានភាពប្រសើរ និងលក្ខខណ្ឌផលិតផល និងសេវាកម្មរបស់ធនាគារមានភាពទាក់ទាញ និងប្រកួតប្រជែងខ្ពស់។

ប្រាក់បញ្ញើ

ក្នុងឆ្នាំ២០១៩ កំណើនប្រាក់បញ្ញើពីអតិថិជនបានកើនឡើងដល់ចំនួន

១២០,២៤
លានដុល្លារអាមេរិក
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

ដែលភាគច្រើនបានមកពីគណនីបញ្ញើសន្សំ គណនីចរន្ត និងគណនីបញ្ញើមានកាលកំណត់។ កត្តាដែលនាំឱ្យមានកំណើនប្រាក់បញ្ញើនេះ គឺដោយសារតែកត្តាផ្នែកសេវាអតិថិជន អត្រាការប្រាក់មានភាពទាក់ទាញ និងលក្ខខណ្ឌមានភាពប្រកួតប្រជែង គណៈគ្រប់គ្រង និងបុគ្គលិករបស់យើងទាំងអស់គ្នា។

ក្រុមប្រឹក្សាភិបាល

លោក យឹម លក្ខណ៍

ប្រធានក្រុមប្រឹក្សាភិបាល



លោក យឹម លក្ខណ៍ បម្រើការងារនៅក្នុងប្រទេស និងមាតុប្រទេសរបស់លោកយ៉ាងខ្លាប់ខ្ជួននៅក្នុងអំឡុងពេលយុវវ័យរបស់លោក ដែលពេលនោះលោកបានចាប់ផ្តើមបង្កើតចក្ខុវិស័យនេះប្រកបដោយមហិច្ឆិតាសម្រាប់ប្រទេសកម្ពុជា ហើយចក្ខុវិស័យនេះត្រូវបានពង្រីកគួរឱ្យកត់សម្គាល់យ៉ាងឆាប់ក្នុងដំណាក់កាលអាជីវកម្ម និងសេដ្ឋកិច្ចសកល។ នេះគឺជាចក្ខុវិស័យ ដែលបានជិតជាប់នឹងបេះដូងដែលលោកបានទទួលពីគ្រួសាររបស់លោក និងបានបង្ហាញយ៉ាងច្បាស់លាស់មិនត្រឹមតែ នៅក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសេវាធនាគារនៅកម្ពុជាជាមួយនឹងធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក B.I.C Markets, និង B.I.C Insurance ប៉ុណ្ណោះទេ ប៉ុន្តែក៏បានឆ្លុះបញ្ចាំងនៅក្នុងគម្រោងបឹងស្នោរដោយមានចក្ខុវិស័យយ៉ាងធំធេង ដែលជាគម្រោងអភិវឌ្ឍអចលនទ្រព្យប្រើប្រាស់ពហុគោលបំណងដោយមានទេសភាពលើកកម្ពស់កម្រិតជីវភាពរស់នៅក្នុងសហគមន៍នេះឱ្យលេចធ្លោផងដែរ។

លោក យឹម លក្ខណ៍ ក៏ជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន Paradise Investment Co., Ltd., និងជាប្រធានក្រុមហ៊ុន Kampot Foods និង SEA Fintech ផងដែរ។ លោកក៏ជានាយកនៃ ក្រុមហ៊ុន B.I.C Markets ផងដែរ។

លោក Zulkiflee Kuan Shun Bin Abdullah

អភិបាល / នាយកប្រតិបត្តិ



បច្ចុប្បន្ន លោក ZULKIFLEE មានបទពិសោធន៍ជាង ៣០ ឆ្នាំ ផ្នែកប្រតិបត្តិការ និងគ្រប់គ្រងសេវាកម្មធនាគារ ដោយចាប់ផ្តើមពីធនាគារ Affin Bank (M) Bhd ហើយក្រោយមកទៀត លោកចូលបម្រើការងារក្នុងធនាគារធំបំផុតមួយរបស់ម៉ាឡេស៊ីគឺ ធនាគារ Public Bank Berhad។ ក្រៅពីប្រទេសម៉ាឡេស៊ី លោក ZULKIFLEE ក៏ធ្លាប់បម្រើការនៅធនាគារ VID Public Bank ក្នុងប្រទេសវៀតណាម នៅឆ្នាំ១៩៩៦ រហូតដល់ឆ្នាំ២០០០ ផងដែរ។ នៅក្នុងអំឡុងពេលលោកបម្រើការងារនៅក្នុងប្រទេសវៀតណាម លោកបានបម្រើការងារនៅទីក្រុងហាណូយ ទីក្រុងហូជីមិញ និងការិយាល័យក្រុងដាណាងផងដែរ។ នៅក្នុងឆ្នាំ២០០៣ លោក ZULKIFLEE បានបម្រើការងារនៅធនាគារ Public Bank Berhad សាខាទីក្រុងវៀងចន្ទ ហើយក្រោយមកទៀត នៅក្នុងឆ្នាំ២០០៨ លោកបានបង្កើតធនាគារ International Commercial Bank Lao Limited ឱ្យក្រុមហ៊ុន ICB Financial Group Holdings AG ដែលពេលនេះបានប្តូរឈ្មោះទៅជាធនាគារ BIC Bank Lao Co., Ltd។

លោក ZULKIFLEE បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតមកពីសាកលវិទ្យាល័យ Multimedia ប្រទេសម៉ាឡេស៊ី និងសញ្ញាបត្រផ្នែកគ្រប់គ្រងមកពី Institute of Supervisory Management ចក្រភពអង់គ្លេស។

លោក Rewin Pataibunlue

អភិបាល



លោក REWIN គឺជាដៃគូស្ថាបនិកនៅក្រុមហ៊ុន PrimeStreet Advisory ដែលនៅក្នុងក្រុមហ៊ុននេះ លោកដឹកនាំផ្នែកសេវាធនាគារវិនិយោគ និងគ្រប់ប្រតិបត្តិការទាំងអស់របស់ក្រុមហ៊ុន។ លោកមានបទពិសោធន៍ជាច្រើនដូចជា ធ្លាប់បម្រើការងារជាធនាគារិកវិនិយោគជាន់ខ្ពស់នៅក្រុមហ៊ុន Quant Group ដែលជាធនាគារវិនិយោគថ្នាក់តំបន់ដែលមានជំនាញឯកទេសផ្នែក M&A និងធ្លាប់ធ្វើជា CFO និងជាប្រធានអភិវឌ្ឍន៍អាជីវកម្មនៅក្រុមហ៊ុនជលិតផលទំនើបធំបំផុតមួយនៅក្នុង SEA ផងដែរ។ ជំនាញឯកទេសរបស់លោករួមមានដូចជា ហិរញ្ញវត្ថុសាជីវកម្ម ការរួមបញ្ចូលគ្នា និងការទិញយកក្រុមហ៊ុន និងហិរញ្ញប្បទាន។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយលើវិស័យជាច្រើន ដូចជា ទូរគមនាគមន៍ ហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងសេវាសាធារណៈ រ៉ែ អចលនទ្រព្យ និងក្រុមហ៊ុនគ្រឹះស្ថានហិរញ្ញវត្ថុ។ ការងារអនុវត្តរបស់លោកបានពង្រីករហូតដល់ M&A ឆ្លងប្រទេស និងការផ្សព្វផ្សាយមូលនិធិសមធម៌ឯកជន ក៏ដូចជាមូលនិធិការពារហានិភ័យ (hedge fund) ផងដែរ។

នាពេលថ្មីៗនេះ លោក REWIN ដឹកនាំក្រុមផ្តល់ប្រឹក្សាយោបល់ដល់អាជ្ញាធរអំពីគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំដែលមានទឹកប្រាក់ចំនួន ២,៧ ពាន់លានបាត-រួមមាន គម្រោង រថភ្លើងល្បឿនលឿន MRTA និង SRT។ លោកក៏បានប្រឹក្សា TOT និង CAT ក្នុងភាពជាដៃគូ JV ដែលអាចមាន ព្រមទាំងគម្រោងចែករំលែកហេដ្ឋារចនាសម្ព័ន្ធផងដែរ (គម្រោង Tower Co ដែលមានទឹកប្រាក់ចំនួន ៤0ពាន់លានបាត និងគម្រោង Fiber Co ដែលមានទឹកប្រាក់ ៣0 ពាន់លានបាត)។ លោក REWIN តែងតែត្រូវបានអញ្ជើញឱ្យធ្វើជាវាគ្មិនកិត្តិយសជាញឹកញាប់នៅក្រុមហ៊ុនឯកជន និងស្ថាប័នរដ្ឋាភិបាលមួយចំនួន។

លោក REWIN បានទទួលបរិញ្ញាបត្រផ្នែកវិស្វកម្មស៊ីវិលពីសាកលវិទ្យាល័យជូឡាឡុងកន និង MBA មកពីសាលា Sloan School of Management នៅ MIT ផងដែរ។

លោក Rutsaran Moonsan

អភិបាល



លោក RUTSARAN MOONSAN គឺជាអនុប្រធានរបស់ក្រុមហ៊ុន AIF Group ទទួលបន្ទុកផ្នែកជួញដូរលោហៈមានតម្លៃផ្នែកជួញដូរទូទៅ និងក្រុមហ៊ុនបុត្រសម្ព័ន្ធចំណីអាហារ និងភេសជ្ជៈរបស់គ្រុប។ លោក RUTSARAN ទទួលបានបរិញ្ញាបត្រផ្នែកកសិឧស្សាហកម្មមកពីសាកលវិទ្យាល័យ Kasetsart ប្រទេសថៃ និងសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកធុរកិច្ចអន្តរជាតិពី University of Greenwich ទីក្រុងឡុងដ៍ រួមមានទាំងវិញ្ញាបនបត្រ កិត្តិយសកម្រិតពីរផងដែរ។

មុនពេលចូលរួមបម្រើការងារជាមួយនឹងក្រុមហ៊ុន AIF Group លោក RUTSARAN ធ្លាប់មានបទពិសោធន៍បម្រើការងារជាង ៨ ឆ្នាំផ្នែកជួញដូរ និងសេវាធនាគារ។ នៅអំឡុងពេលបម្រើការងារក្នុងធនាគារ លោកត្រូវបានចាត់តាំងឱ្យធ្វើជាប្រធានផ្នែកទំនាក់ទំនងសម្រាប់អតិថិជនសំខាន់ៗមួយចំនួនរបស់ធនាគារ រួមទាំងប្រតិបត្តិការគណនីបង្គរដែលមានទឹកប្រាក់ជាង ១ ពាន់លានបាត ហើយអាចនឹងកើនទ្វេដងលើតម្លៃប្រតិបត្តិការគណនីក្នុងរយៈពេលមួយឆ្នាំទៀតផង។ ក្រោយមកទៀត លោក RUTSARAN បានចូលរួមបម្រើការងារជាមួយនឹង YLG Bullion International ហើយត្រូវបានចាត់តាំងឱ្យបង្កើតសាខាក្រុមហ៊ុននៅក្នុងប្រទេសសិង្ហបុរី និងធ្វើការជ្រើសរើសអតិថិជនអន្តរជាតិថ្មីៗ។ ដោយមានទេពកោសល្យផ្នែកទំនាក់ទំនង និងជំនាញជួញដូរលោកបានចូលរួមចំណែកជួយ YLG ឱ្យក្លាយជាក្រុមហ៊ុន Bullion Trading ដ៏ធំបំផុតមួយនៅប្រទេសថៃ។ នៅពេលចូលរួមបម្រើការងារ ជាមួយក្រុមហ៊ុន AIF Group លោក RUTSARAN បានជួយអភិវឌ្ឍក្រុមហ៊ុន AIF Gold Trading ដើម្បីឱ្យក្លាយជាក្រុមហ៊ុននាំចូលមាសធំបំផុត និងសកម្មតែមួយគត់នៅក្នុងប្រទេសឡាវ។

លោកក៏បានជួយរៀបចំឱ្យក្រុមហ៊ុន Asia Loyal ក្លាយជា ក្រុមហ៊ុនចែកចាយដែលមានភាពជោគជ័យលើវិស័យជាច្រើន ដូចជា យានយន្ត និងសម្ភារសំណង់ និងវិស័យផ្សេងទៀតជាច្រើន។ ក្នុងការគាំទ្រអាជីវកម្មអភិវឌ្ឍន៍អចលនទ្រព្យរបស់គ្រុបនេះ លោកក៏បានផ្តួចផ្តើម និងបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធចំណីអាហារ និងភេសជ្ជៈឱ្យក្រុមហ៊ុន AIF Group ផងដែរ។

បច្ចុប្បន្ន លោក RUTSARAN MOONSAN មានតួនាទីជាក្រុមប្រឹក្សាប្រតិបត្តិទាំងនៅធនាគារ BIC Bank Lao Co., Ltd និង ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក។

គណៈគ្រប់គ្រង





គណៈគ្រប់គ្រង



លោកស្រី Adel Leilanie G. Legarta
នាយកប្រតិបត្តិប្រតិបត្តិការ

លោកស្រី ADEL បានបញ្ចប់ការសិក្សាលើមុខជំនាញ ការគ្រប់អាជីវកម្មពី Pontifical University of Santo Tomas ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។ នៅក្នុងឆ្នាំ ១៩៩១ លោកស្រីបានចាប់ផ្តើមអាជីពរបស់ខ្លួននៅ Rizal Commercial Banking, Makati ប្រទេសហ្វីលីពីន។

នៅក្នុងឆ្នាំ ២០០១ លោកស្រីបានមកដល់ប្រទេសកម្ពុជា ហើយបានបម្រើការងារនៅក្នុងធនាគារកាណាឌីយ៉ា ក្នុងឋានៈជាប្រធានផ្នែករៀបចំផែនការ ជំនួយការផ្នែកមជ្ឈមណ្ឌលផ្តល់ព័ត៌មាន (Card Center) ប្រធានផ្នែកទីផ្សារ និងប្រធានផ្នែកទំនាក់ទំនងធុរកិច្ចអន្តរជាតិ។ លោកស្រីបានចូលរួមក្នុងការិយាល័យមេធាវី និងវិនិយោគ ស្ការ៉ូនី អេន អាសូស៊ីអឺត ក្នុងខែឧសភា ឆ្នាំ២០០៦។

បន្ទាប់មក នៅក្នុងខែមេសា ឆ្នាំ២០០៨ លោកស្រីបាន បម្រើការងារនៅក្នុងធនាគារ ABA ក្នុងមុខតំណែងគ្រប់គ្រងជាន់ខ្ពស់ជាច្រើនដូចជាប្រធានផ្នែកទីផ្សារ ប្រធានផ្នែកទំនាក់ទំនងអតិថិជន និងប្រធានសាខាធំផងដែរ។

បច្ចុប្បន្ន លោកស្រី Legarta កំពុងបម្រើការងារនៅធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ក្នុងនាមជានាយកប្រតិបត្តិប្រតិបត្តិការ។



លោក ឃឹម ច័ន្ទដារ៉ា
ប្រធានគ្រប់គ្រងជាន់ខ្ពស់

លោក ដារ៉ា បានចូលរួមបម្រើការងារជាមួយនឹងធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ជាប្រធានគ្រប់គ្រងជាន់ខ្ពស់។ លោកមានបទពិសោធន៍ជាង ១៤ ឆ្នាំ នៅធនាគារពាណិជ្ជចំនួនពីរ រួមមានធនាគារកាណាឌីយ៉ា ភីអិលស៊ី និងធនាគារភ្នំពេញពាណិជ្ជ។ លោកមានបទពិសោធន៍ផ្នែកគ្រប់គ្រងវាយតម្លៃឥណទាន ទំនាក់ទំនងអតិថិជនឥណទានពាណិជ្ជកម្ម សហគ្រាសធុនតូច និងមធ្យម (SME) ប្រធានគ្រប់គ្រងសាខាជាន់ខ្ពស់ និងប្រធានគ្រប់គ្រងសាខា VIP។

លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ នៅឆ្នាំ២០០៥ និងថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ នៅឆ្នាំ២០០៧ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។



លោក បាន ម៉ាវ៉ា
ប្រធានផ្នែកហិរញ្ញវត្ថុ

លោក ម៉ាវ៉ា បានចូលបម្រើការងារនៅធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ក្នុងខែកញ្ញា ឆ្នាំ២០១៨ ជាប្រធានផ្នែកហិរញ្ញវត្ថុ។ លោកមានបទពិសោធន៍ជាង ៨ ឆ្នាំ ផ្នែកហិរញ្ញវត្ថុនៅធនាគារពាណិជ្ជចំនួនពីរ ដូចជាធនាគារ ភ្នំពេញពាណិជ្ជ និងធនាគារ ហ្វីលីព គីអិលស៊ី។ លោកមានបទពិសោធន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ពន្ធដារ ការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំថវិកា ការរៀបចំផែនការអាជីវកម្ម ហើយក៏មានបទពិសោធន៍គ្រប់គ្រងគម្រោងនានាផងដែរ រួមមាន CIFRS និងប្រព័ន្ធស្នូលធនាគារ។

លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារពីសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ២០១០ ហើយបច្ចុប្បន្ន លោកកំពុងបន្តការសិក្សាកម្រិត ACCA នៅសាលា CamED Business School នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។



លោក សេង វេសាលោ
ប្រធានផ្នែកព័ត៌មានវិទ្យា (ប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) & ប្រព័ន្ធស្នូលធនាគារ)

លោក វេសាលោ បានបញ្ចប់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ និងវិស្វកម្មកុំព្យូទ័រនៅឆ្នាំ២០០៨ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ នៅឆ្នាំ២០០៩ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសញ្ញាបត្រជាន់ខ្ពស់គរុកោសល្យផ្នែកព័ត៌មានគ្រប់គ្រង និងភាពជាអ្នកដឹកនាំ នៅឆ្នាំ ២០១១ នៅវិទ្យាស្ថានជាតិអប់រំ។

លោកបានកំពុងបម្រើការងារក្នុងវិស័យធនាគារជាង ៧ ឆ្នាំ ដោយមានបទពិសោធន៍ ផ្នែកប្រព័ន្ធស្នូលធនាគារ MIS ការបង្កើតរបាយការណ៍រដ្ឋបាលមូលដ្ឋានទិន្នន័យ ការរួមបញ្ចូលប្រព័ន្ធការអភិវឌ្ឍន៍នៅខាងក្នុងក្រុមហ៊ុន និងការវិភាគការងារព័ត៌មានវិទ្យា (IT)។លោក វេសាលោ បានចូលរួមបម្រើការងារជាមួយធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក នៅខែធ្នូ ឆ្នាំ២០១៨ ជាប្រធានផ្នែកព័ត៌មានវិទ្យា (IT)។



លោក ស្មើ ម៉េងលីម
ប្រធានផ្នែកសេវាធនាគារឌីជីថល

លោក ម៉េងលីម បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ២០០៦ និងបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកវិស្វកម្មកុំព្យូទ័រពីសាកលវិទ្យាល័យ Lucian Blaga University of Sibiu ប្រទេសរូម៉ានី ក្នុងឆ្នាំ២០១៣។ សូមបញ្ជាក់ផងដែរថា ការសិក្សាទាំងពីរខាងលើនេះ គឺជាការសិក្សាថ្នាក់អាហារូបករណ៍របស់លោក។

លោក ម៉េងលីម មានបទពិសោធន៍ប្រមាណជា ៨ ឆ្នាំជាមួយនឹងក្រុមហ៊ុនឯកជន និងវិស័យធនាគារផងដែរ ក្នុងនោះលោកបានបម្រើការងារផ្នែកគាំទ្រប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អ្នកផ្តល់ដំណោះស្រាយ បង្កើតកម្មវិធីសូហ្វវែរ អនុវត្តប្រព័ន្ធឌីជីថល ប្រព័ន្ធ FAST NBC គ្រប់គ្រងម៉ាស៊ីន ATM បញ្ចូល APIs និងគ្រប់គ្រងគម្រោងផងដែរ។

លោក ម៉េងលី បានចូលរួមបម្រើការងារជាមួយនឹងធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ជាប្រធានផ្នែកសេវាធនាគារឌីជីថលចាប់តាំងពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩។



លោក យុន វ៉ែត
ប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល

លោក វ៉ែត បានបញ្ចប់បរិញ្ញាបត្រ ផ្នែកអក្សរសាស្ត្រអង់គ្លេស ពីសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (PPIU) នៅឆ្នាំ២០១០ និងបានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែករដ្ឋបាលអាជីវកម្ម (MBA) នៅសាកលវិទ្យាល័យន័រតុននៅឆ្នាំ២០១៦។

ដោយសារតែការប្តេជ្ញាចិត្ត និងការចូលចិត្តរបស់ខ្លួន លោក វ៉ែត បានវិវត្តការងាររបស់ខ្លួនពីជំនួយការរដ្ឋបាល នៅសាកលវិទ្យាល័យខ្លួន ទៅជាមន្ត្រីរដ្ឋបាលនៅធនាគារពាណិជ្ជភ្នំពេញជាមន្ត្រីប្រតិបត្តិរដ្ឋបាលជាន់ខ្ពស់ នៅធនាគារហ្វីលីព ភីអិលស៊ី បន្ទាប់មកត្រូវបានដំឡើងតួនាទីជាប្រធានរដ្ឋបាលនៅក្នុងរយៈពេល ៧ ឆ្នាំ។ លោកមានបទពិសោធន៍ជាង១០ ឆ្នាំជាមួយធនាគារពាណិជ្ជនៅក្នុងផ្នែកជំនាញរបស់គាត់។

លោក វ៉ែត បានចូលរួមបម្រើការងារជាមួយនឹងធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ជាប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល។



លោក Thongsavath Pranyvong
ប្រធានផ្នែកប្រតិបត្តិ

លោក THONGSAVATH បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកការគ្រប់គ្រងធុរកិច្ច និងរដ្ឋបាល ពីសាកលវិទ្យាល័យ London School of Commerce (សាលានៅក្នុងទីក្រុងឡុងដ៍) ដែលជាសាកលវិទ្យាល័យសាខារបស់សាកលវិទ្យាល័យ Cardiff Metropolitan University ទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស។

លោក Thongsavath បានចាប់ផ្តើមបម្រើការងារនៅធនាគារ BIC Bank Lao Co., Ltd ចាប់តាំងពីចុងឆ្នាំ២០១០ មកក្នុងនាមជា CSR និងបេឡាករ។ ចាប់តាំងពីពេលនោះមក លោកត្រូវបានដំឡើងតំណែងជាមន្ត្រីឥណទាន និងមន្ត្រីឥណទានជាន់ខ្ពស់។ ក្នុងឆ្នាំ២០១៧ លោក Thongsavath បានប្តូរតំណែងមកជាប្រធានផ្នែករតនាគារ និងប្រធានផ្នែកទំនាក់ទំនង។ ជាមួយនឹងបទពិសោធន៍ទាំងអស់របស់លោក លោកត្រូវបានជ្រើសរើសឱ្យបម្រើការងារជាប្រធានផ្នែកប្រតិបត្តិការនៅក្នុងធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ចាប់តាំងពីឆ្នាំ២០១៩ រហូតមកដល់ពេលបច្ចុប្បន្ននេះ។



លោក ឌុច គឹមហាក់
ប្រធានផ្នែកអាជីវកម្មកាត

លោក គឹមហាក់ មានបទពិសោធន៍ការងារជាង ១១ ឆ្នាំផ្នែកបច្ចេកវិទ្យាទូទាត់ប្រាក់តាមប្រព័ន្ធឌីជីថល ដែលរួមមានផលិតផលនិងសេវាកម្ម ដូចជា ម៉ាស៊ីនឆូតកាត (POS) ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) កម្មវិធីទូទាត់កាតអន្តរជាតិ ទាំងកាតឥណពន្ធ និងឥណទាន។ លោកបានចាប់ផ្តើមការងារជានាយកផ្នែកទីផ្សារនៃក្រុមហ៊ុន A.C.G Real Estate Group នៅឆ្នាំ២០០៧។ នៅក្នុងខែមេសា ឆ្នាំ២០០៨ លោកបានចាប់ផ្តើមអាជីពការងារធនាគារនៅក្នុងធនាគារកាណាឌីយ៉ា ក្នុងមុខតំណែងជាអ្នកចេញកាតឥណទាន ហើយក្រោយមកជាមន្ត្រីប្រតិបត្តិការកាតជាន់ខ្ពស់។ ក្នុងខែមិថុនា ឆ្នាំ២០១៥ លោកបានធ្វើការងារនៅក្នុងធនាគារស៊ិនហាន កម្ពុជា ក្នុងមុខតំណែងជាច្រើនដូចជាមន្ត្រីកាតជាន់ខ្ពស់ អនុប្រធានអាជីវកម្មកាត ហើយត្រូវបានតែងតាំងជាផ្នែកអនុប្រធានផ្នែកបម្រើអតិថិជន។ លោកគ្រប់គ្រងដំណើរការកាតទាំងអស់ អាជីវកម្មកាត យុទ្ធសាស្ត្រ និងការរៀបចំផែនការកាត វិភាគទិន្នន័យកាត ការផ្សព្វផ្សាយទីផ្សារ និងគ្រប់គ្រងបណ្តឹងអតិថិជន។

លោក គឹមហាក់ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោកបានចូលរួមកម្មវិធីបណ្តុះបណ្តាលសំខាន់ស្តីពីទំនោរអន្តរកាលបច្ចេកវិទ្យាទូទាត់តាមកាត ដែលបានផ្តល់ជូនដោយក្រុមហ៊ុនកាតអន្តរជាតិដូចជា វីសា និងម៉ាស្ទ័រ UPI ទាំងក្នុងស្រុក និងក្រៅស្រុក។

បច្ចុប្បន្ន លោក គឹមហាក់ ចូលបម្រើការងារនៅក្នុងធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ជាប្រធានអាជីវកម្មកាត។



លោក ហុង ប៊ុនថ្ល័យ
ប្រធានផ្នែកសវនកម្មផ្ទៃក្នុង

លោក ប៊ុនថ្ល័យ ចូលបម្រើការងារនៅក្នុងធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ក្នុងតំណែងជាប្រធានផ្នែកសវនកម្មផ្ទៃក្នុង ក្នុងខែកញ្ញា ឆ្នាំ២០១៩។ លោកមានបទពិសោធន៍រហូតដល់ទៅ ៦ ឆ្នាំលើការងារសវនកម្មផ្ទៃក្នុង និងខាងក្រៅ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនក្នុងប្រទេស និងអន្តរជាតិ។ ជំនាញឯកទេសរបស់លោកគឺពាក់ព័ន្ធនឹងការត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គ្រប់គ្រងហានិភ័យ អភិបាលកិច្ចក្រុមហ៊ុន និងការសើបអង្កេតការក្លែងបន្លំ/ការប្រព្រឹត្តិមិនត្រឹមត្រូវនៅក្នុងស្ថានប័ន។

មុនពេលចូលរួមជាមួយធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក លោកធ្លាប់បានកាន់តំណែងជាច្រើនដូចជាជំនួយការសវនកម្មក្នុងក្រុមហ៊ុន KPMG Cambodia Ltd ប្រធានគ្រប់គ្រងសវនកម្មផ្ទៃក្នុងនៅធនាគារ ABA និងតួនាទីថ្នាក់គ្រប់គ្រងផ្សេងៗទៀត។ ប៊ុនថ្ល័យ បានបញ្ចប់បរិញ្ញាបត្រផ្នែកគណនេយ្យពីសាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) និងបរិញ្ញាបត្រផ្នែកទំនាក់ទំនងអន្តរជាតិ (សេដ្ឋកិច្ចអន្តរជាតិ) ពីវិទ្យាស្ថានភាសាបរទេស (IFL)។ បច្ចុប្បន្ន លោកកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសញ្ញាបត្រ ACCA ពីសាលា CamEd Business School។ លើសពីនេះ លោកមានវិញ្ញាបនបត្រវិជ្ជាជីវៈជាច្រើនពីស្ថានប័ន/គ្រឹស្ថានវិជ្ជាជីវៈក្នុងប្រទេស និងក្រៅប្រទេសផងដែរ។



ភាពរីកចម្រើន និងការអភិវឌ្ឍ

ការពង្រឹងសេវាថែទាំអតិថិជន



"អតិថិជនទីមួយ"

គឺជាចំណុចអាទិភាពមួយរបស់ធនាគារ។ ធនាគារមានគោលដៅផ្តល់សេវាថែទាំអតិថិជន ដោយធានាចំពោះការពេញចិត្ត និងទំនាក់ទំនងប្រកបដោយភាពរីកជាមួយនឹងសាខាធនាគារ ផលិតផល និងសេវាកម្ម។

ដោយសារតែវិយោបថរបស់អតិថិជនពាក់ព័ន្ធនឹងសេវាកម្មធនាគារមានការប្រែប្រួល ធនាគារបានបង្កើតផលិតផល និងសេវាកម្ម ដែលសមស្របទៅនឹងតម្រូវការធានាគារដែលកំពុងមានការកើនឡើងនេះ។

ក្នុងឆ្នាំ២០១៩ ធនាគារបានធ្វើការណែនាំនូវគណនីសកម្មចរន្តមួយ ដែលជាប្រភេទគណនីត្រួតពិនិត្យ ដែលសន្សំការប្រាក់ និងដែលមានលក្ខណៈពិសេសសមស្របទៅនឹងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់អតិថិជន។

ការវិនិយោគមូលនិធិ ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនលក់រាយ និងអតិថិជនសាជីវកម្មទាំងអស់។ គណនីមានកាលកំណត់កំណើនខ្ពស់ ផ្តល់ជូនអតិថិជននូវអត្រាការប្រាក់ប្រកួតប្រជែងសម្រាប់តម្លៃសាច់ប្រាក់។ គណនីវិនិយោគ ផ្តល់ជូននូវភាពបត់បែន ដែលអាចឱ្យអតិថិជន ជ្រើសរើសជម្រើសរវាងឥណទានការប្រាក់សម្រាប់គណនី ឬការប្រាក់ចិទនៅថ្ងៃដល់កំណត់។ ឥណទានវិបារូបន៍ ក៏មានផ្តល់ជូនផងដែរក្នុងករណីមានតម្រូវការ ជាមួយនឹងម៉ាជីនទាប។

ផលិតផលជាច្រើនទៀតកំពុងត្រូវបានរៀបចំឡើង ហើយយើងត្រូវតែមានភាពប្រាកដប្រជាថាយើងពិតជាបានបំពេញតាមសេចក្តីត្រូវការរបស់អតិថិជន ក្នុងលក្ខណៈមួយដែលឆ្លុះបញ្ចាំងជាវិជ្ជមានទាំងសម្រាប់ធនាគារ និងអតិថិជនផ្ទាល់តែម្តង។ ធនាគារ ប្តេជ្ញាចិត្តក្នុងការផ្តល់បទពិសោធន៍ល្អៗជូនដល់អតិថិជន ដែលការប្តេជ្ញាចិត្តនេះហើយបានជំរុញឱ្យយើងទាំងអស់គ្នារួមគ្នាបង្កើតនូវកម្មវិធីគុណតម្លៃធនាគារ ប៊ី.អាយ.ស៊ី ដែលជាកម្មវិធីស្មោះត្រង់របស់ធនាគារ (Loyalty Program) ក្រោមកិច្ចសហការជាដៃគូជាមួយនឹងពាណិជ្ជករជាច្រើន រួមមានដូចជាវិស័យអាហារ និងភេសជ្ជៈ សណ្ឋាគារ គ្លីនីក និងវិស័យជាច្រើនផ្សេងទៀត។ វិស័យទាំងអស់នេះ នឹងផ្តល់ជូនសេវាកម្មដ៏ល្អប្រសើរជូនដល់ម្ចាស់កាតទាំងអស់។

អតិថិជនដែលពេញចិត្តទាំងអស់ នឹងមិនចាប់អារម្មណ៍ចំពោះការផ្តល់ជូនរបស់ដៃគូប្រកួតប្រជែងរបស់អ្នកទេ ពោលគឺ ពួកគេនឹងបង្ហាញភាពរីករាយ ព្រមទាំងបន្តប្រើប្រាស់សេវាតាមសាខារបស់អ្នក ហើយណែនាំផលិតផលនេះទៅកាន់អ្នកដទៃទៀតផងដែរ។ ប្រសិនបើអ្នកបំពេញតាមលក្ខខណ្ឌតម្រូវទាំងអស់របស់អតិថិជន ហើយបានឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ ក្នុងអំឡុងពេលកំពុងផ្តល់សេវាកម្មដ៏ល្អបំផុតរបស់អ្នក នោះអតិថិជននឹងពេញចិត្តជាទីបំផុត។

ការអភិវឌ្ឍនិយោជិត



ធនាគារ ប៊ី.អាយ.ស៊ី បានចាប់ផ្តើមប្រតិបត្តិការនីខែសីហា ឆ្នាំ២០១៨ ដែលមានបុគ្គលិក

ចំនួន ២៦ នាក់

ហើយឆ្នាំ ២០១៩ កើនឡើងដល់

ចំនួន ៥០ នាក់

ក្នុងនាមជាធនាគារថ្មីមួយ យើងបានផ្តល់ការសិក្សារៀនសូត្រ ការបណ្តុះបណ្តាល និងឱកាសអភិវឌ្ឍជាច្រើនទាំងនៅក្នុងធនាគារ និងនៅស្ថាប័នខាងក្រៅផងដែរ ដើម្បីគាំទ្រដល់គ្រប់ដំណាក់កាលនៃដំណើរការអភិវឌ្ឍខ្លួនទាំងអស់ សម្រាប់ទាំងបុគ្គលិកថ្មី និងបុគ្គលិកចាស់របស់យើង។

កម្មវិធីចល័តបុគ្គលិកគឺជា កម្មវិធីមួយនៅក្នុងចំណោមវិធីសាស្ត្ររបស់យើងក្នុងការអភិវឌ្ឍ និងផ្តល់ឱកាសដល់បុគ្គលិកមានសក្តានុពលម្នាក់ៗ ដែលមានបំណងបង្កើនទេពកោសល្យ និងជោគវាសនាអនាគតរបស់ខ្លួន។

ការផ្តល់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុងាយស្រួល និងមានទំនុកចិត្តដល់អតិថិជនរបស់យើង អាចសម្រេចបាន លុះត្រាតែធនាគាររបស់យើង មានធនធានមនុស្សដែលពោរពេញដោយទេពកោលស្យ ធ្វើការជាមួយយើង។ យើងសូមស្វាគមន៍ និងលើកទឹកចិត្តដល់បុគ្គលិកវ័យក្មេង និងបុគ្គលិកមានទេពកោសល្យ ដែលមានបំណងបង្កើនចំណេះដឹង និងបន្តរៀនសូត្រចំណេះដឹងថ្មីៗ ជាមួយយើង ដើម្បីស្វែងយល់ និងបំពេញតម្រូវការរបស់អតិថិជន ព្រមទាំងគាំទ្រ និងជួយគ្នាទៅវិញទៅមក។

ការបន្តកិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការផ្តល់ឱកាសជាច្រើន សម្រាប់វឌ្ឍនភាពការងារដោយយល់ដឹងថាបុគ្គលិកគឺជា ទ្រព្យសកម្ម ដើម្បីសម្រេចនូវទស្សនវិស័យរបស់ធនាគារ ធនាគារខិតខំធ្វើការទាក់ទាញ និងជ្រើសរើសបេក្ខជន ដែលមានសេចក្តីជឿជាក់ តរិយាបទ និងកម្រិតបទពិសោធន៍ត្រឹមត្រូវ ដែលធនធានត្រូវការ ដើម្បីសម្រេចបានជោគជ័យរបស់ខ្លួន។ ធនាគារជឿជាក់ថា ក្របខ័ណ្ឌអភិវឌ្ឍធនធានមនុស្ស ដែលអាចជួយបុគ្គលិកក្នុងការអភិវឌ្ឍជំនាញ ចំណេះដឹង និងសមត្ថភាពផ្ទាល់ខ្លួន និងធនាគារ គឺជាកត្តាដ៏សំខាន់ក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស ដែលអាចសម្រេចបាននូវគោលដៅរបស់ធនាគារប្រកបដោយភាពជោគជ័យ។

ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចធនាគារ

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវរួមចំពោះការបង្កើត និងការត្រួតពិនិត្យមើលក្របខណ្ឌគ្រប់គ្រងហានិភ័យរបស់ធនាគារ។

ធនាគារបានបង្កើតគោលនយោបាយគ្រប់គ្រងហានិភ័យ ដើម្បីកំណត់ និងវិភាគហានិភ័យ ដែលធនាគារបានជួបប្រទះ ដោយដាក់ចេញនូវប្រព័ន្ធកម្រិត និងគ្រប់គ្រងហានិភ័យសមស្របព្រមទាំងតាមដានហានិភ័យ និងគោរពតាមការកម្រិតនេះផងដែរ។

ធនាគាររបស់យើងប្រឈមនឹងហានិភ័យសំខាន់ៗ ដែលកើតចេញពីឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោម៖

- ហានិភ័យប្រតិបត្តិការ
- ហានិភ័យឥណទាន
- ហានិភ័យទីផ្សារ
- ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺជាហានិភ័យខាតបង់ដោយផ្ទាល់ ឬដោយប្រយោល ដែលកើតឡើងដោយសារតែប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង បុគ្គលិក បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ ឬមិនមានប្រសិទ្ធភាព និងដោយសារតែកត្តាខាងក្រៅផ្សេងទៀតក្រៅពីហានិភ័យឥណទាន ហានិភ័យ ទីផ្សារ និងហានិភ័យសាច់ប្រាក់ងាយស្រួល ដូចជាហានិភ័យដែលកើតចេញពីលក្ខខណ្ឌតម្រូវផ្លូវ និងនិយ័តកម្ម និងស្តង់ដារដែលអាចទទួលយកបានជាទូទៅនៃឥរិយាបថរបស់ធនាគារផងដែរ។

ធនាគារអាចគ្រប់គ្រងការខាតបង់ ដោយសារតែហានិភ័យប្រតិបត្តិការនេះបាន តាមរយៈការបង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យប្រតិបត្តិការ ការតាមដាន និងការរាយការណ៍ត្រឹមត្រូវអំពីសកម្មភាពអាជីវកម្មដោយអង្គភាពត្រួតពិនិត្យ និងគាំទ្រដែលជាអង្គភាពឯករាជ្យ ព្រមទាំងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ។

ការគ្រប់គ្រងហានិភ័យប្រតិបត្តិការនៅក្នុងធនាគារ អាចសម្រេចបានតាមរយៈការបង្កើតរចនាសម្ព័ន្ធធនាគារ តួនាទី និងគោលនយោបាយត្រួតពិនិត្យច្បាស់លាស់។
គោលនយោបាយ
និងវិធានត្រួតពិនិត្យផ្ទៃក្នុងនានា ត្រូវបានអនុវត្ត រួមមានការបង្កើតឱ្យមានសិទ្ធិចុះហត្ថលេខា ការត្រួតពិនិត្យប៉ារ៉ាម៉ែត្រប្រព័ន្ធ ការបញ្ជាបនីតិវិធី និងឯកសារ ព្រមទាំងការអនុវត្តតាមលក្ខខណ្ឌតម្រូវនិយ័តកម្ម និងផ្លូវច្បាប់ផ្សេងទៀតផងដែរ។

ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ចំណូល និងការខាតបង់ដើមទុនដែលអាចមានក្នុងទម្រង់ជាសំវិធានធនជាក់លាក់ ដោយសារតែអ្នកខ្ចី ឬសមភាគីមិនបំពេញតាមកាតព្វកិច្ចក្នុងកិច្ចសន្យារបស់ខ្លួន ក្នុងការផ្តល់ឥណទានជូនអតិថិជន និងសកម្មភាពវិនិយោគ។

ធនាគារប្រាកដថា មានការបែងចែកភារកិច្ចច្បាស់លាស់រវាងអ្នកផ្តើមឱ្យ ឥណទាន អ្នកវាយតម្លៃ ឧបករណ៍វាយតម្លៃផ្ទៃក្នុង និងសិទ្ធិអំណាចអនុម័ត។

ការកំណត់ពិន្ទុហានិភ័យត្រូវតែធ្វើការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ហើយក្នុងករណីដែល (i) មានការផ្លាស់ប្តូរទៅលើ ខ និងលក្ខខណ្ឌឥណទានរួមមាន ការពន្យារពេល (ii) ការសងមិនទៀងទាត់ ឬសងហួសកាលកំណត់ និង (iii) ព័ត៌មានមិនល្អ ដែលមានទាក់ទងជាមួយការខ្ចី ឬប្រតិបត្តិការ។

ធនាគារដាក់ចេញនូវគោលនយោបាយ និងគោលការណ៍អនុវត្តជាច្រើន ដើម្បីកាត់បន្ថយហានិភ័យឥណទាន។ គោលនយោបាយ និងការអនុវត្តធម្មតាបំផុត គឺជាការចាត់វិធានការសន្តិសុខក្នុងទម្រង់ជាវត្ថុបញ្ចាំ សម្រាប់ឥណទានដែលផ្តល់ជូនអតិថិជន ដែលជាការអនុវត្តទូទៅ។ ក្រុមហ៊ុនអនុវត្តតាមគោលការណ៍ណែនាំស្តីពីការទទួលយកប្រភេទជាក់លាក់នៃការកាត់បន្ថយហានិភ័យវត្ថុបញ្ចាំ ឬហានិភ័យឥណទាន។

ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារគឺជា ហានិភ័យនៃការខាតបង់ ដែលកើតចេញពីដំណើរការប្រែប្រួលអវិជ្ជមាននៃតម្លៃ ឬអត្រាក្នុងទីផ្សារ ដែលសមាសធាតុសំខាន់ពីរគឺហានិភ័យអត្រាប្តូរប្រាក់ និងហានិភ័យអត្រាការប្រាក់។

ហានិភ័យទីផ្សារ ដែលកើតចេញពីសកម្មភាពជួញដូរ ត្រូវបានត្រួតពិនិត្យដោយការកំណត់លើទីផ្សារនូវស្ថានភាពជួញដូរ ដោយធៀបជាមួយការកម្រិតហានិភ័យទីផ្សារដែលបានកំណត់ជាមុន។

ហានិភ័យអត្រាប្តូរប្រាក់ គឺជាហានិភ័យនៃការខាតបង់ ដោយសារតែការធ្លាក់តម្លៃនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការប្រែប្រួលអត្រាប្តូរប្រាក់ ឬសកម្មភាពជួញដូរអត្រាប្តូរប្រាក់។


ហានិភ័យអត្រាប្តូប្រាក់ គឺជាការខាតបង់ប្រាក់ចំណូល ដែលអាចមានដោយសារតែការប្រែប្រួលតម្លៃទ្រព្យសកម្មរបស់ធនាគារ ដែលបណ្តាលមកពីការប្រែប្រួលអត្រាការប្រាក់នៅក្នុងទីផ្សារ។

ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល គឺមានទំនាក់ទំនងជាមួយលទ្ធភាពក្នុងការរក្សាទ្រព្យសកម្មសន្ទនីយភាពគ្រប់គ្រាន់ ដើម្បីបំពេញតាមកិច្ចសន្យាផ្តល់ និងកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កំណង់សង តាមការចំណាយមួយសមស្រប។

ក្រៅពីការអនុវត្ត ឱ្យបានពេញលេញតាមលក្ខខណ្ឌតម្រូវសាច់ប្រាក់ងាយស្រួលទាំងអស់ គណៈគ្រប់គ្រងធនាគារក៏ធ្វើការតាមដានយ៉ាងល្អិតល្អន់លើលំហូរចូល និងលំហូរចេញទាំងអស់ ព្រមទាំងភាពលម្អៀងរវាងតម្លៃដើមគ្រា តាមរបាយការណ៍ជាប្រចាំផងដែរ។ ដំណើរការចំពោះឥណទាន និងបញ្ជើបស់អតិថិជនត្រូវធ្វើការត្រួតពិនិត្យ និងកែសម្រួលលក្ខខណ្ឌសាច់ប្រាក់ងាយស្រួល ដើម្បីធានាបានទ្រព្យសកម្មសន្ទនីយភាពគ្រប់គ្រាន់ក្នុងការបំពេញតាមកិច្ចសន្យា និងកាតព្វកិច្ចហិរញ្ញវត្ថុ ព្រមទាំងនៅពេលវាដល់កំណត់សងផងដែរ។

ការធ្វើទំនើបកម្ម ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន



ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ប្តេជ្ញាកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានប្រកបដោយចីរភាព ដើម្បីដោះស្រាយបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងអនាគត។

ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានគឺជាមូលដ្ឋានគ្រឹះសម្រាប់សេវាឌីជីថល និងសេវាធម្មតារបស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក។ ដើម្បីរក្សាសេវាធនាគារកម្រិតខ្ពស់បំផុត ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក តែងតែវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនជានិច្ច។

នៅឆ្នាំ២០១៩ ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក បានបោះជំហានយ៉ាងសំខាន់បំផុតដើម្បីបង្កើតបរិយាកាសការងារតាមប្រព័ន្ធឌីជីថល ដោយបានជ្រើសរើសដំណោះស្រាយល្អបំផុតនៅលើទីផ្សារគឺផលិតផលម៉ាក CISCO HyperFlex។ សេវាកម្មរបស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ដំណើរការក្នុងបរិយាកាសអត្ថិភាពកម្រិតខ្ពស់ ដោយប្រើប្រាស់បច្ចេកវិទ្យាជាចង្កោមនៅលើហាដវែរ ប្រព័ន្ធប្រតិបត្តិការ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងកម្មវិធីនានាជាច្រើនផ្សេងទៀត។

ដោយបានពិចារណាទៅលើការប្រើប្រាស់សេវាកម្មតាមប្រព័ន្ធអ៊ិនធើណិត ធនាគារបានធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់បណ្តាញអ៊ិនធើណិត អនុវត្តនូវ ISPs ជាច្រើន ដែលធ្វើឱ្យការតភ្ជាប់បណ្តាញរបស់ធនាគារគ្មានបញ្ហាកំហុសទាល់តែសោះ។

យើងតែងតែធ្វើការអភិវឌ្ឍឧបករណ៍គ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានរបស់យើងជាប់ជាប្រចាំ ដើម្បីដោះស្រាយបញ្ហាប្រឈមនៃកំណើនអាជីវកម្មយ៉ាងឆាប់រហ័ស ហើយជាលទ្ធផលយើងបង្កើតបានជាហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន នេះតែម្តង។

សេវាធនាគារឌីជីថល



សេវាធនាគារលក់រាយ ឌីជីថលបានដាក់ឱ្យ ប្រើប្រាស់នៅ ខែមេសា ឆ្នាំ២០១៩

ដើម្បីបម្រើជាច្រកចូលថ្មីបំផុតសម្រាប់តភ្ជាប់ជាមួយនឹងប្រព័ន្ធអេកូឌីជីថលដែលកំពុងរីកចម្រើន យើងបានដាក់ឱ្យប្រើប្រាស់នូវសេវាធនាគារលក់រាយឌីជីថលកាលពីខែមេសា ឆ្នាំ២០១៩ ដែលផ្តល់នូវច្រកចូលសេវាធនាគារមានសុវត្ថិភាព រហ័ស និងងាយស្រួល ដោយមានមុខងារងាយស្រួលប្រើប្រាស់អាចឱ្យអតិថិជនចូលប្រើប្រាស់ព័ត៌មានគណនីរបស់ខ្លួនបាននៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែងនៅទូទាំងពិភពលោក។

ម៉ាស៊ីន ATM របស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក បង្ហាញជូនអតិថិជននូវឧត្តមភាពប្រកួតប្រជែងខុសប្លែកពិសេសលើសគេ។ ម៉ាស៊ីននេះដំណើរការលើកម្មវិធីដែលជូនដំណឹងតាមសារ SMS ដើម្បីបើកដំណើរការកាត ATM របស់អ្នកប្រើប្រាស់ដោយមិនត្រូវការលេខកូដ PIN ដំបូងដែលត្រូវព្រីនចេញនៅលើក្រដាសឡើយ ដោយជំនួសឱ្យការផ្ញើទៅកាន់លេខទូរសព្ទរបស់អតិថិជនដើម្បីបើកដំណើរការកាត ATM សារនេះនឹងផ្ញើទៅកាន់ម៉ាស៊ីន ATM ភ្លាមៗវិញ។

ធនាគារបានកំណត់អាទិភាពក្នុងការណែនាំ និងពង្រឹងផលិតផលធនាគារឌីជីថលថាជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់។ សេវាធនាគារតាមទូរស័ព្ទសេវាធនាគារអនឡាញ ATM/CDM ម៉ាស្ទ័រកាត ប្រតិបត្តិការម៉ាស៊ីនឆូតកាត (POS) ដែលនឹងត្រូវណែនាំជូនគឺជាដំណាក់កាលចាប់ផ្តើមដំបូងនៃសេវាកម្មនីមួយៗ។ ធនាគារបន្តបង្កើតមុខងារបន្ថែមទៀតនិងពង្រឹងផលិតផលនីមួយៗផងដែរ។ យើងត្រូវតែនៅបន្តប្រកួតប្រជែង។ យើងនឹងផ្តល់ផលិតផលជាច្រើនបន្ថែមទៀត ដែលអាចផ្តល់ជូនអតិថិជន និងសាធារណជនផងដែរ។

ផលិតផលប័ណ្ណរបស់ធនាគារ



ធនាគារនឹងដាក់ដំណើរការម៉ាស្ទ័រកាតដែលមានទាំងប័ណ្ណឥណទាន និងឥណពន្ធ

ធនាគារ ប៊ី.អាយ.ស៊ី នឹងដាក់ឱ្យប្រើប្រាស់កាតរបស់ខ្លួនក្រោមគម្រោងម៉ាស្ទ័រកាត ដែលមានកាតឥណពន្ធ និងឥណទានផងដែរ៖ Classic, Gold និង Platinum។ កាតទាំងនេះបានរចនាឡើងយ៉ាងប្រណីតដើម្បីសម្របទៅតាមការវិវឌ្ឍនៃពិភពធនាគារដែលកំពុងមានការប្រែប្រួលយ៉ាងឆាប់រហ័សនេះ។ ការដាក់ចេញនូវផលិតផលកំពូលៗរបស់យើងនីមួយៗគឺមានគោលបំណងដើម្បីបង្កើតផលិតផលពោរពេញទៅដោយលក្ខណៈពិសេស ដែលផ្តល់ជូននូវអត្ថប្រយោជន៍ដ៏ល្អបំផុតសម្រាប់វិស័យធនាគារ ជូនដល់អតិថិជន។ កាតទាំងនេះនឹងផ្តល់ជូននូវបទពិសោធន៍ល្អឥតខ្ចោះ កម្រិតខ្ពស់ និងមានជាសុកភាព ព្រមទាំងមានលក្ខណៈពិសេសអាចប្រើប្រាស់បាននៅគ្រប់ទីកន្លែងទាំងអស់នៅពេលធ្វើដំណើរភាពប្រណីត និងការរស់នៅបែបជីវិតស៊ីវីលីយ។ កាតនេះផ្តល់ជូននូវបទពិសោធន៍និងភាពប្រណីតអស្ចារ្យមិនធ្លាប់មានសម្រាប់ការទិញទំនិញជារៀងរាល់ថ្ងៃ ក៏អាចប្រើប្រាស់សម្រាប់តម្រូវការទិញផ្សេងទៀត។ ដោយសារតែកាតទាំងនេះនឹងផ្តល់ជូននូវលទ្ធភាពក្នុងការទិញទំនិញនៅជុំវិញពិភពលោក អតិថិជនរបស់យើងនឹងរីករាយជាមួយនឹងសេវាកម្មកម្រិតពិភពលោកនិងទទួលបានការសន្សំសំចៃដ៏អស្ចារ្យសម្រាប់ជីវិតមិនថានៅទីណាក៏ដោយ។ ជាផលិតផលមានគុណតម្លៃបន្ថែម កាតនេះ ត្រូវបានភ្ជាប់ជាមួយនឹងកម្មវិធីដ៏ស្មោះត្រង់របស់ធនាគារ គឺ កម្មវិធី BIC Value ក្រោមកិច្ចសហការជាដៃគូជាមួយនឹងពាណិជ្ជករជាច្រើនក៏ដូចជាកម្មវិធីផ្តល់ជូន និងកម្មវិធីផ្តល់អត្ថប្រយោជន៍ជាច្រើនផ្សេងទៀតរបស់ម៉ាស្ទ័រកាត ដែលជាកម្មវិធីផ្តល់ជូនពិសេសអស្ចារ្យ។

ការពង្រីកបណ្តាញសាខា



ការខិតខំប្រឹងប្រែងរបស់ធនាគារ ប៊ី.អាយ.ស៊ី ក្នុងការបង្កើតបណ្តាញសាខាបន្ថែម គឺជាចំណុចដ៏សំខាន់ និង "ត្រូវតែធ្វើឱ្យបាន" សម្រាប់ធនាគារនេះ។

ទីតាំងសាខាធនាគារចំនួនពីរកន្លែងរួមមាន នៅក្នុងខេត្តព្រះសីហនុ និងខណ្ឌទួលគោក កំពុងដំណើរការ។

តាមរយៈកិច្ចខិតខំប្រឹងប្រែងបង្កើនសក្តានុពលដែលកំពុងមានកំណើននេះ សាខាធនាគារបច្ចុប្បន្ន និងអនាគត គឺត្រូវតែបង្កើតឡើងនៅក្នុងទីតាំងសំខាន់ៗឱ្យខានតែបាន ដូច្នេះការជ្រើសរើសទីតាំងសាខាធនាគារ គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់ធនាគារ។ ការជ្រើសរើសទីតាំងសាខាធនាគារល្អៗដែលជាតំបន់មានការអភិវឌ្ឍយ៉ាងឆាប់រហ័សនេះ គឺដើម្បីធានាថាអតិថិជនអាចងាយស្តាល់សាខាធនាគាររបស់យើង ការរកបានអតិថិជនដ៏អាចផ្តល់ប្រាក់ចំណេញច្រើន និងការបង្កើនលទ្ធភាពនៃការលក់សក្តានុពល ដោយសារតែសាខានានាបានប្តូរពីបណ្តាញប្រតិបត្តិការមកជាចំណុចទំនាក់ទំនងជាក់ស្តែង។

បច្ចុប្បន្ន ធនាគារមានទីតាំងចំនួនពីរដែលកំពុងដំណើរការ ដែលសាខាមួយស្ថិតក្នុងខេត្តព្រះសីហនុ និងសាខាមួយទៀតស្ថិតនៅក្នុងខណ្ឌទួលគោក ដែលសាខាទាំងពីរនេះនឹងដើរតួនាទីជាសាខាធំរបស់ធនាគារផងដែរ។ តាមរយៈការរៀបចំផែនការបង្កើតចំនួនសាខាធនាគារ បានធ្វើការពិចារណាដោយយកចិត្តទុកដាក់អំពីការពង្រីកសាខារបស់ខ្លួនទៅកាន់ទីតាំងដែលមានការរីកចម្រើនលឿន ឆាប់រហ័ស និងមានសក្តានុពលខ្ពស់បំផុត។ វត្តមានសាខានេះ នឹងដើរតួនាទីជាឧបករណ៍យថាភាព ដោយសារតែនៅពេលមានបញ្ហា អតិថិជនមានទំនោរទៅកាន់សាខាច្រើនជាងដើម្បីជួបពិភាក្សាជាមួយនឹងបុគ្គលិកធនាគារផ្ទាល់តែម្តង។ តាមរយៈការប្រកាន់ខ្ជាប់ទៅនឹងទស្សនវិស័យរបស់យើងដើម្បីបំពេញតម្រូវការសេវាធនាគារ និងហិរញ្ញវត្ថុរបស់អតិថិជន សាខាធនាគារនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងទំនាក់ទំនងរវាងអតិថិជន និងធនាគារ។

ការរៀបចំម៉ាកសញ្ញាថ្មី

ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក
B.I.C (CAMBODIA) BANK PLC.

ឥលូវនេះ

BIC Bank

បរិយាកាសអាជីវកម្មមានការវិវត្តជាប់ជាប្រចាំទៅតាមដែគូប្រកួតប្រជែងនៅលើទីផ្សារ និងការប្រែប្រួលនៃតម្រូវការរបស់អតិថិជន ដែលជំរុញឱ្យធនាគារត្រូវតែសម្របខ្លួនទៅតាមស្ថានភាពទាំងនោះដើម្បីនៅតែអាចផ្សារភ្ជាប់ជាមួយអតិថិជនជានិច្ច។

ពាក់ព័ន្ធនឹងផែនការប្រកបដោយមហិច្ឆតារបស់ធនាគារ ប៊ី.អាយ.ស៊ី ក្នុងការពង្រីកសាខារបស់ខ្លួននៅទូទាំងប្រទេស និងក្នុងតំបន់ធនាគារចាំបាច់ត្រូវតែបង្កើតអត្តសញ្ញាណឱ្យកាន់តែរឹងមាំសម្រាប់វិស័យធនាគារដែលមានភាពសម្បូរបែបនេះ។ តាមរយៈការលម្អ និងការរៀបចំម៉ាកសញ្ញាធនាគារថ្មី យើងនឹងអាចក្លាយទៅជាធនាគារមួយដែលឈានមុខគេ មិនត្រឹមតែនៅក្នុងប្រទេសកម្ពុជានោះទេ ថែមទាំងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ផងដែរ។


ចក្ខុវិស័យនៃការរៀបចំម៉ាកសញ្ញាថ្មីនេះគឺដើម្បីធ្វើទំនើបកម្មរូបសញ្ញាដើមរបស់យើងឱ្យមានលក្ខណៈជាម៉ាកសញ្ញាសកលមានភាពច្នៃប្រឌិតបន្ថែមទៀត ប៉ុន្តែនៅតែរក្សាទុកនូវសមាសធាតុដើមពីធនាគារ ប៊ី.អាយ.ស៊ី ឡាវដដែល។

គោលបំណងនៃការរៀបចំម៉ាកសញ្ញាឡើងវិញនេះ គឺដើម្បីកែប្រែរូបភាពក្រុមហ៊ុនឱ្យស្របទៅតាមគោលបំណងនៃភាពរីកចម្រើនការវិវត្តផ្នែកឌីជីថល និងការពង្រីកទីតាំងភូមិសាស្ត្រផងដែរ។

គោលបំណង គឺដើម្បីកែលម្អនិមិត្តរូបដែលមានស្រាប់នៅក្នុងរូបសញ្ញា ដោយសារតែរូបសញ្ញានោះគឺមានអត្ថន័យគ្រប់គ្រាន់រួចទៅហើយ។ រូបសញ្ញាធរមាត្រចិទជិត គឺតំណាងឱ្យភាពសាមគ្គីភាពពេញលេញ និងភាពយូរអង្វែង។ រូបសញ្ញានេះមានរាងដូចជាប្រាក់កាក់ចិននៅក្នុងក្បួនហុងស៊ុយ (Feng Shui) ដែលតំណាងឱ្យមាសប្រាក់ទ្រព្យសម្បត្តិ សំណាងល្អ និងសុវត្ថិភាព។ រូបសញ្ញានេះមានអត្ថន័យបង្កប់វិជ្ជមានសម្រាប់ធនាគារ ប៊ី.អាយ.ស៊ី ដែលគប្បីតែទទួលបានការលើកតម្កើង។ ស្រដៀងគ្នានេះដែរ សម្រាប់ពណ៌ គឺពណ៌ខៀវចាស់នេះ គឺតំណាងឱ្យបញ្ញា ភាពជឿជាក់ និងសុចរិតភាព ដូច្នេះពណ៌នេះគឺសំគ្តិសមបំផុតសម្រាប់ជាពណ៌របស់ក្រុមហ៊ុន។ ពណ៌ក្រហម តំណាងឱ្យថាមពល និងសេចក្តីប្រាថ្នាចង់បាន ដែលយើងខិតខំប្រឹងប្រែងប្រមូលផលនៅក្នុងធនាគាររបស់យើង។ ជារួម ដំណើរការរៀបចំម៉ាកសញ្ញាថ្មីនេះ នឹងមិនអាចទទួលបានជោគជ័យឡើងប្រសិនបើគ្មានឯកសារណែនាំអំពីស្តាកសញ្ញាផ្លូវការដែលជួយបង្ហាញផ្លូវដល់ក្រុមការងារផ្នែកលក់ និងទីផ្សារក្នុងការចនា និងរក្សាទំនាក់ទំនងជាមួយអតិថិជន។

ចំណុចនេះរួមបញ្ចូលទាំងការកំណត់ពណ៌ជាក់លាក់ និងប្រៃប្រូលម៉ូតអក្សរ និងការបកស្រាយរូបសញ្ញាដែលអាចប្រើប្រាស់។ នៅពេលមានចំណុចទាំងអស់នេះហើយ យើងអាចធានាបានថាការផ្សព្វផ្សាយរបស់យើងនឹងមានសង្គតិភាព និងបំពេញបន្ថែមទៅលើម៉ាកសញ្ញាថ្មីនេះ។

ជាចុងក្រោយ វៃបសាយត៍របស់ធនាគារ ប៊ី.អាយ.ស៊ី សេវាធនាគារតាមទូរសព្ទ និងសេវាធនាគារតាមអ៊ីនធឺណិត UI/UX ទាំងអស់ត្រូវតែផ្លាស់ប្តូរ ដើម្បីរក្សាភាពស្របគ្នាជាមួយនឹងរូបភាពក្រុមហ៊ុនថ្មី។ តាមរយៈការផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុឈានមុខគេ ធនាគារចង់ធានាថាសារទាំងអស់ឆ្លុះបញ្ចាំងអំពីភាពទំនើប និងការគិតឆ្ពោះទៅមុខដែលយើងនឹងឈានទៅដល់។



គម្រោងទំនួលខុសត្រូវសង្គម របស់ធនាគារ



យើងជឿជាក់ទៅលើពាក្យមួយថា "ការងារធនាគារចេញពីបេះដូង"។ ការតបស្នងទៅកាន់សហគមន៍ គឺជាទំនួលខុសត្រូវរបស់យើង ដែលនេះក៏ជាស្មារតីទទួលខុសត្រូវសង្គមរបស់ធនាគារ និងការប្តេជ្ញាចិត្តចំពោះចីរភាព និងសុខុមាលភាពសហគមន៍ផងដែរ។

ធនាគារបានរួមចំណែកក្នុង CSR សំខាន់ៗចំនួនពីរគឺសុខុមាលភាពសង្គម និងការការពារបរិស្ថាន។

១. ធនាគារ ប៊ី.អាយ.ស៊ី បានបរិច្ចាគទឹកប្រាក់ចំនួន

៥០.០០០ ដុល្លារ

សម្រាប់មហន្តរាយនៃការបាក់រលំអគារចំនួនប្រាំពីរជាន់ ដែលកើតឡើងក្នុងខេត្តព្រះសីហនុ។

២. ធនាគារ ប៊ី.អាយ.ស៊ី បានបរិច្ចាគទឹកប្រាក់ចំនួន

១០០.០០០ ដុល្លារ

ដើម្បីអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងខេត្តព្រៃវែង។



របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019
និងរបាយការណ៍របស់សវនករឯករាជ្យ



ព័ត៌មានអំពីធនាគារ

ធនាគារ	**ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក**	
ចុះបញ្ជីពាណិជ្ជកម្មលេខ	00029200	
ទីស្នាក់ការចុះបញ្ជី	អាសយដ្ឋាន 462 ផ្លូវលេខ 93 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា	
ភាគទុនិក	Asia Investment and Financial Services Sole Co., Ltd. Paradise Investment Co., Ltd. PrimeStreet Advisory Co., Ltd.	
ក្រុមប្រឹក្សាភិបាល	លោក យឹម លក្ខណ៍	ប្រធានក្រុមប្រឹក្សាភិបាល (តែងតាំងនៅថ្ងៃទី 28 ខែ សីហា ឆ្នាំ 2019)
	បណ្ឌិត Sathit Limpongpan	ប្រធានក្រុមប្រឹក្សាភិបាល (លាឈប់នៅថ្ងៃទី 5 ខែ មេសា ឆ្នាំ 2019)
	លោក Rewin Patailbunlue	អភិបាល (លាឈប់នៅថ្ងៃទី 30 ខែ មីនា ឆ្នាំ 2020)
	លោក Zulkiflee Kuan Shun Bin Abdullah	អភិបាល
	លោក Rutsaran Moonsan	អភិបាល
អ្នកគ្រប់គ្រង	លោក Zulkiflee Kuan Shun Bin Abdullah	នាយកប្រតិបត្តិ
	អ្នកស្រី Legarta Adel Leilanie Gaba	នាយកប្រតិបត្តិប្រតិបត្តិការ
	លោក យឹម ច័ន្ទដារ៉ា	ប្រធានគ្រប់គ្រងជាន់ខ្ពស់
	លោក បាន ម៉ារ៉ា	ប្រធានផ្នែកហិរញ្ញវត្ថុ
	លោក Thongsavath Pranyvong	ប្រធានផ្នែកប្រតិបត្តិការ
	លោក ឃុន វ៉ែត	ប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល
	លោក ហុង ប៊ុនថ្ល័យ	ប្រធានផ្នែកសវនកម្មផ្ទៃក្នុង
	លោក សេង វេសាលោ	ប្រធានផ្នែកបច្ចេកវិទ្យាព័ត៌មាន
សវនករ	ខេភីអឹមជី ខេមបូឌា ចំកាត់	

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីរីករាយ សូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ហៅកាត់ថា ("ធនាគារ") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ។

សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ធនាគារ រួមមានការធ្វើប្រតិបត្តិការលើរាល់សកម្មភាពអាជីវកម្មធនាគារ និងការផ្តល់សេវាកម្ម ហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

នៅក្នុងការិយបរិច្ឆេទនេះ ពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពចម្បងរបស់ធនាគារទេ ។

លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារមានដូចខាងក្រោម៖

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ប្រាក់ចំណេញ/(ខាត)មុនដកពន្ធ	1,465,845	(1,049,459)	5,939,604	(4,245,062)
(ចំណាយ)/ឥណទានពន្ធលើប្រាក់ចំណេញ	(326,638)	175,160	(1,323,537)	708,522
ប្រាក់ចំណេញ/(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទ	**1,139,207**	**(874,299)**	**4,616,067**	**(3,536,540)**

ភាគលាភ

ពុំមានការប្រកាសឬការបែងចែកភាគលាភ ហើយក្រុមប្រឹក្សាភិបាលក៏មិនណែនាំអោយមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

ដើមទុន

ដើមទុនរបស់ធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 មានចំនួន 75,000,000 ដុល្លារអាមេរិក (2018: 75,000,000 ដុល្លារអាមេរិក)។

ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

ឥណទាន និងបុរេប្រទាន

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង អ្នកគ្រប់គ្រងបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទាន និងបុរេប្រទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង។ អ្នកគ្រប់គ្រងជឿជាក់ថា រាល់ឥណទានដែលទទួលស្គាល់ថា មិនអាចទារបានត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើង លើការបាត់បង់ឥណទាន និងបុរេប្រទាន ។

នាថ្ងៃចេញរបាយការណ៍នេះ អ្នកគ្រប់គ្រងពុំបានពិនិត្យឃើញមានស្ថានភាពណាមួយ ដែលអាចនឹងបណ្តាលឲ្យ ចំនួននៃការលុបបំបាត់ចោលឥណទាន និងបុរេប្រទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើការបាត់បង់ឥណទាន និងបុរេប្រទានក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានចំនួនខ្វះខាតជាសារវន្តនោះឡើយ ។

ទ្រព្យសកម្មចរន្ត

នៅមុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ចាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ក្រៅពីបំណុល ដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ហើយតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ នឹងត្រូវបន្ថយនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ អ្នកគ្រប់គ្រងពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់ តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ថាមានភាពមិនត្រឹមត្រូវនោះទេ ។

វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ អ្នកគ្រប់គ្រងពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ហើយអាចនឹងធ្វើអោយប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថា មានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ ។

បំណុលយថាភាព និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំនូវទ្រព្យសកម្មណាមួយរបស់ធនាគារ ត្រូវបានធ្វើឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទក្នុងការធានា ចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះធនាគារចាប់តាំងពីចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារឡើយ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេល 12 ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ដែលនឹង ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់នោះទេ ។

ការប្រៀបធៀបសភាពការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចនឹងបណ្តាលអោយមានតួលេខនៃចំនួនណាមួយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវនោះទេ ។

ប្រតិបត្តិការមិនប្រក្រតី

តាមមតិក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ធនាគារ ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិន មានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈមិនប្រក្រតី នោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងអំឡុងពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

ព្រឹត្តិការណ៍ចាប់តាំងពីកាលបរិច្ឆេទរាយការណ៍

នៅថ្ងៃចេញរបាយការណ៍នេះ លើកលែងមានការបញ្ជាក់បន្ថែមនៅកំណត់សម្គាល់ 34 នៃរបាយការណ៍ហិរញ្ញវត្ថុ មិនមានព្រឹត្តិការណ៍ជាសារវន្ត ណាមួយកើតឡើងបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ តម្រូវឲ្យមាននិយ័តភាព ឬការលាតត្រដាងណាមួយនៅក្នុងរបាយហិរញ្ញវត្ថុឡើយ ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបានបម្រើការក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះរួមមាន៖

លោក យឹម លក្ខណ៍	ប្រធានក្រុមប្រឹក្សាភិបាល (តែងតាំងនៅថ្ងៃទី 28 ខែ សីហា ឆ្នាំ 2019)
បណ្ឌិត Sathit Limpongpan	ប្រធានក្រុមប្រឹក្សាភិបាល (លាឈប់នៅថ្ងៃទី 5 ខែ មេសា ឆ្នាំ 2019)
លោក Rewin Patailbunlue	អភិបាល (លាឈប់នៅថ្ងៃទី 30 ខែ មីនា ឆ្នាំ 2020)
លោក Zulkiflee Kuan Shun Bin Abdullah	អភិបាល
លោក Rutsaran Moonsan	អភិបាល

ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់កាន់កាប់ ឬមានការទាក់ទិននៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬដោយប្រយោល នៅក្នុងការិយបរិច្ឆេទ ហិរញ្ញវត្ថុនេះទេ ។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀង ណាមួយដែលធនាគារជាភាគី ម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់អោយទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ធនាគារ ឬសាជីវកម្មដទៃ ។

នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍នេះ ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់របស់ធនាគារបានទទួល ឬ មានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុប ទទួលបាន ឬដល់កំណត់ទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចបាន បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារ ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងធនាគារ ដែលក្រុមប្រឹក្សា ភិបាលនោះជាសមាជិក ឬក៏ជាមួយធនាគារ ដែលអ្នកគ្រប់គ្រងនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារៈទទួលខុសត្រូវក្នុងការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជា សារវន្តទាំងអស់ ដើម្បីចង្អុលបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរ ទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទ ដែលបាន បញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណ យ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

(ខ) អនុវត្តទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញអោយមាន ភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានបង្ហាញ ពន្យល់ និង កំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុ

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ឲ្យមានប្រសិទ្ធភាព

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ឈប់ផ្នែកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(ង) ត្រួតពិនិត្យ និងដឹកនាំធនាគារឲ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំបាយការណ៍ហិរញ្ញវត្ថុ។

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់មកជាមួយដូចដែលបានបង្ហាញនៅទំព័រទី 10 ដល់ទី 120 ថាបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំង លទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដា របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

ចុះហត្ថលេខាដោយយោងលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល:

ក្រុមហ៊ុន
ប៊ី.អាយ.ស៊ី (ខេមបូឌា) ឡឹមធីត
B.I.C (CAMBODIA) BANK PLC.
KINGDOM OF CAMBODIA

លោក Zulkiflee Kuan Shun Bin Abdullah
អភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី 15 MAY 2020

របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិករបស់
ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក

មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ហៅកាត់ថា ("ធនាគារ") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី 10 ដល់ទី 120 (ដែលហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាព ហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ។

មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី *ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំ មានភាពឯករាជ្យពីធនាគារដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

បញ្ហាផ្សេងៗ

ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់ 33 នៃរបាយការណ៍ហិរញ្ញវត្ថុ ធនាគារបានអនុវត្ត ស.រ.ទ.ហ.អ.ក នៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 ដែលមានកាលបរិច្ឆេទអន្តរកាលនៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។ ស្តង់ដារទាំងនេះ គឺត្រូវបានអនុវត្តតាមវិធីសាស្ត្រប្រតិសកម្មលើព័ត៌មានប្រៀបធៀបនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងកំណត់សម្គាល់ពាក់ព័ន្ធផ្សេងៗ។ យើងខ្ញុំ មិនតម្រូវឲ្យធ្វើសវនកម្មលើព័ត៌មានប្រៀបធៀបដែលបានកែប្រែឡើងវិញឡើយ ហើយព័ត៌មានទាំងនេះ មិនបានត្រូវធ្វើសវនកម្មទេ។ ការទទួលខុសត្រូវរបស់យើងខ្ញុំលើព័ត៌មានប្រៀបធៀបទាំងនេះ គឺត្រូវកំណត់ថាតើរបាយការណ៍ហិរញ្ញវត្ថុ បានរួមបញ្ចូលនូវព័ត៌មានប្រៀបធៀបដែលតម្រូវដោយ ស.រ.ទ.ហ.អ.ក និងថាតើពត៌មានប្រៀបធៀបទាំងនេះត្រូវបានធ្វើចំណាត់ថ្នាក់សមស្រប ឬទេ។

ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី 1 ដល់ទី 5 និងរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារ ដែលរំពឹងថានឹងរួចរាល់ បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុងឆ្គងជាសារវន្ត ។ ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង ។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ ។

ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយ អនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ ធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ឈប់ដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ធនាគារ។

ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើង ដោយសារ ការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គង តែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈភាតុនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជា មូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុស ជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនាការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។

- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារឡើយ។

- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលធនាគារបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។

- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃ ការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រងហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់សារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឲ្យធនាគារបញ្ឈប់និរន្តរភាពនៃអាជីវកម្ម ។

- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំង ចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

តំណាងក្រុមហ៊ុន **ខេគីអឹមជ្ជី ខេមបូឌា ចំកាត់**

Lim Chew Teng
Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី 15 ខែ ឧសភា ឆ្នាំ 2020

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	កំណត់សម្គាល់	នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ដុល្លារអាមេរិក	នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ដុល្លារអាមេរិក	នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ពាន់រៀល (កំណត់សម្គាល់ 5)	នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ពាន់រៀល (កំណត់សម្គាល់ 5)
ទ្រព្យសកម្ម					
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	6	61,254,513	22,200,650	249,612,140	89,202,212
ប្រាក់បញ្ញើនៅធនាគារនានា	7	18,058,081	-	73,586,680	-
ប្រាក់តម្កល់តាមច្បាប់	8	23,771,135	9,901,244	96,867,375	39,783,198
ឥណទាន និងបុរេប្រទានផ្តល់ដល់ អតិថិជន - សុទ្ធ	9	67,711,026	36,072,557	275,922,431	144,939,534
ការវិនិយោគផ្សេងៗ	10	22,392,269	22,443,254	91,248,496	90,176,995
ទ្រព្យសកម្មអរូបី	11	856,157	119,352	3,488,840	479,556
ទ្រព្យ និងបរិក្ខារ	12	1,230,441	612,119	5,014,047	2,459,494
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	13	1,748,854	341,686	7,126,580	1,372,894
ទ្រព្យសកម្មផ្សេងៗ	14	813,899	697,385	3,316,638	2,802,093
ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ	19	76,439	175,160	311,489	703,793
ទ្រព្យសកម្មសរុប		**197,912,814**	**92,563,407**	**806,494,716**	**371,919,769**
បំណុល និងមូលធន					
បំណុល					
ប្រាក់បញ្ញើរបស់អតិថិជន	15	119,914,870	16,749,654	488,653,095	67,300,110
ប្រាក់បញ្ញើរបស់ធនាគារនានា	16	321,843	1,224,100	1,311,510	4,918,434
បំណុលភតិសន្យា	17	1,721,470	348,277	7,014,990	1,399,377
បំណុលផ្សេងៗ	18	513,885	112,017	2,094,081	450,083
បំណុលពន្ធអប្បបរមា		-	3,658	-	14,698
បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ	19	175,838	-	716,540	-
សរុបបំណុល		122,647,906	18,437,706	499,790,216	74,082,702
មូលធន					
ដើមទុន	20	75,000,000	75,000,000	300,000,000	300,000,000
ទុនបម្រុងតាមបទប្បញ្ញត្តិ		1,410,468	420,139	5,723,710	1,688,119
ប្រាក់ខាតបង្គរ		(1,145,560)	(1,294,438)	(4,644,183)	(5,224,659)
ទុនបម្រុងលើការប្តូររូបិយប័ណ្ណ		-	-	5,624,973	1,373,607
សរុបមូលធន		75,264,908	74,125,701	306,704,500	297,837,067
សរុបបំណុល និងមូលធន		**197,912,814**	**92,563,407**	**806,494,716**	**371,919,769**

កំណត់សម្គាល់ ដែលភ្ជាប់ជូន គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

		2019	2018	2019	2018
		ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
	កំណត់សម្គាល់				
ចំណូលពីប្រតិបត្តិការ					
ចំណូលពីការប្រាក់	21	5,239,468	558,409	21,230,324	2,258,764
ចំណាយលើការប្រាក់	22	(819,985)	(24,424)	(3,322,579)	(98,795)
ចំណូលពីការប្រាក់សុទ្ធ		4,419,483	533,985	17,907,745	2,159,969
ចំណូលកម្រៃ និងជើងសារសុទ្ធ	23	267,844	2,782	1,085,304	11,253
ចំណូលផ្សេងៗ	24	40,876	836	165,630	3,382
ចំណូលពីប្រតិបត្តិការសរុប		4,728,203	537,603	19,158,679	2,174,604
ចំណាយលើបុគ្គលិក	25	(793,155)	(282,835)	(3,213,864)	(1,144,068)
រំលស់	26	(656,886)	(137,111)	(2,661,702)	(554,614)
ចំណាយលើប្រតិបត្តិការផ្សេងៗ	27	(1,727,881)	(989,052)	(7,001,374)	(4,000,715)
ការខាតបង់លើឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ	9	(84,436)	(172,534)	(342,135)	(697,900)
ចំណាយពន្ធអប្បបរមា	19	-	(5,530)	-	(22,369)
ចំណាយលើប្រតិបត្តិការសរុប		(3,262,358)	(1,587,062)	(13,219,075)	(6,419,666)
ប្រាក់ចំណេញ/(ខាត)មុនដកពន្ធ		1,465,845	(1,049,459)	5,939,604	(4,245,062)
(ចំណាយ)/ឥណទានពន្ធលើប្រាក់ចំណេញ	19	(326,638)	175,160	(1,323,537)	708,522
ប្រាក់ចំណេញ/(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទ		**1,139,207**	**(874,299)**	**4,616,067**	**(3,536,540)**
លទ្ធផលលម្អិតផ្សេងៗ					
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	-	4,251,366	1,373,607
លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ		**1,139,207**	**(874,299)**	**8,867,433**	**(2,162,933)**

កំណត់សម្គាល់ ដែលភ្ជាប់ជូន គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

ដើមទុន		ទុនបម្រុងតាមបទប្បញ្ញត្តិ		ប្រាក់ខាតបង្គរ		ទុនបម្រុងលើការប្តូរប្រូបិយប័ណ្ណ		សរុប	
ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់5)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់5)

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

នាថ្ងៃទី1 ខែមករា ឆ្នាំ 2019	75,000,000	300,000,000	420,139	1,688,119	(1,294,438)	(5,224,659)	-	1,373,607	74,125,701	297,837,067
ការផ្ទេរ	-	-	990,329	4,035,591	(990,329)	(4,035,591)	-	-	-	-
ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	1,139,207	4,616,067	-	-	1,139,207	4,616,067
លម្អៀងពីការប្តូរប្រូបិយប័ណ្ណ	-	-	-	-	-	-	-	4,251,366	-	4,251,366
នាថ្ងៃទី31 ខែ ធ្នូ ឆ្នាំ 2019	**75,000,000**	**300,000,000**	**1,410,468**	**5,723,710**	**(1,145,560)**	**(4,644,183)**	**-**	**5,624,973**	**75,264,908**	**306,704,500**

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

នាថ្ងៃទី1 ខែមករា ឆ្នាំ 2018	-	-	-	-	-	-	-	-	-	-
ដើមទុនដែលបានបែងចែក	75,000,000	300,000,000	-	-	-	-	-	-	75,000,000	300,000,000
ការផ្ទេរ	-	-	420,139	1,688,119	(420,139)	(1,688,119)	-	-	-	-
ប្រាក់ខាតសម្រាប់ការិយបរិច្ឆេទ	-	-	-	-	(874,299)	(3,536,540)	-	-	(874,299)	(3,536,540)
លម្អៀងពីការប្តូរប្រូបិយប័ណ្ណ	-	-	-	-	-	-	-	1,373,607	-	1,373,607
នាថ្ងៃទី31 ខែ ធ្នូ ឆ្នាំ 2018	**75,000,000**	**300,000,000**	**420,139**	**1,688,119**	**(1,294,438)**	**(5,224,659)**	**-**	**1,373,607**	**74,125,701**	**297,837,067**

កំណត់សម្គាល់ ដែលភ្ជាប់ជូន គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

របាយការណ៍លំហូរទឹកប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ				
ចំណេញ/(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទ	1,139,207	(874,299)	4,616,067	(3,536,540)
និយ័តភាពលើ៖				
រំលស់	656,886	137,111	2,661,702	554,614
ចំណូលពីការប្រាក់សុទ្ធ	(4,419,483)	(533,985)	(17,907,745)	(2,159,969)
ការខាតបង់លើឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុសុទ្ធ	84,436	172,534	342,135	697,900
ចំណាយ/(ឥណទាន)ពន្ធលើប្រាក់ចំណេញ	326,638	(175,160)	1,323,537	(708,522)
ចំណាយពន្ធអប្បបរមា	-	5,530	-	22,369
ការលុបចោលទ្រព្យ និងបរិក្ខារ	952	-	3,858	-
	(2,211,364)	(1,268,269)	(8,960,446)	(5,130,148)
បរិម្រៃបម្រួល៖				
ប្រាក់បញ្ញើនៅធនាគារនានា	(18,058,081)	-	(73,171,344)	-
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	(31,624,137)	(36,050,057)	(128,141,003)	(145,822,481)
ប្រាក់តម្កល់តាមច្បាប់	(13,869,891)	(9,901,244)	(56,200,798)	(40,050,532)
ទ្រព្យសកម្មផ្សេងៗ	(116,514)	(697,385)	(472,115)	(2,820,922)
ប្រាក់បញ្ញើរបស់អតិថិជន	102,750,408	16,779,260	416,344,654	67,872,107
ប្រាក់បញ្ញើរបស់ធនាគារនានា	(902,257)	1,224,100	(3,655,945)	4,951,485
ការវិនិយោគផ្សេងៗ	50,467	(22,578,250)	204,492	(91,329,021)
បំណុលផ្សេងៗ	401,868	112,017	1,628,369	453,109
សាច់ប្រាក់ទទួលបានពី/(ប្រើប្រាស់ក្នុង) ប្រតិបត្តិការ	36,420,499	(52,379,828)	147,575,864	(211,876,403)

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ការប្រាក់ដែលបានទទួល	5,201,395	500,067	21,076,053	2,022,771
ការប្រាក់បានបង់	(356,969)	(38,932)	(1,446,439)	(157,480)
ពន្ធលើប្រាក់ចំណេញបានបង់	(52,079)	-	(211,024)	-
ពន្ធអប្បបរមាបានបង់	(3,658)	(1,872)	(14,822)	(7,572)
សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់ក្នុង) សកម្មភាពប្រតិបត្តិការ	41,209,188	(51,920,565)	166,979,632	(210,018,684)
លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ				
ការទិញទ្រព្យ និងបរិក្ខារ និងទ្រព្យសកម្មអរូបី	(1,882,030)	(810,423)	(7,625,986)	(3,278,161)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ	(1,882,030)	(810,423)	(7,625,986)	(3,278,161)
លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន				
សាច់ប្រាក់ទទួលបានពីការបង្កើតដើមទុន	-	75,000,000	-	303,375,000
ការទូទាត់បំណុលកតិសន្យា	(213,118)	(66,666)	(868,456)	(267,864)
សាច់ប្រាក់សុទ្ធ (ប្រើប្រាស់ក្នុង)/ ទទួលបានពីសកម្មភាពហិរញ្ញប្បទាន	(213,118)	74,933,334	(868,456)	303,107,136
ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និង សាច់ប្រាក់សមមូល	39,114,040	22,202,346	158,485,190	89,810,291
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ	22,202,346	-	89,209,026	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	2,170,057	(601,265)
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ (កំណត់សម្គាល់ 6)	**61,316,386**	**22,202,346**	**249,864,273**	**89,209,026**

កំណត់សម្គាល់ ដែលភ្ជាប់ជូន គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

1. ព័ត៌មានធនាគារ

ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក ហៅកាត់ថា ("ធនាគារ") ត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី 14 ខែ វិច្ឆិកា ឆ្នាំ 2017 ក្រោមលេខចុះបញ្ជី 00029200 ហើយបានចាប់ផ្តើមប្រតិបត្តិការបន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី 18 ខែ កក្កដា ឆ្នាំ 2018 ។

សកម្មភាពចម្បងៗរបស់ធនាគាររួមមានប្រតិបត្តិការអាជីវកម្មធនាគារជាមូលដ្ឋាន និងការផ្តល់សេវាហិរញ្ញវត្ថុពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យដែលបានចុះបញ្ជីរបស់ធនាគារបច្ចុប្បន្នមានទីតាំងនៅផ្ទះលេខ 462 ផ្លូវ 93 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ធនាគារ មាននិយោជិតចំនួន 50 នាក់ នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 (2018 :និយោជិតចំនួន 24 នាក់)។

2. មូលដ្ឋាននៃគណនេយ្យ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហៅកាត់ថា ("ស.រ.ទ.ហ.អ.ក") ឬ ("CIFRSs") ។ នេះគឺជារបាយការណ៍ ហិរញ្ញវត្ថុលើកដំបូងរបស់ធនាគារដែលត្រូវបានរៀបចំឡើងដោយអនុលោមទៅតាម ស.រ.ទ.ហ.អ.ក និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ឬ ("CIFRS") 1 "ការអនុវត្តដំបូងនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា" ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុកាលពីការិយបរិច្ឆេទមុន របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការពន្យល់ពីរបៀបនៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក ដែលបានប៉ះពាល់ដល់ការរាយការណ៍ពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 33 ។

គោលនយោបាយគណនេយ្យ និងវិធីសាស្ត្រនៃការគណនា ត្រូវបានអនុវត្តប្រកបដោយសង្គតិភាពនៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ។

ព័ត៌មានលម្អិតទាក់ទងនឹងគោលនយោបាយគណនេយ្យសំខាន់ៗរបស់ធនាគារ ត្រូវបានលាតត្រដាងក្នុងកំណត់សម្គាល់ 32 ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងអនុញ្ញាតឲ្យចេញផ្សាយនៅថ្ងៃទី 15 ខែ ឧសភា ឆ្នាំ 2020 ។

3. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ

ធនាគារធ្វើប្រតិបត្តិការ និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក។ អ្នកគ្រប់គ្រងក៏បានកំណត់ថា ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងជារូបិយបណ្ណ័សម្រាប់ធ្វើការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ធនាគារ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ធនាគារ ។ តួលេខទាំងអស់ត្រូវបានបង្គត់ចំនួនមួយដុល្លារអាមេរិក ឬមួយពាន់រៀលដែលជិតបំផុត បើមិនដូច្នេះទេលុះត្រាតែមានការបង្ហាញផ្សេងពីនោះ។

4. ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែលើការប៉ាន់ស្មាន ត្រូវបានទទួលស្គាល់តាមវិធីសាស្ត្រទស្សន:វិស័យ។

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានផលប៉ះពាល់ជាសារវន្ត លើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ដូចខាងក្រោម ។

- កំណត់សម្គាល់ 32គ(ii)៖ ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃគំរូអាជីវកម្មដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ (" SPPI") លើចំនួនប្រាក់ដើមដែលនៅសល់។
- កំណត់សម្គាល់ 32គ(vii)៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូង ដោយកំណត់វិធីសាស្ត្រសម្រាប់បញ្ចូលព័ត៌មានទៅក្នុងការវាស់វែងនៃ ឥណទានដែលរំពឹងថានឹងបាត់បង់ ("ECL") និងការជ្រើសរើស និងការអនុម័តលើគំរូដែលប្រើដើម្បីវាស់ ECL។

ព័ត៌មានអំពីភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន ដែលមានហានិភ័យជាសារវន្ត ដែលអាចធ្វើឲ្យមាននិយ័តភាពលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនាពេលបន្ទាប់ ត្រូវបានបញ្ចូលក្នុងកំណត់សម្គាល់ ដូចខាងក្រោម៖

- កំណត់សម្គាល់ 32គ(vi) ៖ ការកំណត់លើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុដែលមិនមានទិន្នន័យដែលអាចអង្កេតបាន។
- កំណត់សម្គាល់ 32គ(vii) ៖ ឱនភាពនៃឧបករណ៍ហិរញ្ញវត្ថុ៖ ការសន្មតសំខាន់ៗ ដែលប្រើក្នុងការប៉ាន់ស្មាន លំហូរទឹកប្រាក់ដែលអាចប្រមូលមកវិញបាន ។
- កំណត់សម្គាល់ 32គ(vii) ៖ ឱនភាពនៃឧបករណ៍ហិរញ្ញវត្ថុ៖ កំណត់ការបញ្ចូលសមាសធាតុទៅក្នុងគំរូនៃការវាស់វែង លើការរំពឹងទុកលើការខាតបង់ឥណទាន រួមទាំងការបញ្ចូលព័ត៌មាននៃការប្រមើលនាពេលអនាគត ។

5. ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រា នាកាលបរិច្ឆេទរាយការណ៍ ។ គណនេយ្យមូលធនត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្ត្រ។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរទឹកប្រាក់ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "ទុនបម្រុងលើការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ ។

ធនាគារប្រើប្រាស់អត្រាប្តូររូបិយប័ណ្ណដូចខាងក្រោម៖

			អត្រានាកាលបរិច្ឆេទ	
			រាយការណ៍	**អត្រាមធ្យម**
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	1 ដុល្លារអាមេរិក	=	4,075 រៀល	4,052 រៀល
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	1 ដុល្លារអាមេរិក	=	4,018 រៀល	4,045 រៀល
ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018	1 ដុល្លារអាមេរិក	=	4,037 រៀល	មិនប្រើ

តួលេខជាប្រាក់រៀលនេះ គឺសម្រាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយថាតួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ ។

6. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
សាច់ប្រាក់ក្នុងដៃ	4,155,506	4,518,232	16,933,687	18,154,256
សាច់ប្រាក់សមមូលជាមួយធនាគារនានា	57,160,880	17,684,114	232,930,586	71,054,770
	61,316,386	22,202,346	249,864,273	89,209,026
ដក: ការខាតបង់លើសំវិធានធនលើឱនភាពនៃតម្លៃ	(61,873)	(1,696)	(252,133)	(6,814)
	61,254,513	**22,200,650**	**249,612,140**	**89,202,212**

បម្រែបម្រួលនៃការខាតបង់សំវិធានធនលើឱនភាពនៃតម្លៃមានដូចខាងក្រោម៖

	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
នាថ្ងៃទី1 ខែ មករា	1,696	-	6,814	-
ការទិញបន្ថែម	60,177	1,696	243,837	6,860
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	1,482	(46)
នាថ្ងៃទី31 ខែ ធ្នូ	**61,873**	**1,696**	**252,133**	**6,814**

7. ប្រាក់បញ្ញើនៅធនាគារនានា

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ប្រាក់បញ្ញើមានកាលកំណត់ (មិនមែនជាសាច់ប្រាក់សមមូល)	18,058,081	-	73,586,680	-

ប្រាក់បញ្ញើនៅធនាគារនានា មានកាលកំណត់ចាប់ពី 3 ខែដល់ 6 ខែ ហើយទទួលបានការប្រាក់ចន្លោះពី 2% ទៅ 4% ក្នុងមួយឆ្នាំ ។

8. ប្រាក់តម្កល់តាមច្បាប់

		ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
		ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
		ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ប្រាក់តម្កល់ធានាលើដើមទុន	ក	7,500,000	7,500,000	30,562,500	30,135,000
ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើរបស់អតិថិជន	ខ	16,271,135	2,401,244	66,304,875	9,648,198
		23,771,135	9,901,244	96,867,375	39,783,198

ក. ប្រាក់តម្កល់ធានាលើដើមទុន

យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-01-136 ចុះថ្ងៃទី 15 ខែ តុលា ឆ្នាំ 2001 ធនាគារ តម្រូវឲ្យរក្សាប្រាក់តម្កល់តាមច្បាប់ចំនួន 10% នៃដើមទុនរបស់ខ្លួន ។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួនបានឡើយ ប៉ុន្តែធនាគារអាចដកវិញបាននៅពេលដែលធនាគារសម្រេចចិត្តឈប់ធ្វើអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្ម័គ្រចិត្ត ។ ប្រាក់តម្កល់ធានាដើមទុនទទួលបានអត្រាការប្រាក់ 0% - 0.48% (2018: 0% - 0.73%).

ខ. ប្រាក់បម្រុងកាតព្វកិច្ច

ប្រាក់បម្រុងកាតព្វកិច្ចគឺជាទុនបម្រុងអប្បបរមាដែលត្រូវបានគណនាតាមអត្រា 8% ចំពោះប្រាក់រៀល និង 12.50% ចំពោះរូបិយប័ណ្ណផ្សេងៗនៃប្រាក់បញ្ញើរបស់អតិថិជន ប្រាក់បញ្ញើរបស់ធនាគារអនិវាសនជន និងប្រាក់បញ្ញើគ្រឹះស្ថានហិរញ្ញវត្ថុ និង ប្រាក់កម្ចីអនិវាសនជន ។ យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-018-282 ប្រ.ក. ស្តីពីការរក្សា ទុនបម្រុងកាតព្វកិច្ចចុះថ្ងៃទី 29 ខែ សីហា ឆ្នាំ 2018 សម្រាប់ប្រាក់បញ្ញើនិងការខ្ចីរបស់ធនាគារពាណិជ្ជ ប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀល និងរូបិយប័ណ្ណផ្សេងមិនទូលបាន ការប្រាក់ទេ។

9. ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - សុទ្ធ

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ឥណទានពាណិជ្ជកម្ម				
ឥណទានវិបារូបន៍	8,220,144	7,021,662	33,497,087	28,213,038
ឥណទានរយៈពេលខ្លី	-	-	-	-
ឥណទានរយៈពេលវែង	7,056,409	7,022,167	28,754,867	28,215,067
ឥណទានអ្នកប្រើប្រាស់				
ឥណទានវិបារូបន៍	12,879,818	8,055,237	52,363,008	32,365,942
ឥណទានរយៈពេលខ្លី	9,544,131	-	39,014,584	-

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	៣ន់រៀល (កំណត់សម្គាល់ 5)	៣ន់រៀល (កំណត់សម្គាល់ 5)
តំណាងរយៈពេលវែង	14,637,690	14,009,333	59,648,587	56,289,500
តំណាងសម្ព័ន្ធញាតិ	15,432,417	-	62,887,099	-
	67,770,609	36,108,399	276,165,232	145,083,547
ដក: ការខាតបង់លើសំវិធានធនលើឱនភាពនៃតម្លៃ	(59,583)	(35,842)	(242,801)	(144,013)
	67,711,026	**36,072,557**	**275,922,431**	**144,939,534**

ក. ការខាតបង់លើសំវិធានធនលើឱនភាពនៃតម្លៃ

(i) ការខាតបង់លើសំវិធានធនលើឱនភាពនៃតម្លៃដែលបានទទួលស្គាល់ក្នុងចំណេញ ឬខាតត្រូវបានសង្ខេបមានដូចខាងក្រោម៖

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	៣ន់រៀល (កំណត់សម្គាល់ 5)	៣ន់រៀល (កំណត់សម្គាល់ 5)
ការខាតបង់លើឱនភាពនៃតម្លៃសុទ្ធនៃតំណាង	23,741	35,842	96,199	144,981
ការខាតបង់លើឱនភាពនៃតម្លៃសុទ្ធនៃសមតុល្យធនាគារផ្សេងៗ	60,177	1,696	243,837	6,860
ការខាតបង់លើឱនភាពនៃតម្លៃសុទ្ធនៃការវិនិយោគផ្សេងៗ	518	134,996	2,099	546,059
	84,436	**172,534**	**342,135**	**697,900**

(ii) បម្រែបម្រួលនៃសំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃតំណាង និងបុរេប្រទាន មានដូចខាងក្រោម៖

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	៣ន់រៀល (កំណត់សម្គាល់ 5)	៣ន់រៀល (កំណត់សម្គាល់ 5)
នាថ្ងៃទី 1 ខែ មករា	35,842	-	144,013	-
សំវិធានធនសម្រាប់ការិយបរិច្ឆេទ	23,741	35,842	96,199	144,981
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	2,589	(968)
នាថ្ងៃទី 31 ខែ ធ្នូ	**59,583**	**35,842**	**242,801**	**144,013**

ខ. ការវិភាគបំណុលតាមកាលវិសាន្ត

តណាទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល ដែលមានកាលកំណត់ដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
រយៈពេល 1 ខែ	7,000,000	-	28,525,000	-
> 1 ទៅ 3 ខែ	1,009,806	-	4,114,959	-
> 3 ទៅ 6 ខែ	3,088,733	-	12,586,587	-
> 6 ទៅ 12 ខែ	34,977,971	15,076,899	142,535,232	60,578,980
> 1 ទៅ 3 ឆ្នាំ	31,303	-	127,560	-
> 3 ទៅ 5 ឆ្នាំ	21,163,591	21,031,500	86,241,634	84,504,567
លើសពី 5 ឆ្នាំ	499,205	-	2,034,260	-
	67,770,609	**36,108,399**	**276,165,232**	**145,083,547**

សម្រាប់ការវិភាគបន្ថែមលើ តណាទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល សូមមើលកំណត់សម្គាល់លេខ 30ខ ។

10. ការវិនិយោគផ្សេងៗ

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ការវិនិយោគផ្សេងៗ តាមរំលស់ ថ្លៃដើម	22,527,783	22,578,250	91,800,716	90,719,409
ដក: ការខាតបង់លើសំវិធានធន លើឱនភាពនៃតម្លៃ	(135,514)	(134,996)	(552,220)	(542,414)
	22,392,269	**22,443,254**	**91,248,496**	**90,176,995**

ការវិនិយោគនេះគឺតំណាងឲ្យប្រាក់តម្កល់ក្នុងការទិញមាសនៅក្រុមហ៊ុន Asia Investment and Financial Services Sole Co., Ltd. ដែលជាភាគទុនិករបស់ធនាគារ ។ Asia Investment and Financial Services Sole Co., Ltd យល់ព្រមឲ្យការប្រាក់ចំនួន 6% ក្នុង 1 ឆ្នាំ ។

បម្រែបម្រួលនៃឱនភាពខាតមានដូចខាងក្រោម៖

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
នាថ្ងៃទី 1 ខែ មករា	134,996	-	542,414	-
ការបន្ថែម	518	134,996	2,099	546,059
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	7,707	(3,645)
នាថ្ងៃទី 31 ខែ ធ្នូ	**135,514**	**134,996**	**552,220**	**542,414**

11. ទ្រព្យសកម្មអរូបី

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
សូហ្វវែរ				
ថ្លៃដើម				
នាថ្ងៃទី 1 ខែ មករា	138,577	-	556,802	-
ការទិញបន្ថែម	1,046,578	138,577	4,240,734	560,544
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	31,971	(3,742)
នាថ្ងៃទី 31 ខែ ធ្នូ	1,185,155	138,577	4,829,507	556,802
ដក: រំលស់បង្គរ				
នាថ្ងៃទី 1 ខែ មករា	19,225	-	77,246	-
រំលស់សម្រាប់ការិយបរិច្ឆេទ	309,773	19,225	1,255,200	77,765
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	8,221	(519)
នាថ្ងៃទី 31 ខែ ធ្នូ	328,998	19,225	1,340,667	77,246
តម្លៃយោង				
នាថ្ងៃទី 31 ខែ ធ្នូ	**856,157**	**119,352**	**3,488,840**	**479,556**

12. ទ្រព្យ និងបរិក្ខារ

2019	ការកែលម្អអគារ	គ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារ	បរិក្ខារការិយាល័យ	បរិក្ខារកុំព្យូទ័រ និងព័ត៌មានវិទ្យា	យានយន្ត	ទ្រព្យកំពុងបង្កើត	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)
ថ្លៃដើម								
នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2019	420,138	5,175	126,921	70,612	49,000	-	671,846	2,699,477
ការទិញបន្ថែម	2,288	3,347	146,371	235,463	1,350	446,633	835,452	3,385,252
ការលុបចោល	-	-	-	(1,556)	-	-	(1,556)	(6,305)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	57,475
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	422,426	8,522	273,292	304,519	50,350	446,633	1,505,742	6,135,899
ដក: រំលស់បង្គរ								
នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2019	34,932	431	10,522	9,759	4,083	-	59,727	239,983
រំលស់សម្រាប់ការិយបរិច្ឆេទ	84,407	1,423	46,170	74,176	10,002	-	216,178	875,953
ការលុបចោល	-	-	-	(604)	-	-	(604)	(2,447)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	8,363
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	119,339	1,854	56,692	83,331	14,085	-	275,301	1,121,852
តម្លៃយោង								
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	**303,087**	**6,668**	**216,600**	**221,188**	**36,265**	**446,633**	**1,230,441**	**5,014,047**

2018	ការកែលម្អអគារ	គ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារ	បរិក្ខារការិយាល័យ	បរិក្ខារកុំព្យូទ័រ និងព័ត៌មានវិទ្យា	យានយន្ត	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)
ថ្លៃដើម							
នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018	-	-	-	-	-	-	-
ការទិញបន្ថែម	420,138	5,175	126,921	70,612	49,000	671,846	2,717,617
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	(18,140)
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	420,138	5,175	126,921	70,612	49,000	671,846	2,699,477

2018	ការកែលម្អអគារ	គ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារ	បរិក្ខារការិយាល័យ	បរិក្ខារកុំព្យូទ័រ និងព័ត៌មានវិទ្យា	យានយន្ត	សរុប	
ដក: រំលស់បង្គរ							
នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018	-	-	-	-	-	-	-
រំលស់	34,932	431	10,522	9,759	4,083	59,727	241,596
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	(1,613)
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	34,932	431	10,522	9,759	4,083	59,727	239,983
តម្លៃយោង							
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	**385,206**	**4,744**	**116,399**	**60,853**	**44,917**	**612,119**	**2,459,494**

13. សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	**1,748,854**	**341,686**	**7,126,580**	**1,372,894**

ធនាគារ បានជួលអគារការិយាល័យ ។ ព័ត៌មានអំពីការជួល ដែលធនាគារជាអ្នកជួលត្រូវបានបង្ហាញដូចខាងក្រោម និង កំណត់សម្គាល់ 33 (ខ)។ ព័ត៌មានពាក់ព័ន្ធទៅនឹងបំណុលភតិសន្យាត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 17។

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
អគារការិយាល័យ				
ថ្លៃដើម				
នាថ្ងៃទី 1 ខែ មករា	399,845	-	1,606,577	-
ការទិញបន្ថែម	1,538,103	399,845	6,232,393	1,617,373
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	58,168	(10,796)
នាថ្ងៃទី 31 ខែ ធ្នូ	1,937,948	399,845	7,897,138	1,606,577
ដក: **រំលស់បង្គរ**				
នាថ្ងៃទី 1 ខែ មករា	58,159	-	233,683	-
រំលស់សម្រាប់ការិយបរិច្ឆេទ	130,935	58,159	530,549	235,253

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	6,326	(1,570)
នាថ្ងៃទី 31 ខែ ធ្នូ	189,094	58,159	770,558	233,683
តម្លៃយោង				
នាថ្ងៃទី 31 ខែ ធ្នូ	**1,748,854**	**341,686**	**7,126,580**	**1,372,894**

14. ទ្រព្យសកម្មផ្សេងៗ

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ចំណាយបង់មុន	**813,899**	**697,385**	**3,316,638**	**2,802,093**

15. ប្រាក់បញ្ញើរបស់អតិថិជន

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
គណនីសន្សំ	42,363,119	14,699,610	172,629,710	59,063,033
ប្រាក់បញ្ញើមានកាលកំណត់	30,313,654	486,090	123,528,140	1,953,110
គណនីចរន្ត	47,188,097	1,513,954	192,291,495	6,083,067
ប្រាក់បញ្ញើមានកម្រិត	50,000	50,000	203,750	200,900
	119,914,870	**16,749,654**	**488,653,095**	**67,300,110**

ប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានវិភាគដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ក. តាមកាលកំណត់៖				
រយៈពេល 1 ខែ	89,561,262	16,213,564	364,962,143	65,146,100
> 1 ទៅ 3 ខែ	15,862,964	90,180	64,641,578	362,343
> 3 ទៅ 6 ខែ	731,068	245,138	2,979,102	984,965
> 6 ទៅ 12 ខែ	12,073,953	150,772	49,201,358	605,802
>លើសពី 12 ខែ	1,685,623	50,000	6,868,914	200,900
	119,914,870	**16,749,654**	**488,653,095**	**67,300,110**
ខ តាមនិវាសនដ្ឋាន៖				
និវាសនជន	40,522,389	1,505,260	165,128,735	6,048,135
អនិវាសនជន	79,392,481	15,244,394	323,524,360	61,251,975
	119,914,870	**16,749,654**	**488,653,095**	**67,300,110**
គ. តាមទំនាក់ទំនង៖				
មិនមែនសម្ព័ន្ធញាតិ	**119,914,870**	**16,749,654**	**488,653,095**	**67,300,110**

ឃ. តាមអត្រាការប្រាក់៖

ប្រាក់បញ្ញើរបស់អតិថិជនទាំងអស់នេះទទួលអាត្រាការប្រាក់ប្រចាំឆ្នាំដូចខាងក្រោម៖

	2019	2018
គណនីសន្សំ	1%	1%
ប្រាក់បញ្ញើមានកាលកំណត់	2.00% - 6.00%	2.00% - 6.00%
ប្រាក់បញ្ញើមានកម្រិត	**ពុំមាន**	**ពុំមាន**

16. ប្រាក់បញ្ញើរបស់ធនាគារនានា

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
គណនីចរន្ត-ពុំមានការប្រាក់	**321,843**	**1,224,100**	**1,311,510**	**4,918,434**

ប្រាក់បញ្ញើរបស់ធនាគារ ត្រូវបានវិភាគដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ក. តាមកាលកំណត់៖				
រយៈពេល 1 ខែ	**321,843**	**1,224,100**	**1,311,510**	**4,918,434**
ខ. តាមទំនាក់ទំនង៖				
សម្ព័ន្ធញាតិ	311,923	1,224,100	1,271,086	4,918,434
មិនមែនសម្ព័ន្ធញាតិ	9,920	-	40,424	-
	321,843	**1,224,100**	**1,311,510**	**4,918,434**
គ. វិភាគនិវាសនដ្ឋាន៖				
អនិវាសនជន	**321,843**	**1,224,100**	**1,311,510**	**4,918,434**

17. បំណុលភតិសន្យា

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
វិភាគតាមកាលកំណត់ - លំហូរទឹកប្រាក់តាមកិច្ចសន្យាមិនទាន់ធ្វើអប្បហារ				
តិចជាង 1 ឆ្នាំ	254,293	100,000	1,036,244	401,800
1 ឆ្នាំ ទៅ 5 ឆ្នាំ	2,218,545	291,667	9,040,571	1,171,918
បំណុលភតិសន្យាសរុបមិនទាន់ធ្វើអប្បហារ	**2,472,838**	**391,667**	**10,076,815**	**1,573,718**
តម្លៃបច្ចុប្បន្ននៃបំណុលភតិសន្យា				
រយៈពេលខ្លី	155,138	81,315	632,187	326,724
រយៈពេលវែង	1,566,332	266,962	6,382,803	1,072,653
	1,721,470	**348,277**	**7,014,990**	**1,399,377**
ចំនួនដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត				
ការប្រាក់លើបំណុលភតិសន្យា	48,208	15,098	195,339	61,071
ចំណាយទាក់ទងនឹងភតិសន្យារយៈពេលខ្លី	13,522	19,397	54,791	78,461
	61,730	**34,495**	**250,130**	**139,532**
ចំនួនដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លំហូរទឹកប្រាក់				
លំហូរទឹកប្រាក់ភតិសន្យាសរុប	213,118	66,666	868,456	267,864

18. បំណុលផ្សេងៗ

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ការបង់ពន្ធផ្សេងទៀត	68,558	88,017	279,373	353,652
ចំណាយបង្គរ និងបំណុលផ្សេងៗ	445,327	24,000	1,814,708	96,431
	513,885	**112,017**	**2,094,081**	**450,083**

19. ពន្ធលើប្រាក់ចំណេញ

ក. ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ពន្ធពន្យារជាទ្រព្យសកម្ម	426,210	263,168	1,736,806	1,057,409
ពន្ធពន្យារជាបំណុល	(349,771)	(88,008)	(1,425,317)	(353,616)
ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ	**76,439**	**175,160**	**311,489**	**703,793**

ពន្ធពន្យារជាទ្រព្យសកម្ម រួមមានគណនីដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ការខាតបង់សំវិធានធនលើឱនភាពនៃតម្លៃ	51,394	34,507	209,431	138,649
រំលស់	6,055	(19,671)	24,674	(79,038)
សំវិធានធនលើអត្ថប្រយោជន៍និយោជិត	360	2,310	1,467	9,282
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	(349,771)	(68,337)	(1,425,317)	(274,578)
បំណុលភតិសន្យា	344,294	69,655	1,402,998	279,873
ប្រាក់ចំណូលបង្គរ	24,107	-	98,236	-
ការខាតបង់ពន្ធដែលមិនបានទទួលស្គាល់	-	156,696	-	629,605
	76,439	**175,160**	**311,489**	**703,793**

បម្រែបម្រួលនៃពន្ធពន្យា - សុទ្ធ មានដូចខាងក្រោម៖

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
នាថ្ងៃទី 1 ខែ មករា	175,160	-	703,793	-
ទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬ ខាត	(98,721)	175,160	(400,017)	708,522
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	7,713	(4,729)
នាថ្ងៃទី 31 ខែ ធ្នូ	**76,439**	**175,160**	**311,489**	**703,793**

ខ. បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
នាថ្ងៃទី 1 ខែ មករា	-	-	-	-
ចំណាយពន្ធលើប្រាក់ចំណេញ	227,917	-	923,520	-
ពន្ធលើប្រាក់ចំណេញបានបង់	(52,079)	-	(211,024)	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	4,044	-
នាថ្ងៃទី 31 ខែ ធ្នូ	**175,838**	**-**	**716,540**	**-**

គ. ចំណាយ/(ឥណទាន)ពន្ធលើប្រាក់ចំណេញ

អនុលោមតាមច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ ដោយគណនាតាមអត្រា 20% នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមាដោយគណនាតាមអត្រា 1% នៃប្រាក់ចំណូលនៅពេលដែលពន្ធមួយណាមានចំនួនធំជាង។

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ចំណាយ/(ឥណទាន)ពន្ធលើប្រាក់ចំណេញ				
ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ	227,917	-	923,520	-
ពន្ធពន្យារ	98,721	(175,160)	400,017	(708,522)
	326,638	(175,160)	1,323,537	(708,522)
ចំណាយលើពន្ធអប្បបរមា	**-**	**5,530**	**-**	**22,369**

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញដែលត្រូវបានគណនាតាមអត្រាពន្ធផ្លូវការ 20% ចំពោះចំណាយពន្ធលើប្រាក់ចំណេញ/(ឥណទាន) ដូចបានបង្ហាញនៅក្នុងប្រាក់ចំណេញ ឬខាត ដូចខាងក្រោម៖

	2019			2018		
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	%	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	%
ប្រាក់ចំណេញ/(ខាត)មុនដកពន្ធ	1,465,845	5,939,604		(1,049,459)	(4,245,062)	
ពន្ធលើប្រាក់ចំណេញតាមអត្រាផ្លូវការ 20%	293,169	1,187,921	20%	(209,892)	(849,013)	20%
ចំណាយមិនអាចកាត់កងបាន	33,469	135,616	2%	34,732	140,491	-3%
ចំណាយ/(ឥណទាន)ពន្ធលើប្រាក់ចំណេញ	**326,638**	**1,323,537**	**22%**	**(175,160)**	**(708,522)**	**17%**

ការគណនាប្រាក់ចំណេញជាប់ពន្ធ គឺស្ថិតក្រោមការត្រួតពិនិត្យ និងវាយតម្លៃពីអាជ្ញាធរពន្ធដារ ។

20. ដើមទុន

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019			ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		
	% នៃ កម្មសិទ្ធិ	ចំនួន ភាគហ៊ុន	ទឹកប្រាក់ ដុល្លារអាមេរិក	% នៃ កម្មសិទ្ធិ	ចំនួន ភាគហ៊ុន	ទឹកប្រាក់ ដុល្លារអាមេរិក
Asia Investment and Financial Services Sole Co., Ltd.	60%	45,000,000	45,000,000	60%	45,000,000	45,000,000
Paradise Investment Co., Ltd.	15%	11,250,000	11,250,000	15%	11,250,000	11,250,000
PrimeStreet Advisory Co., Ltd.	25%	18,750,000	18,750,000	25%	18,750,000	18,750,000
	100%	75,000,000	75,000,000	100%	75,000,000	75,000,000
(ពាន់រៀលកំណត់សម្គាល់ 5)			**300,000,000**			**300,000,000**

ចំនួនភាគហ៊ុនដែលដែលបានចុះបញ្ជីសរុបមានចំនួន 75,000,000 ភាគហ៊ុន (2018: 75,000,000 ភាគហ៊ុន) ដែលមានតម្លៃស្មើ 1 ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន ។ ភាគហ៊ុនទាំងអស់ត្រូវបានបោះផ្សាយ និងបានបង់គ្រប់ចំនួន។

21. ចំណូលពីការប្រាក់

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ឥណទាន និងបុរេប្រទាន	3,546,167	273,984	14,369,069	1,108,265
ការវិនិយោគផ្សេងៗ	1,368,750	258,250	5,546,175	1,044,621
ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា	47,195	23,628	191,234	95,575
ប្រាក់បញ្ញើនៅធនាគារនានា	277,356	2,547	1,123,846	10,303
	5,239,468	**558,409**	**21,230,324**	**2,258,764**

22. ចំណាយលើការប្រាក់

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
គណនីសន្សំ	214,966	8,730	871,042	35,313
ប្រាក់បញ្ញើមានកាលកំណត់ និងចរន្ត	556,811	596	2,256,198	2,411
បំណុលភតិសន្យា	48,208	15,098	195,339	61,071
	819,985	**24,424**	**3,322,579**	**98,795**

23. ចំណូលកម្រៃ និងជើងសារសុទ្ធ

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
សេវាផ្ទេរប្រាក់ចេញចូល	54,662	515	221,490	2,083
កម្រៃផ្សេងៗ	213,182	2,267	863,814	9,170
	267,844	**2,782**	**1,085,304**	**11,253**

24. ចំណូលផ្សេងៗ

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ចំណេញលើការប្តូរប្រាក់បរទេស	**40,876**	**836**	**165,630**	**3,382**

25. ចំណាយលើបុគ្គលិក

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល	784,278	277,208	3,177,894	1,121,306
អត្ថប្រយោជន៍បន្ថែម	1,733	-	7,022	-
អត្ថប្រយោជន៍ផ្សេងៗ	7,144	5,627	28,948	22,762
	793,155	**282,835**	**3,213,864**	**1,144,068**

26. រំលស់

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
រំលស់លើទ្រព្យ និងបរិក្ខារ	216,178	59,727	875,953	241,596
រំលស់លើទ្រព្យសកម្មអរូបី	309,773	19,225	1,255,200	77,765
រំលស់លើសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	130,935	58,159	530,549	235,253
	656,886	**137,111**	**2,661,702**	**554,614**

27. ចំណាយលើប្រតិបត្តិការផ្សេងៗ

	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ចំណាយលើផ្នែកវិជ្ជាជីវៈ	1,047,361	522,850	4,243,907	2,114,928
ចំណាយពន្ធផ្សេងៗ	196,649	169,877	796,822	687,152
ចំណាយលើជួសជុល និងថែទាំ	56,970	11,039	230,842	44,653
កម្រៃអាជ្ញាប័ណ្ណ	48,383	19,043	196,048	77,029
ចំណាយលើទឹកភ្លើង	30,379	15,656	123,096	63,329
ចំណាយលើសម្ភារៈការិយាល័យ	18,288	17,506	74,103	70,812
ចំណាយលើការជួល	13,522	19,397	54,791	78,461
ចំណាយលើទំនាក់ទំនងសាធារណៈ ទីផ្សារ និងផ្សាយពាណិជ្ជកម្ម	13,206	77,519	53,511	313,564
ចំណាយលើធានារ៉ាប់រង	12,022	4,230	48,713	17,110
ចំណាយលើការធ្វើដំណើរ និងការកម្សាន្ត	8,940	-	36,225	-
ចំណាយលើទំនាក់ទំនង	10,452	1,158	42,352	4,684
ចំណាយផ្សេងៗ	271,709	130,777	1,100,964	528,993
	1,727,881	**989,052**	**7,001,374**	**4,000,715**

28. យថាភាពលើពន្ធ

ពន្ធត្រូវបានស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានអង្កេតដោយក្រុមអាជ្ញាធរ ដែលផ្តល់សិទ្ធិដោយច្បាប់ក្នុងការដាក់ពិន័យដាក់ទណ្ឌកម្ម និងគិតការប្រាក់ ។ ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពន្ធលើប្រតិបត្តិការច្រើនប្រភេទអាចប្រឈមនឹងបំណកស្រាយផ្សេងៗ។

បញ្ហាទាំងនេះ អាចបង្កើតឲ្យមានហានិភ័យពន្ធ នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈធំជាងនៅប្រទេសដទៃទៀត ។ អ្នកគ្រប់គ្រងជឿជាក់ថា ការធ្វើសំវិធានធនមានលក្ខណៈគ្រប់គ្រាន់ ដោយផ្អែកទៅលើការបកស្រាយនៃនីតិកម្មពន្ធ ។ ក៏ប៉ុន្តែ អាជ្ញាធរជាប់ពាក់ព័ន្ធអាចនឹងមានបំណកស្រាយខុសគ្នា ហើយផលប៉ះពាល់អាចមានទំហំធំ ។

29. សម្ព័ន្ធញាតិ

ក. អត្តសញ្ញាណរបស់សម្ព័ន្ធញាតិ

ទំនាក់ទំនាក់របស់សម្ព័ន្ធញាតិជាមួយនិងក្រុមហ៊ុនទាំងមូលនិងធនាគារមានដូចខាងក្រោម៖

ទំនាក់ទំនង	សម្ព័ន្ធញាតិ
ក្រុមហ៊ុនមេផ្ទាល់	យោងតាមកំណត់សម្គាល់ 20
សម្ព័ន្ធញាតិ	ក្រុមហ៊ុនស្ថិតក្រោមភាគទុនិកធំបំផុតតែមួយ
អ្នកគ្រប់គ្រងសំខាន់ៗ	រាល់អភិបាលនៃធនាគារ ដែលជាអ្នកធ្វើការសម្រេចចិត្តសំខាន់ៗ ដែលទាក់ទងទៅនឹងទិសដៅយុទ្ធសាស្ត្រ និងបុគ្គលិកគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ (រួមបញ្ចូលទាំងសមាជិកគ្រួសារ)

ខ. ឥណទាន និងបុរេប្រទានផ្តល់ដល់សម្ព័ន្ធញាតិ

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ឥណទាន	**15,432,417**	**-**	**62,887,099**	**-**

គ. ប្រាក់បញ្ញើរបស់ធនាគារនានា

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ប្រាក់បញ្ញើ	**311,923**	**1,224,100**	**1,271,086**	**4,918,434**

ឃ. លាភការរបស់អ្នកគ្រប់គ្រងសំខាន់ៗ

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	2019	2018	2019	2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍	**226,086**	**153,791**	**916,102**	**622,085**

30. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

ក. សេចក្តីផ្តើម និងទស្សនៈទូទៅ

ធនាគារប្រឈមមុខនឹងហានិភ័យឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោម៖

- ហានិភ័យឥណទាន
- ហានិភ័យទីផ្សារ
- ហានិភ័យសាច់ប្រាក់ងាយស្រួល និង
- ហានិភ័យប្រតិបត្តិការ

កំណត់សម្គាល់នេះ បង្ហាញពីព័ត៌មានស្តីពី ហានិភ័យនីមួយៗ ខាងលើរបស់ធនាគារ ដែលមានគោលដៅ គោលការណ៍ណែនាំ និងវិធានការរបស់ធនាគារ ដើម្បីវាស់វែង និងចាត់ចែងនូវហានិភ័យដែលកើតឡើង និងការគ្រប់គ្រងនូវដើមទុនរបស់ធនាគារ។

មុខងារគ្រប់គ្រងហានិភ័យ និងរចនាសម្ព័ន្ធអភិបាលកិច្ច

ក្រុមប្រឹក្សាភិបាលរបស់ធនាគារមានការទទួលខុសត្រូវទាំងស្រុងសម្រាប់ការបង្កើត និងត្រួតពិនិត្យលើក្របខណ្ឌគ្រប់គ្រងហានិភ័យរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការគ្រប់គ្រង ទ្រព្យសកម្ម និងទទួលខុសត្រូវក្នុងការអនុម័ត និងត្រួតពិនិត្យគោលនយោបាយគ្រប់គ្រងហានិភ័យរបស់ធនាគារ ។

គោលនយោបាយគ្រប់គ្រងហានិភ័យរបស់ធនាគារ ត្រូវបានបង្កើតឡើងដើម្បីកំណត់លក្ខណៈ និងវិភាគហានិភ័យ ដែលធនាគារបានប្រឈមដើម្បីកំណត់ និងគ្រប់គ្រងហានិភ័យឲ្យបានសមស្រប និងតាមដានហានិភ័យ និងការប្រកាន់ខ្ជាប់នូវដែនកំណត់។ គោលនយោបាយ និងប្រព័ន្ធគ្រប់គ្រងហានិភ័យ ត្រូវបានពិនិត្យឡើងវិញជាប្រចាំដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរលក្ខខណ្ឌទីផ្សារ និងសកម្មភាពរបស់ធនាគារ ។ ធនាគារ តាមរយៈស្តង់ដារនៃការបណ្តុះបណ្តាល ការគ្រប់គ្រង និងនីតិវិធីគ្រប់គ្រងរបស់ខ្លួន គឺក្នុងគោលបំណងអភិវឌ្ឍន៍ត្រួតពិនិត្យដែលមានវិន័យ និងបង្កើតការត្រួតពិនិត្យស្ថានភាព ដែលបុគ្គលិកទាំងអស់យល់ពីតួនាទី និងកាតព្វកិច្ចរបស់ពួកគេ។

ខ. ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ធនាគារ ប្រសិនបើអតិថិជនឬភាគីម្ខាងទៀត មិនមានលទ្ធភាពបំពេញកាតព្វកិច្ចទៅតាមកិច្ចសន្យា ហើយហានិភ័យជាចម្បងនេះ គឺកើតចេញតាមរយៈការផ្តល់ ឥណទាន និងបុរេប្រទានដល់អតិថិជន ធនាគារនានា និងការវិនិយោគលើបំណុល ។ សម្រាប់គោលបំណងរាយការណ៍អំពីការគ្រប់គ្រងហានិភ័យធនាគារធ្វើការពិចារណា និងដាក់រួមបញ្ចូលនូវធាតុទាំងអស់នៃហានិភ័យឥណទានដែលប្រឈម - ឧទាហរណ៍ ហានិភ័យតាមកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗ តាមតំបន់ និងហានិភ័យតាមវិស័យសេដ្ឋកិច្ច។

ហានិភ័យឥណទាន គឺជាការខាតបង់ហិរញ្ញវត្ថុរបស់ធនាគារ ប្រសិនបើអ្នកខ្ចី ឬដៃគូពាណិជ្ជកម្មខកខានមិនបានបំពេញកាតព្វកិច្ចលើការបង់ប្រាក់ដើមចំពោះឥណទាន និងបុរេប្រទាន ។

(i). ការគ្រប់គ្រងហានិភ័យឥណទាន

ក្រុមប្រឹក្សាភិបាល បានបង្កើតគណៈកម្មាធិការឥណទានធនាគារ សម្រាប់ត្រួតពិនិត្យហានិភ័យឥណទាន ។ នាយកដ្ឋានឥណទានដោយឡែកត្រូវរាយការណ៍ជូនគណៈកម្មាធិការឥណទាន ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យឥណទានរួមមានដូចខាងក្រោម ។

- ការរៀបចំគោលនយោបាយឥណទាន ក្នុងការពិគ្រោះយោបល់ជាមួយអង្គភាពអាជីវកម្មដែល រួមមានតម្រូវការទ្រព្យបញ្ចាំ ការវាយតម្លៃឥណទាន ការដាក់ចំណាត់ថ្នាក់ហានិភ័យ និងការធ្វើរបាយការណ៍ ការរៀបចំឯកសារ និងនីតិវិធីនៃច្បាប់ និងអនុលោមតាមតម្រូវការបទប្បញ្ញត្តិ និងច្បាប់ ។
- ការបង្កើតរចនាសម្ព័ន្ធសិទ្ធិអំណាច សម្រាប់ការអនុម័ត និងបន្តឥណទាន ។ ដែនកំណត់នៃសិទ្ធិអំណាច ត្រូវបានចាត់ចែងសម្រាប់មន្ត្រីឥណទាននៃអង្គភាពអាជីវកម្ម ។ ឥណទានដែលមានទំហំធំ តម្រូវឲ្យមានការអនុម័តពីផ្នែកឥណទានធនាគារ ប្រធានផ្នែកឥណទាន គណៈកម្មាធិការឥណទាន ឬក្រុមប្រឹក្សាភិបាល ។
- ធ្វើការត្រួតពិនិត្យ និងវាយតម្លៃហានិភ័យឥណទាន៖ អ្នកគ្រប់គ្រងឥណទានរបស់ធនាគារវាយតម្លៃរាល់ហានិភ័យឥណទានដែលហួសកម្រិតកំណត់ មុនពេលដែលឥណទាននានាត្រូវបានផ្តល់ជូន អតិថិជនដោយអង្គភាពអាជីវកម្មដែលពាក់ព័ន្ធ។ ការបន្ត និងការពិនិត្យឡើងវិញនៃឥណទានគឺស្ថិតនៅក្រោមដំណើរការត្រួតពិនិត្យដូចគ្នា។

- កម្រិតលើការប្រឈម ដែលកើតពីដែគូភាគី ភូមិសាស្ត្រ និងឧស្សាហកម្ម (សម្រាប់តណទាន និងបុរេប្រទានការធានាហិរញ្ញវត្ថុ និងការប្រឈមប្រហាក់ប្រហែល) និងដោយអ្នកចេញប័ណ្ណ ការចាត់ថ្នាក់តណទាន ហានិភ័យទីផ្សារងាយស្រួល និងតំបន់ (សម្រាប់មូលបត្រវិនិយោគ)។
- ការអភិវឌ្ឍន៍ និងការការពារ ចំណាត់ថ្នាក់ហានិភ័យរបស់ធនាគារ ដើម្បីបង្ហាញពីចំណាត់ថ្នាក់ដោយផ្អែកតាមកម្រិតហានិភ័យនៃការមិនទូទាត់សង ។ ក្របខណ្ឌកំណត់ហានិភ័យបច្ចុប្បន្នរួមមាន 5 ថ្នាក់ ដែលឆ្លុះបញ្ចាំងពីកម្រិតខុសៗ គ្នានៃហានិភ័យ ។ ការទទួលខុសត្រូវចំពោះការកំណត់ចំណាត់ថ្នាក់ហានិភ័យ គឺអាស្រ័យលើការអនុម័តចុងក្រោយដោយនាយកប្រតិបត្តិ ឬគណៈកម្មាធិការ ប្រសិនបើសមរម្យ។ ចំណាត់ថ្នាក់ហានិភ័យ ត្រូវឆ្លងកាត់ការត្រួតពិនិត្យជាប្រចាំ ដោយអ្នកគ្រប់គ្រងហានិភ័យរបស់ធនាគារ ។
- ការអភិវឌ្ឍន៍ និងរក្សាដំណើរការរបស់ធនាគារសម្រាប់វាស់វែង ECL៖ នេះរួមបញ្ចូលទាំងដំណើរការសម្រាប់៖
  - ការអនុម័តដំបូង ការបញ្ជាក់ពីភាពត្រឹមត្រូវ និងការធ្វើតេស្តទិន្នន័យថយក្រោយ (Back - testing) នៃម៉ូដែលដែលបានប្រើ
  - កំណត់ និងតាមដានការកើនឡើងហានិភ័យតណទានជាសារវន្ត និងការបង្កើតព័ត៌មាននៃការប្រមើលអនាគត ។
- ការពិនិត្យឡើងវិញនូវអនុលោមភាព របស់អង្គភាពអាជីវកម្ម ទៅនឹងកម្រិតហានិភ័យដែលបានព្រមព្រៀង រួមទាំងសហគ្រាសដែលបានជ្រើសរើសហានិភ័យប្រទេស និងប្រភេទផលិតផល។ របាយការណ៍ទៀងទាត់ស្តីពីគុណភាពតណទាន ត្រូវបានផ្តល់ជូនដល់អ្នកគ្រប់គ្រងតណទានរបស់ធនាគារ ដែលអាចតម្រូវឲ្យមានវិធានការកែតម្រូវសមស្របដែលត្រូវអនុវត្ត។ ទាំងនេះរាប់បញ្ចូលទាំងរបាយការណ៍ដែលមានការប៉ាន់ស្មានសំវិធានធនលើ ECL។
- ការផ្តល់ដំបូន្មាន ការណែនាំ និងជំនាញឯកទេស ដល់អង្គភាពអាជីវកម្មដើម្បីលើកកម្ពស់ការអនុវត្តឲ្យមានប្រសិទ្ធភាពបំផុតនៅទូទាំងធនាគារក្នុងការគ្រប់គ្រងហានិភ័យតណទាន។

អង្គភាពអាជីវកម្មនីមួយៗ តម្រូវឲ្យអនុវត្តគោលនយោបាយ និងនីតិវិធីតណទានរបស់ធនាគារដោយមានការអនុម័តពីអាជ្ញាធរតណទានដើម្បីផ្ទេរសិទ្ធិពីគណៈកម្មាធិការតណទានធនាគារ។ អង្គភាពអាជីវកម្មនីមួយៗ មានប្រធានផ្នែកហានិភ័យតណទានដែលរាយការណ៍អំពីបញ្ហាទាក់ទងនឹងតណទានដល់អ្នកគ្រប់គ្រងមូលដ្ឋាន និងគណៈកម្មាធិការតណទានធនាគារ ។ អង្គភាពអាជីវកម្មនីមួយៗ ទទួលខុសត្រូវចំពោះគុណភាព និងដំណើរការនៃផលបត្រតណទានរបស់ខ្លួន និង ត្រួតពិនិត្យ និង គ្រប់គ្រងហានិភ័យតណទានទាំងអស់នៅក្នុងផលបត្ររបស់ខ្លួន រួមទាំងបែបបទដែលមានការអនុម័តពីការិយាល័យកណ្តាល។

សវនកម្មផ្ទៃក្នុងនៃអង្គភាពអាជីវកម្ម និងដំណើរការរបស់អ្នកគ្រប់គ្រងតណទានធនាគារត្រូវបានធ្វើដោយសវនកម្មផ្ទៃក្នុង។

(ii). ការប្រមូលផ្តុំហានិភ័យ

ក្រុមប្រឹក្សាភិបាលធនាគារបានបង្កើត គណៈកម្មាធិការតណទានរបស់ធនាគារសម្រាប់ត្រួតពិនិត្យទៅលើហានិភ័យតណទាន។ អគ្គនាយកដ្ឋានតណទានរបស់ធនាគារដាច់ដោយឡែក រាយការណ៍ទៅកាន់ គណៈកម្មាធិការតណទានរបស់ធនាគារដែលទទួលខុសត្រូវទៅលើការគ្រប់គ្រងហានិភ័យតណទានរបស់ធនាគារ បូករួមនិងខាងក្រោមមានដូចជា៖

តារាងខាងក្រោមបង្ហាញពីការប្រឈមនឹងហានិភ័យអតិបរមារបស់ធនាគារ ចំពោះហានិភ័យតណទានក្នុងតារាងតុល្យការ និងឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការ ដោយមិនគិតពីទ្រព្យបញ្ចាំ ឬការពង្រឹង តណទានដទៃទៀត។ សម្រាប់ទ្រព្យសកម្មក្នុងតារាងតុល្យការ ការប្រឈមនឹងហានិភ័យតណទាន ស្មើនឹងតម្លៃយោងរបស់វា។ ចំពោះបំណុលយថាភាព ការប្រឈមនឹងហានិភ័យតណទានអតិបរមា គឺជាចំនួនអតិបរមាដែលធនាគារត្រូវបង់ប្រសិនបើកាតព្វកិច្ចនៃឧបករណ៍ហិរញ្ញវត្ថុត្រូវបានស្នើសុំ ។ ចំពោះកិច្ចសន្យាតណទាន ការប្រឈមទៅនឹងហានិភ័យតណទានអតិបរមា គឺជាចំនួនទឹកប្រាក់គ្រប់គ្រាន់នៃតណទានដែលមិនទាន់ដកចេញដោយអតិថិជន ។

ការប្រឈមនឹងប្រភេទហានិភ័យឥណទាន

	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា	ការដាក់ទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន	ផ្នែកខ្លះនៃទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន	មិនមានការធានា និងគ្មានទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	%	%	%
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019					
ធាតុនានាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ					
សាច់ប្រាក់ និងសាច់ប្រាក់សមមូល- ដុល	61,316,386	249,864,273	-	-	100%
ប្រាក់បញ្ញើជាមួយធនាគារនានា- ដុល	18,058,081	73,586,680	-	-	100%
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន-ដុល	67,770,609	276,165,232	74%	-	26%
ការវិនិយោគផ្សេងៗ-ដុល	22,527,783	91,800,716	-	-	100%
សរុប	**169,672,859**	**691,416,901**			
ធាតុនានាក្រៅរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ					
បំណុលយថាភាព	901,775	3,674,733	69%	-	31%
កិច្ចសន្យា	2,606,046	10,619,637	62%	-	38%
សរុប	**3,507,821**	**14,294,370**			

	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា	ការដាក់ទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន	ផ្នែកខ្លះនៃទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន	មិនមានការធានា និងគ្មានទ្រព្យ បញ្ចាំ/ការពង្រឹងឥណទាន
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	%	%	%
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018					
ធាតុនានាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ					
សាច់ប្រាក់ និងសាច់ប្រាក់សមមូល - ដុល	22,202,346	89,209,026	-	-	100%
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	36,108,399	145,083,547	99.9%	-	0.01%
ការវិនិយោគផ្សេងៗ - ដុល	22,578,250	90,719,409	-	-	100%
សរុប	**80,888,995**	**325,011,982**			

	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា	ការដាក់ទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន	ផ្នែកខ្លះនៃទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន	មិនមានការធានា និងគ្មានទ្រព្យ បញ្ចាំ/ការពង្រឹងឥណទាន
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	%	%	%
ថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2018					
ធាតុនានាក្រៅរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ					
បំណុលយថាភាព	17,096	68,692	-	-	100%
សរុប	**17,096**	**68,692**			

ការប្រមូលផ្តុំហានិភ័យវិភាគតាមប្រភេទអាជីវកម្ម

ថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2019	សាច់ប្រាក់និងសាច់ប្រាក់សមមូល - ដុល	ប្រាក់បញ្ញើនៅធនាគារនានា - ដុល	ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	ការវិនិយោគផ្សេងៗ - ដុល	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និង ទូរគមនាគមន៍	-	-	14,006,189	-	14,006,189
ពាណិជ្ជកម្ម	-	-	46,260	-	46,260
អចលនទ្រព្យ	-	-	31,397,481	-	31,397,481
គ្រឹះស្ថានហិរញ្ញវត្ថុ	61,316,386	18,058,081	-	-	79,374,467
កម្ចីបុគ្គលិក	-	-	550,601	-	550,601
ផ្សេងៗ	-	-	21,770,078	22,527,783	44,297,861
សរុប	61,316,386	18,058,081	67,770,609	22,527,783	169,672,859
សរុប (ពាន់រៀល – កំណត់សម្គាល់ 5)	**249,864,273**	**73,586,680**	**276,165,232**	**91,800,716**	**691,416,901**
ថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2018					
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និង ទូរគមនាគមន៍	-	-	14,043,828	-	14,043,828
ពាណិជ្ជកម្ម	-	-	49,999	-	49,999
អចលនទ្រព្យ	-	-	22,014,572	-	22,014,572
គ្រឹះស្ថានហិរញ្ញវត្ថុ	22,202,346	-	-	-	22,202,346
ផ្សេងៗ	-	-	-	22,578,250	22,578,250
សរុប	22,202,346	-	36,108,399	22,578,250	80,888,995
សរុប (ពាន់រៀល – កំណត់សម្គាល់ 5)	**89,209,026**	**-**	**145,083,547**	**90,719,409**	**325,011,982**

ការប្រមូលផ្តុំហានិភ័យវិភាគតាមនិវាសដ្ឋាន និងទំនាក់ទំនង និងការប្រឈមទៅនឹងហានិភ័យនៃឥណទាន និងបុរេប្រទានធំៗ ៖

	ថ្ងៃទី 31 ខែ ធ្នូ		ថ្ងៃទី 31 ខែ ធ្នូ	
	ឆ្នាំ 2019	ឆ្នាំ 2018	ឆ្នាំ 2019	ឆ្នាំ 2018
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)	ពាន់រៀល (កំណត់សម្គាល់ 5)
វិភាគតាមនិវាសដ្ឋាន៖				
និវាសជន	**67,770,609**	**36,108,399**	**276,165,232**	**145,083,547**
វិភាគតាមទំនាក់ទំនង៖				
អតិថិជនខាងក្រៅ	51,787,591	36,108,399	211,034,434	145,083,547
ឥណទានបុគ្គលិក	550,601	-	2,243,699	-
សម្ព័ន្ធញាតិ	15,432,417	-	62,887,099	-
	67,770,609	**36,108,399**	**276,165,232**	**145,083,547**
តាមហានិភ័យ៖				
ហានិភ័យទំហំធំ (*)	49,088,877	28,053,162	200,037,174	112,717,605
ហានិភ័យទំហំតូច	18,681,732	8,055,237	76,128,058	32,365,942
	67,770,609	**36,108,399**	**276,165,232**	**145,083,547**

(*) ហានិភ័យទំហំធំ ត្រូវបានកំណត់ដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ថាជាហានិភ័យដុលនៃសមតុល្យសរុបនៃឥណទាន និងបុរេប្រទានជាមួយអ្នកទទួលផលតែមួយដែលមានចំនួនលើសពី 10% នៃទ្រព្យសម្បត្តិសុទ្ធរបស់ធនាគារ ។ ផលប៉ះពាល់នេះ គឺខ្ពស់ជាងឥណទាន ឬកិច្ចសន្យា ដែលនៅសល់ និងឥណទាន ឬកិច្ចសន្យាដែលបានអនុម័ត ។

(iii). ទ្រព្យបញ្ចាំ

ខណៈពេលដែលការប្រឈមនឹងហានិភ័យអតិបរមារបស់ធនាគារ គឺជាតម្លៃយោងរបស់ទ្រព្យសកម្ម ឬក្នុងករណីឧបករណ៍ហិរញ្ញវត្ថុនៅក្រៅតារាងតុល្យការ គឺចំនួនទឹកប្រាក់ដែលបានធានា ការសន្យាផ្តល់ឲ្យ ការទទួលយក ឬការយល់ព្រម ហានិភ័យទាំងនោះទំនងអាចទាបជាងដោយសារតែការកាត់កងទ្រព្យបញ្ចាំ ការធានាឥណទាន និងសកម្មភាពផ្សេងទៀតដើម្បីកាត់បន្ថយហានិភ័យ។

ការពិពណ៌នាអំពីទ្រព្យបញ្ចាំសម្រាប់ប្រភេទនៃទ្រព្យសកម្មហិរញ្ញវត្ថុនីមួយៗ ត្រូវបានបង្ហាញដូចខាងក្រោម៖

សាច់ប្រាក់ និងសាច់ប្រាក់សមមូល ប្រាក់បញ្ញើជាមួយធនាគារនានា និងការវិនិយោគផ្សេងៗ

ទ្រព្យបញ្ចាំជាទូទៅមិនត្រូវបានស្វែងរកសម្រាប់ទ្រព្យសកម្មទាំងនេះទេ ។

ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន បំណុល និងការសន្យាយថាភាព

ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន បំណុលយថាភាព និងការសន្យា ជាធម្មតាត្រូវមានដាក់ជាទ្រព្យបញ្ចាំក្នុងកម្រិតណាមួយ។ ជាពិសេសហានិភ័យលើឥណទានគេហដ្ឋាន ជាទូទៅត្រូវបានធានាពេញលេញដោយគេហដ្ឋាន ។

តារាងខាងក្រោមនេះសង្ខេបអំពីការធានាលើទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន៖

	ទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន					
	ទ្រព្យ	ទ្រព្យសកម្មចល័ត	គណនីមានកាលកំណត់	ផ្សេងៗ	ឥណទានពុំមានការធានា	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2019						
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	50,435,194	-	-	-	17,335,415	67,770,609
បំណុលយថាភាព	620,000	-	-	-	281,775	901,775
កិច្ចសន្យា	1,606,046	-	-	-	1,000,000	2,606,046
	52,661,240	-	-	-	18,617,190	71,278,430
ពាន់រៀល (**កំណត់សម្គាល់** 5)	**214,594,553**	**-**	**-**	**-**	**75,865,049**	**290,459,602**
ថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2018						
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	36,058,400	-	-	-	49,999	36,108,399
បំណុលយថាភាព	-	-	-	-	17,096	17,096
	36,058,400	-	-	-	67,095	36,125,495
ពាន់រៀល (**កំណត់សម្គាល់** 5)	**144,882,651**	**-**	**-**	**-**	**269,588**	**145,152,239**

(iv). គុណភាពនៃឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល

ដោយអនុលោមតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-017-344 ចំណាត់ថ្នាក់ឥណទាននីមួយៗ យោងទៅតាមគុណភាពឥណទានដូចខាងក្រោម៖

ឥណទានធម្មតា៖

ឥណទានដែលនៅសល់ ត្រូវបានទូទាត់សងទាន់ពេលវេលា និងមិនជាប់សង្ស័យសម្រាប់ការទូទាត់សងនាពេលអនាគត ។ ការទូទាត់សងត្រូវបានធ្វើឡើងតាមកិច្ចសន្យា ហើយអតិថិជនមិនបង្ហាញពីភាពទន់ខ្សោយ នៃលទ្ធភាពក្នុងការទូទាត់សង អាជីវកម្ម លំហូរទឹកប្រាក់ និងស្ថានភាពហិរញ្ញវត្ថុនោះឡើយ ។

ឥណទានឃ្លាំមើល៖

ឥណទានដែលនៅក្នុងចំណាត់ថ្នាក់នេះ ត្រូវបានការពារនាពេលបច្ចុប្បន្ន ហើយប្រហែលជាមិនអាចហួសកាលកំណត់ទេ ប៉ុន្តែវាបង្ហាញពីភាពទន់ខ្សោយដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការទូទាត់សងរបស់កូនបំណុលនៅកាលបរិច្ឆេទនាពេលអនាគត ប្រសិនបើមិនបានកែតម្រូវឱ្យបានទាន់ពេលវេលា និងយកចិត្តទុកដាក់ពីគ្រឹះស្ថាន។

ភាពទន់ខ្សោយនេះរាប់បញ្ចូល ប៉ុន្តែមិនត្រូវបានកំណត់ចំពោះនិន្នាការថយចុះនៃប្រតិបត្តិការអាជីវកម្មរបស់ដៃគូភាគី ឬស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន និងស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌទីផ្សារដែល អាចប៉ះពាល់ដល់ប្រាក់ចំណេញ និងលទ្ធភាពទូទាត់សងនាពេលអនាគតរបស់ខ្លួន ឬស្ថានភាពកាន់តែយ៉ាប់យ៉ឺននៃទ្រព្យបញ្ចាំ។ ចំណាត់ថ្នាក់នេះមានសនិទានភាពផ្ទាល់ខ្លួនយ៉ាងច្បាស់លាស់ ហើយមិនគួរប្រើជាការសម្របសម្រួលរវាងឥណទានធម្មតា និងឥណទានក្រោមស្តង់ដារទេ ។

ឥណទានក្រោមស្តង់ដារ៖

ឥណទានដែលបានចាត់ថ្នាក់នៅក្នុងចំណាត់ថ្នាក់នេះ បង្ហាញពីភាពទន់ខ្សោយគួរឱ្យកត់សម្គាល់ ហើយមិនត្រូវបានការពារគ្រប់គ្រាន់ដោយអាជីវកម្មបច្ចុប្បន្ន ឬស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពសងរបស់កូនបំណុលទេ ។ និយាយឱ្យចំទៅប្រភពដើមនៃការសងបំណុលគឺមិនគ្រប់គ្រាន់ដើម្បីទូទាត់បំណុលនោះទេ ដោយមិនគិតពីប្រាក់ចំណូលដែលបានមកពីប្រភពបន្ទាប់បន្សំដូចជាលក់ទ្រព្យបញ្ចាំជាដើម។

កត្តាដែលនាំឱ្យមានចំណាត់ថ្នាក់ឥណទានក្រោមស្តង់ដាររួមមាន៖

- កូនបំណុលគ្មានលទ្ធភាពដើម្បីបំពេញតាមលក្ខខណ្ឌនៃការទូទាត់សងប្រាក់តាមកិច្ចសន្យា
- ស្ថានភាពសេដ្ឋកិច្ច និងទីផ្សារមិនអំណោយផល ដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់អាជីវកម្ម និងប្រាក់ចំណេញរបស់ដៃគូភាគីនាពេលអនាគត
- ស្ថានភាពហិរញ្ញវត្ថុទន់ខ្សោយ និង / ឬ អសមត្ថភាពរបស់ដៃគូភាគីដើម្បីបង្កើតលំហូរទឹកប្រាក់គ្រប់គ្រាន់ដើម្បីបំពេញការទូទាត់សង
- ភាពលំបាកដែលបានជួបប្រទះដោយដៃគូភាគី ក្នុងការទូទាត់សងឥណទានផ្សេងទៀត ដែលផ្តល់ដោយគ្រឹះស្ថាន ឬដោយស្ថាប័នផ្សេងៗទៀត នៅពេលមានព័ត៌មានអាចប្រើប្រាស់បាន និង
- ការបំពានលើកិច្ចព្រមព្រៀងហិរញ្ញវត្ថុដោយដៃគូភាគី។

ឥណទានជាប់សង្ស័យ៖

ឥណទានដែលបានចាត់ថ្នាក់នៅក្នុងប្រភេទនេះ បង្ហាញពីភាពទន់ខ្សោយធ្ងន់ធ្ងរជាងចំណាត់ថ្នាក់ឥណទានក្រោមស្តង់ដារ ដែលការប្រមូលបានមកវិញគ្រប់ចំនួន ផ្អែកលើមូលដ្ឋាននៃដំណើរហេតុដែលមានស្រាប់ លក្ខខណ្ឌ ឬតម្លៃនៃទ្រព្យបញ្ចាំមានការសង្ស័យខ្ពស់ ឬមិនអាចប្រមូលបានវិញ។ ការរំពឹងទុកថានឹងបាត់បង់គឺខ្ពស់ ទោះបីជាចំនួនពិតប្រាកដនៅមិនទាន់បានកំណត់សម្រាប់ពេលនេះក៏ដោយ ។

ឥណទានខាតបង់៖

ឥណទានដែលត្រូវបានចាត់ថ្នាក់ថាជាការបាត់បង់ គឺនៅពេលដែលវាមិនអាចប្រមូលបានមកវិញ ហើយការទូទាត់សងវិញអាចមានចំនួនតិចតួច ឬប្រមូលមិនបានសោះ ។

ការទទួលស្គាល់លើការរំពឹងទុកលើការខាតបង់ឥណទាន

ធនាគារអនុវត្តវិធីសាស្ត្រ 3 ដំណាក់កាល ដោយផ្អែកលើការផ្លាស់ប្តូរគុណភាពឥណទានចាប់តាំងពីមានការទទួលស្គាល់ដំបូង៖

	ដំណាក់កាលទី 1	ដំណាក់កាលទី 2	ដំណាក់កាលទី 3
វិធីសាស្ត្រ 3 ដំណាក់កាល	ដំណើរការ	ក្រោមដំណើរការ	មិនដំណើរការ
ការទទួលស្គាល់ឥណទានដែលរំពឹងថានឹងបាត់បង់	រំពឹងថានឹងបាត់បង់រយៈពេល 12 ខែ	រំពឹងថានឹងបាត់បង់ពេញអាយុកាល	រំពឹងថានឹងបាត់បង់ពេញអាយុកាល
លក្ខណៈវិនិច្ឆ័យ	មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ	ហានិភ័យឥណទានដែលបានកើនឡើងជាសារវន្ត	ឥណទានដែលមានឱនភាព
មូលដ្ឋាននៃការគណនាចំណូលជាប្រាក់ចំណេញ	តម្លៃយោងដុល	តម្លៃយោងដុល	តម្លៃយោងដុល

ធនាគារនឹងវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន ដោយប្រើវិធីសាស្ត្រទូទៅ ។ វិធីសាស្ត្រទូទៅរួមមាន ការញែកអតិថិជនចេញជា 3 ដំណាក់កាលផ្សេងៗ គ្នា ដោយយោងទៅតាមលក្ខណៈវិនិច្ឆ័យដំណាក់កាល ដោយធ្វើការវាយតម្លៃហានិភ័យឥណទាន។ លើការរំពឹងទុកលើការខាតបង់ឥណទាន រយៈពេល 12 ខែ នឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី 1 ខណៈការរំពឹងទុកលើការខាតបង់ឥណទានពេញអាយុកាលនឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី 2 និងដំណាក់កាលទី 3 ។ នាការិយបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារនឹងវាយតម្លៃហានិភ័យឥណទានទៅតាមគណនីនីមួយៗ បើប្រៀបធៀបនឹងកម្រិតហានិភ័យនៅពេលផ្តល់ឲ្យ។

ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)

ដំណាក់កាល	ស្ថានភាពហានិភ័យឥណទាន	ចំណាត់ថ្នាក់	ចំនួនថ្ងៃហួសកាលកំណត់	សុចនាករណ៍នៃការយឺតយ៉ាវ
1	មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ	ឥណទានធម្មតា	0 ដល់ 30 ថ្ងៃ	ដំណើរការ
2	ហានិភ័យឥណទានបានកើនឡើងជាសារវន្ត	ឥណទានឃ្លាំមើល	30 ដល់ 90 ថ្ងៃ	ក្រោមដំណើរការ
3	ឥណទានមានឱនភាព	ឥណទានក្រោមស្តង់ដារ	90 ដល់ 180 ថ្ងៃ	មិនដំណើរការ
		ឥណទានជាប់សង្ស័យ	180 ដល់ 360 ថ្ងៃ	
		ឥណទានខាតបង់	លើសពី 360 ថ្ងៃ	

ឥណទានរយៈពេលខ្លី (1 ឆ្នាំ ឬតិចជាង)

ដំណាក់កាល	ស្ថានភាពហានិភ័យឥណទាន	ចំណាត់ថ្នាក់	ចំនួនថ្ងៃហួសកាលកំណត់	សុចនាករណ៍នៃការយឺតយ៉ាវ
1	មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ	ឥណទានធម្មតា	0 ដល់ 14 ថ្ងៃ	ដំណើរការ
2	ហានិភ័យឥណទានបានកើនឡើងជាសារវន្ត	ឥណទានឃ្លាំមើល	15 ដល់ 30 ថ្ងៃ	ក្រោមដំណើរការ
3	ឥណទានមានឱនភាព	ឥណទានក្រោមស្តង់ដារ	31 ដល់ 60 ថ្ងៃ	មិនដំណើរការ
		ឥណទានជាប់សង្ស័យ	61 ដល់ 90 ថ្ងៃ	
		ឥណទានខាតបង់	លើសពី 91 ថ្ងៃ	

ធនាគារនឹងប្រើប្រាស់ចំនួនថ្ងៃហួសកាលកំណត់សង និងចំណាត់ថ្នាក់របស់ធនាគារជាតិនៃកម្ពុជា សម្រាប់លក្ខណៈវិនិច្ឆ័យក្នុងការបែងចែកដំណាក់កាល ។ ដូចគ្នានេះផងដែរ ធនាគារនឹងបង្កើតការដាក់ពិន្ទុឥណទាន ឬធាតុដែលអាចប៉ាន់ស្មានបាននាពេលអនាគត នៅពេលមានព័ត៌មានកាន់តែងាយស្រួលរក ។ នៅពេលអនុវត្តប្រព័ន្ធដាក់ពិន្ទុឥណទាន កម្រិតហានិភ័យធ្លាក់ចុះទ្វេដង ឬច្រើនជាងនេះ បើប្រៀបធៀបទៅនឹងកម្រិតហានិភ័យនៅពេលផ្តល់ឲ្យ គណនីត្រូវចាត់ថ្នាក់នៅដំណាក់កាលទី 2។

សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានលក្ខណៈរយៈពេលខ្លី វិធីសាស្ត្រសាមញ្ញនឹងត្រូវបានអនុម័ត នៅពេលដែលវាមិនតម្រូវឲ្យមានលក្ខណៈវិនិច្ឆ័យជាំហានៗ។ នៅក្នុងករណីនេះវានឹងត្រូវបានបែងចែកជាឥណទានដំណើរការ (ដំណាក់កាលទី 1) ឬឥណទានមិនដំណើរការ។

តារាងខាងក្រោមសង្ខេបពីគុណភាពឥណទាននៃហិរញ្ញប្បទានដុលរបស់ធនាគារ ដោយយោងតាមចំណាត់ថ្នាក់ខាងលើ។

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019			
	ដំណាក់កាលទី 1	ដំណាក់កាលទី 2	ដំណាក់កាលទី 3	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនតាមរំលស់ថ្លៃដើម				
ឥណទានធម្មតា	67,770,609	-	-	67,770,609
ឥណទានឃ្លាំមើល	-	-	-	-
ឥណទានក្រោមស្តង់ដារ	-	-	-	-
ឥណទានជាប់សង្ស័យ	-	-	-	-
	67,770,609	-	-	67,770,609
សំវិធានធនខាតបង់	(59,583)			(59,583)
តម្លៃយោង	**67,711,026**	**-**	**-**	**67,711,026**
តម្លៃយោង (ពាន់រៀល - កំណត់សម្គាល់5)	**275,922,431**	**-**	**-**	**275,922,431**

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018			
	ដំណាក់កាលទី 1	ដំណាក់កាលទី 2	ដំណាក់កាលទី 3	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនតាមរំលស់ថ្លៃដើម				
ឥណទានធម្មតា	36,108,399	-	-	36,108,399
ឥណទានឃ្លាំមើល	-	-	-	-
ឥណទានក្រោមស្តង់ដារ	-	-	-	-
ឥណទានជាប់សង្ស័យ	-	-	-	-
	36,108,399	-	-	36,108,399
សំវិធានធនខាតបង់	(35,842)			(35,842)
តម្លៃយោង	**36,072,557**	**-**	**-**	**36,072,557**
តម្លៃយោង(ពាន់រៀល - កំណត់សម្គាល់5)	**144,939,534**	**-**	**-**	**144,939,534**

ការដាក់បញ្ចូលព័ត៌មានលើការប្រមើលអនាគត

ធនាគារដាក់បញ្ចូលព័ត៌មានលើការប្រមើលអនាគត ដោយការវាយតម្លៃទាំងលើថាតើ ហានិភ័យឥណទានរបស់ឧបករណ៍ហិរញ្ញវត្ថុបានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់ដំបូង និងការវាស់វែង ECL។

ព័ត៌មានខាងក្រៅដែលត្រូវបានពិចារណារួមមានទិន្នន័យសេដ្ឋកិច្ច និងការព្យាករណ៍ដែលបានបោះពុម្ពផ្សាយដោយស្ថាប័នរដ្ឋាភិបាល និងអាជ្ញាធររូបិយវត្ថុនៅក្នុងបណ្តាប្រទេសដែលធនាគារធ្វើប្រតិបត្តិការដែលមានអង្គការអន្តរជាតិធំៗ ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ និងវិស័យឯកជន និងការសិក្សារបស់អ្នកព្យាករណ៍ ។

ធនាគារបានកំណត់ និងចងក្រងឯកសារគន្លឹះនៃហានិភ័យឥណទាន និងឥណទានខាតបង់សម្រាប់ផលបត្រ ឧបករណ៍ហិរញ្ញវត្ថុ ស្របតាមប្រទេសនីមួយៗ ហើយប្រើការវិភាគទិន្នន័យប្រវត្តិសាស្ត្រ បានប៉ាន់ស្មានទំនាក់ទំនងរវាងអថេរម៉ាក្រូសេដ្ឋកិច្ច និងហានិភ័យឥណទាន និងឥណទានខាតបង់។

(v). គណនីកើតឡើងពីការរំពឹងទុកលើការខាតបង់ឥណទាន

សំវិធានធនលើការខាតបង់

តារាងខាងក្រោមបង្ហាញពីការផ្សៀងផ្ទាត់ លើសំវិធានធនខាតបង់តាមការចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុនាដើម និងចុងការិយបរិច្ឆេទ។

	2019			
	ដំណាក់កាលទី 1	ដំណាក់កាលទី 2	ដំណាក់កាលទី 3	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនតាមរំលស់ថ្លៃដើម				
នាថ្ងៃទី 1 ខែ មករា	35,842	-	-	35,842
ទ្រព្យសកម្មហិរញ្ញវត្ថុដំបូង ឬបានទិញថ្មី	23,741	-	-	23,741
នាថ្ងៃទី 31 ខែ ធ្នូ	59,583	-	-	59,583
នាថ្ងៃទី 31 ខែ ធ្នូ (ពាន់រៀល - កំណត់សម្គាល់5)	242,801	-	-	242,801

	2018			
	ដំណាក់កាលទី 1	ដំណាក់កាលទី 2	ដំណាក់កាលទី 3	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនតាមរំលស់ថ្លៃដើម				
នាថ្ងៃទី 1 ខែ មករា	-	-	-	-
ទ្រព្យសកម្មហិរញ្ញវត្ថុដំបូង ឬបានទិញថ្មី	35,842	-	-	35,842
នាថ្ងៃទី 31 ខែ ធ្នូ	35,842	-	-	35,842
នាថ្ងៃទី 31 ខែ ធ្នូ (ពាន់រៀល - កំណត់សម្គាល់5)	144,013	-	-	144,013

គ. ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារគឺជាហានិភ័យដែលមានការផ្លាស់ប្តូរតម្លៃទីផ្សារ - ឧទាហរណ៍ អត្រាការប្រាក់ អត្រាប្តូររូបិយប័ណ្ណបរទេស និងតម្លៃមូលធន - នឹងមានផលប៉ះពាល់ដល់ប្រាក់ចំណូលរបស់ធនាគារ ឬតម្លៃនៃការកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុ ។ គោលបំណងនៃការគ្រប់គ្រងហានិភ័យទីផ្សារ គឺដើម្បីគ្រប់គ្រង និងត្រួតពិនិត្យហានិភ័យទីផ្សារតាមប៉ារ៉ាម៉ែត្រដែលអាចទទួលយកបាន ខណៈពេលដែលមានការបង្កើននូវប្រសិទ្ធភាពក្នុងការទទួលបានចំណូលមកវិញ ។

(i). ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ សំដៅលើការខាតបង់នូវប្រាក់ចំណូលការប្រាក់សុទ្ធ ដោយសារតែការប្រែប្រួលនៃកម្រិតអត្រាការប្រាក់ និងការផ្លាស់ប្តូរនៅក្នុងសមាសភាពនៃទ្រព្យសកម្ម និងបំណុល ។ ហានិភ័យអត្រាការប្រាក់ ត្រូវបានចាត់ចែងតាមរយៈការត្រួតពិនិត្យយ៉ាងហ្មត់ចត់ លើចំណូលនៃការបណ្តាក់ទុន តម្លៃសមស្រប និងតម្លៃដើមនៃមូលនិធិ ។ សក្តានុពលនៃការធ្លាក់ចុះចំណូលការប្រាក់សុទ្ធ បណ្តាលមកពីការប្រែប្រួលអត្រាការប្រាក់ដែលខុសប្រក្រតី បានត្រួតពិនិត្យដោយធៀបទៅនឹងកម្រិតអាចទទួលយកបាននៃហានិភ័យ ។

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យអត្រាការប្រាក់របស់ធនាគារ ។ តារាងនេះចង្អុលបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុកំណត់ថ្លៃឡើងវិញ ឬមានកាលកំណត់ណាមួយណាដែលកើតឡើងមុន។

នាថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2019	**រហូតដល់** 1 **ខែ**	> 1 - 3 **ខែ**	> 3 – 6 **ខែ**	> 6 – 12 **ខែ**	> 1 - 5 **ឆ្នាំ**	**លើសពី** 5 **ឆ្នាំ**	**ពុំមាន ការប្រាក់**	**សរុប**	**អត្រា ការប្រាក់**
	ដុល្លារអាមេរិក	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	%
ទ្រព្យសកម្ម ហិរញ្ញវត្ថុ									
សាច់ប្រាក់ និងសាច់ប្រាក់សមមូល - ដុល	61,316,386	-	-	-	-	-	-	61,316,386	1%
ប្រាក់បញ្ញើនៅធនាគារនានា - ដុល	-	-	18,058,081	-	-	-	-	18,058,081	2%-4%
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	7,000,000	1,009,806	3,088,733	17,642,556	21,194,894	499,205	17,335,415	67,770,609	6%-12%
ការវិនិយោគផ្សេងៗ-ដុល	-	-	-	22,527,783	-	-	-	22,527,783	6%
	68,316,386	1,009,806	21,146,814	40,170,339	21,194,894	499,205	17,335,415	169,672,859	
បំណុលហិរញ្ញវត្ថុ									
ប្រាក់បញ្ញើរបស់អតិថិជន	42,323,165	15,862,964	731,068	12,073,953	1,685,623	-	47,238,097	119,914,870	2%-5.75%
ប្រាក់បញ្ញើរបស់ធនាគារនានា	-	-	-	-	-	-	321,843	321,843	-
បំណុលភតិសន្យា	-	-	-	155,138	1,566,332	-	-	1,721,470	6%
បំណុលផ្សេងៗ	513,885	-	-	-	-	-	-	513,885	-
	42,837,050	15,862,964	731,068	12,229,091	3,251,955	-	47,559,940	122,472,068	
សរុបគំលាតការប្រាក់	**25,479,336**	**(14,853,158)**	**20,415,746**	**27,941,248**	**17,942,939**	**499,205**	**(30,224,525)**	**47,200,791**	
(សមមូលពាន់រៀល - កំណត់សម្គាល់ 5**)**	**103,828,294**	**(60,526,619)**	**83,194,165**	**113,860,586**	**73,117,476**	**2,034,260**	**(123,164,939)**	**192,343,223**	

ការវិភាគនៃទំនាក់ទំនងអត្រាការប្រាក់ទៅនឹងទ្រព្យសកម្ម និងបំណុលរបស់ធនាគារបានបង្ហាញដូចខាងក្រោម៖

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	**រហូតដល់ 1 ខែ**	**> 1 - 3 ខែ**	**> 3 – 6 ខែ**	**> 6 – 12 ខែ**	**> 1 - 5 ឆ្នាំ**	**លើសពី 5 ឆ្នាំ**	**ពុំមានការប្រាក់**	**សរុប**	**អត្រាការប្រាក់**
	ដុល្លារអាមេរិក	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	%
ទ្រព្យសកម្មហិរញ្ញវត្ថុ									
សាច់ប្រាក់ និងសាច់ប្រាក់សមមូល - ដុល	22,202,346	-	-	-	-	-	-	22,202,346	1%
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - ដុល	-	-	-	15,076,899	21,031,500	-	-	36,108,399	6%-8%
ការវិនិយោគផ្សេងៗ - ដុល	22,578,250	-	-	-	-	-	-	22,578,250	6%
	44,780,596	-	-	15,076,899	21,031,500	-	-	80,888,995	
បំណុលហិរញ្ញវត្ថុ									
ប្រាក់បញ្ញើរបស់អតិថិជន	14,649,610	90,180	245,138	150,772	50,000	-	1,563,954	16,749,654	1%-6.5%
ប្រាក់បញ្ញើរបស់ធនាគារនានា	-	-	-	-	-	-	1,224,100	1,224,100	-
បំណុលភតិសន្យា	-	-	-	81,315	266,962	-	-	348,277	6%
បំណុលផ្សេងៗ	112,017	-	-	-	-	-	-	112,017	-
	14,761,627	90,180	245,138	232,087	316,962	-	2,788,054	18,434,048	
សរុបគំលាតការប្រាក់	**30,018,969**	**(90,180)**	**(245,138)**	**14,844,812**	**20,714,538**	**-**	**(2,788,054)**	**62,454,947**	
(សមមូលពាន់រៀល - កំណត់សម្គាល់ 5)	**120,616,217**	**(362,343)**	**(984,964)**	**59,646,454**	**83,231,014**	**-**	**(11,202,401)**	**250,943,977**	

(ii). ហានិភ័យរូបិយប័ណ្ណបរទេស

ហានិភ័យរូបិយប័ណ្ណ គឺជាហានិភ័យដែលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុមានការប្រែប្រួល បណ្តាលមកពីការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស។

ការប្រមូលផ្តុំហានិភ័យរូបិយប័ណ្ណ

ចំនួនទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ តាមប្រភេទនៃរូបិយប័ណ្ណមានដូចខាងក្រោម៖

	ប្រភេទនៃរូបិយប័ណ្ណ សមមូលដុល្លារអាមេរិក			
ថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2019	ពាន់រៀល	ដុល្លារអាមេរិក	ផ្សេងៗ	សរុប
ទ្រព្យសកម្មហិរញ្ញវត្ថុ				
សាច់ប្រាក់ និងសាច់ប្រាក់សមមូល- ដុល	80,801	61,102,037	133,548	61,316,386
ប្រាក់បញ្ញើជាមួយធនាគារនានា- ដុល	-	18,058,081	-	18,058,081
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន- ដុល	-	67,770,609	-	67,770,609
ការវិនិយោគផ្សេងៗ-ដុល	-	22,527,783	-	22,527,783
	80,801	169,458,510	133,548	169,672,859
បំណុលហិរញ្ញវត្ថុ				
ប្រាក់បញ្ញើរបស់អតិថិជន	37,488	119,877,382	-	119,914,870
ប្រាក់បញ្ញើរបស់ធនាគារនានា	-	321,843	-	321,843
បំណុលភតិសន្យា	-	1,721,470	-	1,721,470
បំណុលផ្សេងៗ	-	513,885	-	513,885
	37,488	122,434,580	-	122,472,068
ស្ថានភាពទ្រព្យសកម្មសុទ្ធ	43,313	47,023,930	133,548	47,200,791
(**សមមូលពាន់រៀល - កំណត់សម្គាល់** 5)	**176,500**	**191,622,515**	**544,208**	**192,343,223**

	ប្រភេទនៃរូបិយប័ណ្ណ សមមូលដុល្លារអាមេរិក		
ថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2018	ពាន់រៀល	ដុល្លារអាមេរិក	សរុប
ទ្រព្យសកម្មហិរញ្ញវត្ថុ			
សាច់ប្រាក់ និងសាច់ប្រាក់សមមូល- ដុល	16,978,098	5,224,248	22,202,346
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន- ដុល	-	36,108,399	36,108,399
ការវិនិយោគផ្សេងៗ-ដុល	-	22,578,250	22,578,250
	16,978,098	63,910,897	80,888,995

ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	ប្រភេទនៃរូបិយប័ណ្ណ សមមូលដុល្លារអាមេរិក		
	ពាន់រៀល	ដុល្លារអាមេរិក	សរុប
បំណុលហិរញ្ញវត្ថុ			
ប្រាក់បញ្ញើរបស់អតិថិជន	291	16,749,363	16,749,654
ប្រាក់បញ្ញើរបស់ធនាគារនានា	-	1,224,100	1,224,100
បំណុលភតិសន្យា	-	348,277	348,277
បំណុលផ្សេងៗ	-	112,017	112,017
	291	18,433,757	18,434,048
ស្ថានភាពទ្រព្យសកម្មសុទ្ធ	**16,977,807**	**45,477,140**	**62,454,947**
សមមូលពាន់រៀល (**កំណាត់សម្គាល់** 5)	**68,216,829**	**182,727,148**	**250,943,977**

ការវិភាគរំញោច

សន្មតថា ហានិភ័យអថេរផ្សេងទៀតនៅតែថេរជានិច្ច ការប្រែប្រួលនៃការប្តូររូបិយប័ណ្ណបរទេសសម្រាប់ ធនាគារនាកាលបរិច្ឆេទរាយការណ៍ត្រូវបានសង្ខេបដូចខាងក្រោម (ដោយបង្ហាញតែរូបិយប័ណ្ណដែលមានចំនួនច្រើនជាង 5% នៃស្ថានភាពដំបូងសុទ្ធ ត្រូវបានបង្ហាញជារូបិយប័ណ្ណជាក់លាក់របស់វានៅក្នុងតារាងខាងក្រោម ។ សម្រាប់រូបិយប័ណ្ណផ្សេងទៀត ការលាតត្រដាងទាំងនេះត្រូវបានដាក់ជាក្រុមផ្សេងៗ៖

	2019		2018	
	- 1% រំលស់ ដុល្លារអាមេរិក	+ 1% ការកើនឡើង ដុល្លារអាមេរិក	- 1% រំលស់ ដុល្លារអាមេរិក	+ 1% ការកើនឡើង ដុល្លារអាមេរិក
ពាន់រៀល	(449)	449	(169,778)	169,778
ផ្សេងៗ	(1,335)	1,335	-	-
	(1,784)	1,784	(169,778)	169,778
ពាន់រៀល – កំណាត់សម្គាល់ 5	**(7,270)**	**7,270**	**(682,168)**	**682,168**

ឃ. ហានិភ័យសាច់ប្រាក់ងាយស្រួល

"ហានិភ័យសាច់ប្រាក់ងាយស្រួល" គឺជាហានិភ័យដែលធនាគារនឹងជួបផលលំបាកក្នុងការបំពេញកាតព្វកិច្ច ពាក់ព័ន្ធនឹងបំណុលហិរញ្ញវត្ថុរបស់ខ្លួន ដែលត្រូវបានទូទាត់តាមរយៈជាសាច់ប្រាក់ ឬ ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត។ ហានិភ័យសាច់ប្រាក់ងាយស្រួល កើតឡើងពីភាពមិនស៊ីគ្នាទៅនឹងពេលវេលា និងចំនួនលំហូរទឹកប្រាក់ដែលមាននៅក្នុងប្រតិបត្តិការ និងការវិនិយោគរបស់ធនាគារ ។

ការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល

ធនាគារ គ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ខ្លួនតាមរយៈគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម បំណុល ដែលទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយសាច់ប្រាក់ងាយស្រួល និងត្រួតពិនិត្យសាច់ប្រាក់ងាយស្រួលជាប្រចាំ ។ តម្រូវការទ្រព្យសកម្មងាយស្រួលអប្បបរមាត្រូវបានបង្កើតឡើងដើម្បីធានាថាអនុបាតនៃទ្រព្យសកម្មងាយស្រួល និងបំណុលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវទទួលបានកម្រិតអប្បបរមាគ្រប់ពេលវេលា។

តារាងខាងក្រោមសង្ខេបពីទ្រព្យសកម្ម និងបំណុលរបស់ធនាគារ ដោយផ្អែកលើកាលកំណត់កិច្ចសន្យាដែលនៅសល់។ លំហូរទឹកប្រាក់ដែលបានរំពឹងទុកលើទ្រព្យសកម្ម និងបំណុលទាំងនេះ អាចខុសជាសារវន្តពីអ្វីដែលបានបង្ហាញនៅក្នុងតារាង ។ ឧទាហរណ៍ ប្រាក់បញ្ញើរបស់អតិថិជនមិនត្រូវបានរំពឹងថានឹងត្រូវដកបានភ្លាមៗ នោះទេ។

នាថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2019	**រហូតដល់** 1 **ខែ**	> 1 - 3 **ខែ**	> 3 – 6 **ខែ**	> 6 – 12 **ខែ**	> 1 - 5 **ឆ្នាំ**	**លើសពី** 5 **ឆ្នាំ**	**ពុំមាន ការប្រាក់**	**សរុប**
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
បំណុលហិរញ្ញវត្ថុ								
ប្រាក់បញ្ញើរបស់អតិថិជន	42,323,165	15,862,964	731,068	12,073,953	1,685,623	-	47,238,097	119,914,870
ប្រាក់បញ្ញើរបស់ធនាគារនានា	-	-	-	-	-	-	321,843	321,843
បំណុលភតិសន្យា-មិនអប្បហា	18,333	42,902	64,353	128,705	2,218,545	-	-	2,472,838
បំណុលផ្សេងៗ	-	-	-	-	-	-	513,885	513,885
	42,341,498	15,905,866	795,421	12,202,658	3,904,168	-	48,073,825	123,223,436
(សមមូលពាន់រៀល - កំណត់សម្គាល់ 5 **)**	**172,541,604**	**64,816,404**	**3,241,341**	**49,725,831**	**15,909,485**	**-**	**195,900,837**	**502,135,502**

នាថ្ងៃទី 31 **ខែ ធ្នូ ឆ្នាំ** 2018	**រហូតដល់** 1 **ខែ**	> 1 - 3 **ខែ**	> 3 – 6 **ខែ**	> 6 – 12 **ខែ**	> 1 - 5 **ឆ្នាំ**	**លើសពី** 5 **ឆ្នាំ**	**ពុំមាន ការប្រាក់**	**សរុប**
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
បំណុលហិរញ្ញវត្ថុ								
ប្រាក់បញ្ញើរបស់អតិថិជន	14,649,610	90,180	245,138	150,772	50,000	-	1,563,954	16,749,654
ប្រាក់បញ្ញើរបស់ធនាគារនានា	-	-	-	-	-	-	1,224,100	1,224,100
បំណុលភតិសន្យា-មិនអប្បហា	8,333	16,667	25,000	50,000	291,667	-	-	391,667
បំណុលផ្សេងៗ	-	-	-	-	-	-	112,017	112,017
	14,657,943	106,847	270,138	200,772	341,667	-	2,900,071	18,577,438
(សមមូលពាន់រៀល - កំណត់សម្គាល់ 5 **)**	**58,895,616**	**429,311**	**1,085,414**	**806,702**	**1,372,818**	**-**	**11,652,485**	**74,242,346**

ង. ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺជាហានិភ័យនៃការបាត់បង់ផ្ទាល់ ឬប្រយោលដែលកើតមានឡើងពីការខ្វះខាត ឬ ការអនុវត្តមិនមានប្រសិទ្ធភាពនូវនីតិវិធីដំណើរការផ្ទៃក្នុង បុគ្គលិក ឬប្រព័ន្ធ ឬពីកត្តាខាងក្រៅ។ ហានិភ័យនេះ ត្រូវបានគ្រប់គ្រងតាមរយៈការបង្កើតប្រព័ន្ធដំណើរការគ្រប់គ្រងប្រតិបត្តិការ ការត្រួតពិនិត្យ និងការរាយការណ៍ឲ្យបានត្រឹមត្រូវពីសកម្មភាពអាជីវកម្ម តាមរយៈអង្គភាពគ្រប់គ្រង និងគាំទ្រដែលឯករាជ្យពីអង្គភាពអាជីវកម្ម និងគណៈគ្រប់គ្រង។ ទាំងនេះរួមមាន ហានិភ័យខាងផ្នែកច្បាប់ អនុលោមភាពតាមគណនេយ្យ និងការក្លែងបន្លំ ។

ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការរបស់ធនាគារ តម្រូវឲ្យបង្កើតនូវរចនាសម្ព័ន្ធតួនាទី និងវិធីសាស្ត្រនៃការគ្រប់គ្រងរបស់អង្គភាពឲ្យបានច្បាស់លាស់។ គោលការណ៍ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងជាច្រើន ត្រូវបានអនុវត្ត រួមមានការបង្កើតអ្នកមានសិទ្ធិចុះហត្ថលេខា ប្រព័ន្ធត្រួតពិនិត្យយ៉ាងហ្មត់ចត់ ការរៀបចំនូវនីតិវិធី និងឯកសារសំអាងនានា ព្រមទាំងការអនុវត្តតាមបទប្បញ្ញត្តិ និងតម្រូវការតាមច្បាប់នានា។ ដំណើរការទាំងនេះត្រូវបានត្រួតពិនិត្យជាប្រចាំឆ្នាំ ដើម្បីឆ្លើយតបទៅនឹងហានិភ័យប្រតិបត្តិការ ដែលអាចកើតឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។

ច. ការគ្រប់គ្រងដើមទុន

(i). បទប្បញ្ញត្តិដើមទុន

គោលដៅរបស់ធនាគារក្នុងការគ្រប់គ្រងដើមទុន មានន័យទូលំទូលាយជាង "មូលធន" ដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ការគ្រប់គ្រងដើមទុនមានដូចខាងក្រោម៖

- អនុលោមតាមតម្រូវការដើមទុនដែលកំណត់ដោយធនាគារជាតិ
- ការពារលទ្ធភាពរបស់ធនាគារដើម្បីបន្តនិរន្តរ៍ភាពអាជីវកម្ម ដូចនេះ ធនាគារអាចបន្តផ្តល់ផលប្រយោជន៍ដល់ភាគទុនិក និងអត្ថប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនឹងធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍អាជីវកម្ម ។

គោលនយោបាយរបស់ធនាគារ គឺធានាឲ្យបាននូវមូលដ្ឋានដើមទុនរឹងមាំដើម្បីរក្សានូវទំនុកចិត្តទីផ្សារ និងដើម្បីធានាស្ថេរភាពនៃការអភិវឌ្ឍន៍យូរអង្វែងរបស់អាជីវកម្ម ។ ផលប៉ះពាល់ទៅលើកម្រិតដើមទុនលើភាគលាភរបស់ភាគទុនិក ក៏ត្រូវបានទទួលស្គាល់ ហើយធនាគារបានទទួលស្គាល់នូវតម្រូវការ ដើម្បីធានាបាននូវតុល្យភាពរវាងភាគលាភខ្ពស់ដែលអាចនឹងកើតមានឡើងជាមួយនឹងប្រាក់បម្រុងកម្រិតខ្ពស់អត្ថប្រយោជន៍ និងការធានាដែលផ្តល់ដោយស្ថានភាពដើមទុនល្អ ។

(ii). ការបែងចែកដើមទុន

ការបែងចែកដើមទុនរវាងប្រតិបត្តិការ និងសកម្មភាពជាក់លាក់ គឺត្រូវបានគ្រប់គ្រងដោយកម្រិតភាគលាភដែលទទួលបានពីការបែងចែកនោះ។ ដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាព នីមួយៗ ត្រូវផ្អែកទៅតាមដើមទុនដែលកំណត់ដោយច្បាប់។

31. តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុរួមមានទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការ ។ តម្លៃសមស្រប គឺជាថ្លៃដែលត្រូវទទួលដើម្បីលក់ទ្រព្យសកម្ម ឬបានទូទាត់ ដើម្បីផ្ទេរបំណុលទៅតាមលំដាប់លំដោយនៅក្នុងប្រតិបត្តិការ រវាងអ្នកចូលរួមក្នុងទីផ្សារនៅកាលបរិច្ឆេទនៃការវាស់វែងចម្បង ឬប្រសិនអវត្តមានទីផ្សារដែលមានការរីកចម្រើនបំផុតដែលធនាគារបានទទួលនៅកាលបរិច្ឆេទនោះ ។ ព័ត៌មានដែលបានបង្ហាញនៅទីនេះ តំណាងឱ្យការប៉ាន់ស្មាននៃតម្លៃសមស្របនាកាលបរិច្ឆេទរាយការណ៍នៃស្ថានភាពហិរញ្ញវត្ថុ ។

តម្លៃទីផ្សារដែលបានដកស្រង់ និងអាចអង្កេតបាន ហើយអាចរកបាន ត្រូវបានប្រើសម្រាប់វាស់វែងលើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ ។ នៅពេលដែលតម្លៃទីផ្សារដែលបានដកស្រង់ និងអាចសង្កេតបាន មិនអាចប្រើប្រាស់បាន នោះតម្លៃសមស្របត្រូវបានប៉ាន់ស្មានដោយផ្អែកលើវិធីសាស្ត្រ និងការសន្មតជាច្រើនទាក់ទងទៅនឹងលក្ខណៈហានិភ័យនៃឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ ដែលមានអត្រាអប្បហារ ការប៉ាន់ស្មាននៃលំហូរទឹកប្រាក់នាពេលអនាគត និងកត្តាផ្សេងៗទៀត ។

ព័ត៌មាននៃតម្លៃសមស្របសម្រាប់ទ្រព្យសកម្ម និងបំណុលមិនមែនហិរញ្ញវត្ថុ មិនត្រូវបានរាប់បញ្ចូលទេ ពីព្រោះវាមិនស្ថិតក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក 7 ៖ ការបង្ហាញឧបករណ៍ហិរញ្ញវត្ថុដែលទាមទារឱ្យមានការបង្ហាញព័ត៌មាននៃតម្លៃសមស្រប ។ នេះរួមបញ្ចូលទាំងការវិនិយោគទ្រព្យ និងបរិក្ខារ ។

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានដូចជាសាច់ប្រាក់ និងមូលនិធិរយៈពេលខ្លី នៅធនាគារជាតិ និងប្រាក់បញ្ញើជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារនានា ទ្រព្យសកម្មផ្សេងៗ បំណុលផ្សេងៗ និងប្រាក់កម្ចីរយៈពេលខ្លីមិនមានលក្ខណៈជាសារវន្ត ចំពោះការផ្លាស់ប្តូរ អត្រាប្រាក់ចំណេញក្នុងទីផ្សារ ដោយសារតែឧបករណ៍ហិរញ្ញវត្ថុទាំងនេះមានរយៈពេលកំណត់ជាក់លាក់។ តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុទាំងនេះនៅកាលបរិច្ឆេទរាយការណ៍មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា។

តម្លៃសមស្របគឺផ្អែកលើវិធីសាស្ត្រ និងការសន្មតដូចខាងក្រោម៖

(i). សាច់ប្រាក់នៅក្នុងធនាគារ

តម្លៃសមស្របនៃសមតុល្យជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានាមានកាលកំណត់តិចជាងមួយឆ្នាំមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា។

(ii). ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន និងការវិនិយោគផ្សេងៗ

សម្រាប់កម្ចីមានអត្រាថេរជាមួយ នឹងការិយបរិច្ឆេទនៅសល់រហូតដល់មានកាលកំណត់តិចជាងមួយឆ្នាំ ចំណែកតម្លៃយោងជាទូទៅគឺត្រូវធ្វើការការប៉ាន់ស្មានត្រឹមត្រូវ នឹងតម្លៃសមស្របរបស់វា។

សម្រាប់កម្ចីមានអត្រាថេរ នឹងការវិនិយោគផ្សេងៗ ជាមួយនិងការិយបរិច្ឆេទនៅសល់រហូតដល់មានកាលកំណត់ពីមួយនិងលើសមួយឆ្នាំ តម្លៃសមស្រប គឺត្រូវធ្វើបច្ចុប្បន្នកម្មទៅលើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគតដោយប្រើអត្រាទីផ្សារនៃការផ្តល់កម្ចីដែលមានហានិភ័យ ឥណទាន និងកាលកំណត់ស្រដៀងគ្នា។

(iii). ប្រាក់បញ្ញើរបស់ធនាគារនានា និងអតិថិជន

តម្លៃសមស្របនៃប្រាក់បញ្ញើត្រូវបង់តាមតម្រូវការ(គណនីចរន្តរយៈពេលខ្លី និងគណនីសន្សំ) ឬប្រាក់បញ្ញើដែលមានកាលកំណត់សងតិចជាងមួយឆ្នាំគឺនឹងត្រូវប៉ាន់ស្មានយកតម្លៃយោងប្រហាក់ប្រហែល ។ រីឯ តម្លៃសមស្របនៃប្រាក់បញ្ញើ ដែលមានកាលកំណត់សងច្រើនជាងមួយឆ្នាំគឺ នឹងត្រូវប៉ាន់ស្មានយកតម្លៃតាមការធ្វើអប្បហារលើលំហូរទឹកប្រាក់ដោយប្រើអត្រាទីផ្សារនៃប្រាក់បញ្ញើពីធនាគារនិងអតិថិជនដែលស្រដៀងគ្នា។

(iv). ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុផ្សេងៗ

តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានសន្មត់នូវតម្លៃប្រហាក់ប្រហែលទៅនឹងតម្លៃសមស្របដែលកម្មវត្ថុទាំងនេះមិនងាយនឹងផ្លាស់ប្តូរទៅតាមអត្រាការប្រាក់ទីផ្សារ។

ចំណាត់ថ្នាក់តម្លៃសមស្រប

ស.រ.ហ.អ.ក 7 បញ្ជាក់ពីចំណាត់ថ្នាក់នៃបច្ចេកទេសវាយតម្លៃដោយផ្អែកលើ ថាតើទិន្នន័យនៃបច្ចេកទេសវាយតម្លៃទាំងនោះអាចអង្កេតបាន ឬមិនអាចអង្កេតបាន។ ទិន្នន័យដែលអាចអង្កេតបាន ឆ្លុះបញ្ចាំងពីទិន្នន័យទីផ្សារដែលទទួលបានពីប្រភពឯករាជ្យ និងទិន្នន័យដែលមិនអាចអង្កេតបាន ឆ្លុះបញ្ចាំងពីការសន្មតទីផ្សាររបស់ធនាគារ ។ ចំណាត់ថ្នាក់នៃតម្លៃសមស្របមានដូចខាងក្រោម:

- កម្រិត 1 - តម្លៃដកស្រង់ (មិនបានធ្វើនិយ័តភាព) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម ឬបំណុលដូចគ្នា។ កម្រិតនេះរាប់បញ្ចូលទាំងមូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជី និងឧបករណ៍បំណុល ។
- កម្រិត 2 - ទិន្នន័យក្រៅពីតម្លៃដែលបានដកស្រង់រាប់បញ្ចូលក្នុងកម្រិត 1 ដែលអាចអង្កេតបានចំពោះទ្រព្យសកម្ម ឬបំណុល ដោយផ្ទាល់ (ឧទាហរណ៍ តម្លៃ) ឬដោយប្រយោល (ឧទាហរណ៍ កើតចេញពីតម្លៃ)។
- កម្រិត 3 - ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន (ធាតុចូលដែលមិនអាចអង្កេតបាន)។ កម្រិតនេះរួមបញ្ចូលទាំងឧបករណ៍មូលធន និងឧបករណ៍បំណុល ដែលមានសមាសធាតុមិនអាចអង្កេតបានជាសារវន្ត ។

តម្លៃយោង និងតម្លៃសមស្រប នៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ ដែលចាត់ថ្នាក់ជាតម្លៃសមស្របកម្រិត 3មិនត្រូវបានវាស់វែងតាមតម្លៃសមស្របទេ ។ តម្លៃសមស្រប គឺជាតម្លៃដែលទ្រព្យសកម្មអាចប្តូរបាន ឬជាតម្លៃដែលបំណុលអាចសងបាន។ ដោយសារតម្លៃសមស្របពុំអាចវាយតម្លៃបាន ដូច្នេះតម្លៃសមស្របមិនមានសម្រាប់ទ្រព្យសកម្ម និងបំណុលមួយចំណែកធំរបស់ធនាគារឡើយ។ ដូច្នេះហើយ តម្លៃសមស្របត្រូវបានសន្មត់ដោយអ្នកគ្រប់គ្រងយោងតាមទម្រង់នៃទ្រព្យសកម្ម និងបំណុលទាំងនោះ។ តាមមតិរបស់អ្នកគ្រប់គ្រង តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលបង្ហាញក្នុងតារាងតុល្យការ គឺជាតម្លៃប៉ាន់ស្មានដ៏សមហេតុផលសម្រាប់តម្លៃសមស្រប។

32. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានបង្ហាញនៅខាងក្រោមនេះ ត្រូវបានអនុវត្តដោយសង្គតិភាពនៅគ្រប់កាលបរិច្ឆេទដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ហើយនៅក្នុងការរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុតាម ស.រ.ទ.ហ.អ.ក ដំបូង នៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ក្នុងគោលបំណងផ្លាស់ប្តូរ លើកលែងតែមានការបង្ហាញផ្សេងពីនេះ ។

ក. មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើមដំបូង ។

ខ. រូបិយប័ណ្ណបរទេស

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅជារូបិយប័ណ្ណ ដែលជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។

ទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុ ដែលជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទរាយការណ៍។ ការចំណេញ ឬការខាតបង់ពីការប្តូររូបិយប័ណ្ណបរទេស គឺជាភាពខុសគ្នារវាងថ្លៃដើមដែលត្រូវបានរំលស់ជាដុល្លារអាមេរិកនៅដើមឆ្នាំ ដែលត្រូវបានធ្វើនិយ័តកម្មសម្រាប់ អត្រាប្តូរប្រាក់ប្រសិទ្ធិភាព និងការទូទាត់ក្នុងឆ្នាំ ហើយនិងរំលស់ថ្លៃដើមជារូបិយប័ណ្ណបរទេសដែលបានប្តូរដោយប្រើអត្រាប្តូរប្រាក់នៅចុងឆ្នាំ។

ទ្រព្យសកម្ម និងបំណុលដែលមិនមែនជារូបិយវត្ថុ ដែលត្រូវបានវាស់វែងតាមតម្លៃសមស្របជារូបិយប័ណ្ណបរទេសត្រូវបានប្តូរទៅជាដុល្លារអាមេរិក នៅអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទដែលតម្លៃត្រូវបានកំណត់ ។ ធាតុមិនមែនរូបិយវត្ថុ ដែលត្រូវបានវាស់វែងផ្អែកលើតម្លៃប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេសត្រូវបានប្តូរដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការនីមួយៗ។

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

(i). ការទទួលស្គាល់ និងការវាស់វែងដំបូង

ធនាគារទទួលស្គាល់ជាលើកដំបូងនូវឥណទាន ប្រាក់កម្ចី និងបុរេប្រទាននៅកាលបរិច្ឆេទដែលកើតមានប្រតិបត្តិការ ។ ទ្រព្យហិរញ្ញវត្ថុផ្សេងទៀតទទួលស្គាល់នៅកាលបរិច្ឆេទ ដែលធនាគារក្លាយជាភាគីកិច្ចសន្យា។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប (សម្រាប់ឧបករណ៍ដែលមិនមែនវាស់វែងតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL")) បូកនឹងថ្លៃដើមប្រតិបត្តិការ ដែលកើតមកពីការទិញ ឬលក់ ទ្រព្យ និងបំណុលទាំងនោះ។

(ii). ការចាត់ចំណាត់ថ្នាក់ និងការវាស់វែងបន្ទាប់

ទ្រព្យសកម្មហិរញ្ញវត្ថុ-ការចាត់ចំណាត់ថ្នាក់

នៅក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមការវាស់វែង: រំលស់ថ្លៃដើម FVOCI ឬ FVTPL ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ប្រសិនបើវាបំពេញទៅនឹងលក្ខខណ្ឌដូចខាងក្រោមហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរទឹកប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") ។

ឧបករណ៍បំណុល ត្រូវបានវាស់វែងនៅ FVOCI លុះត្រាតែវាបានបំពេញនឹងលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ ចំពោះលំហូរទឹកប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើមនិងការប្រាក់ ("SPPI") ។

សម្រាប់ការទទួលស្គាល់ការវិនិយោគលើមូលធនជាលើកដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ជួញដូរ សាធនាគារត្រូវតែជ្រើសរើសការបង្ហាញការប្រែប្រួលនាពេលបន្ទាប់តាមរយៈលទ្ធផលលម្អិតផ្សេងៗ ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកលើការវិនិយោគនីមួយៗ។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងទៀតត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL

លើសពីនេះ សម្រាប់ការទទួលស្គាល់ជាលើកដំបូង ធនាគារអាចនឹងកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបំពេញតាមលក្ខខណ្ឌក្នុងការវាស់វែងតាមរំលស់ថ្លៃដើម ឬតាម FVOCI ប្រសិនបើវាស់វែងតាម FVTPL នឹងលុបបំបាត់ ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតឡើង ។

ទ្រព្យសកម្មហិរញ្ញវត្ថុ - ការវាយតម្លៃគំរូអាជីវកម្ម

ធនាគារ ធ្វើការវាយតម្លៃអំពីគោលបំណងនៃគំរូអាជីវកម្ម លើទ្រព្យសកម្មក្នុងកម្រិតសំណុំឥណទាននីមួយៗ ព្រោះគំរូនេះបង្ហាញយ៉ាងច្បាស់ពីវិធីគ្រប់គ្រងអាជីវកម្ម និងវិធីផ្តល់ព័ត៌មានទៅអ្នកគ្រប់គ្រង ។ ព័ត៌មានទាំងនោះរួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានបញ្ជាក់សម្រាប់សំណុំឥណទាន និងអនុវត្តនូវគោលនយោបាយទាំងនោះ ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់អ្នកគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា រក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឲ្យស៊ីសង្វាក់គ្នារវាង រយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ទៅនឹងរយៈពេលនៃបំណុល ដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឲ្យមានលំហូរទឹកប្រាក់តាមរយៈការលក់ទ្រព្យសកម្ម ។
- វិធីក្នុងការវាយតម្លៃលទ្ធផលនៃសំណុំឥណទាន និងវិធីរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់ធនាគារ
- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលនៃគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់សំណងផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណ និងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់នោះ និងការរំពឹងទុកអំពីសកម្មភាពលក់នាពេលអនាគត ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានចាត់ទុកថាដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទូទៅអំពីរបៀបដែលធ្វើឲ្យសម្រេចបាននូវគោលបំណងក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារ ។

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់ការជួញដូរ ឬចាត់ចែង ហើយដែលលទ្ធផលត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនសម្រាប់ទាំងការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ឡើយ។

ទ្រព្យសកម្មហិរញ្ញវត្ថុ - ការវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" គឺជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់ជាលើកដំបូង ។ "ការប្រាក់" គឺជាតម្លៃតបស្នងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ សម្រាប់រយៈពេលណាមួយ និងសម្រាប់ហានិភ័យដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើមនៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ការចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសាច់ប្រាក់ងាយស្រួល និងចំណាយរដ្ឋបាល) រួមទាំងប្រាក់ចំណេញ។

ដើម្បីវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ ធនាគារ ត្រូវពិចារណាលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ រួមបញ្ចូលការវាយតម្លៃថាតើ ទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរទឹកប្រាក់តាមកិច្ចសន្យា ដែលអាចធ្វើឲ្យខុសពីលក្ខខណ្ឌនៃការទូទាត់ប្រាក់ដើម និងការប្រាក់។

ក្នុងការវាយតម្លៃ ធនាគារពិចារណាលើ៖

- ព្រឹត្តិការណ៍ជាយថាភាពដែលអាចផ្លាស់ប្តូរចំនួន និងរយៈពេលនៃលំហូរទឹកប្រាក់
- លក្ខខណ្ឌពិសេស
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យាពេលសង
- លក្ខខណ្ឌដែលកម្រិតធនាគារ ក្នុងការទាមទារមកវិញនូវសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជា ឥណទានដែលមិនអាចប្រមូលមកវិញបាន) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីតម្លៃប្រាក់តាមពេលវេលា (ឧទាហរណ៍ ការកំណត់អត្រាការប្រាក់ឡើងវិញតាមកាលកំណត់) ។

ទ្រព្យសកម្មហិរញ្ញវត្ថុ-ឥណទានដែលមិនអាចប្រមូលមកវិញបាន

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយធនាគារ ដែលត្រូវបានការពារដោយទ្រព្យដាក់ធានារបស់អតិថិជនក៏មានកំហិតធនាគារក្នុងការ ទាមទារសាច់ប្រាក់មកវិញដែរ (ឥណទានដែលមិនអាចប្រមូលមកវិញបាន)។ ក្នុងករណីនេះ ធនាគារធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើឥណទាននោះអាចប្រមូលមកវិញបានតែប្រាក់ដើម និងការប្រាក់ឬទេ ។ ជាទូទៅធនាគារពិចារណាលើព័ត៌មានខាងក្រោមក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃការបង់សងកម្ចីដែរ ឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា
- សមត្ថភាព និងឆន្ទៈរបស់អតិថិជន ក្នុងការទូទាត់សងតាមកិច្ចសន្យា ទោះបីមានឱនភាពនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ
- ថាតើអតិថិជនគឺជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណងពិសេស
- ហានិភ័យរបស់ធនាគារក្នុងការបាត់បង់ទ្រព្យសកម្ម ទាក់ទងនឹងឥណទានដែលមិនអាចប្រមូលមកវិញបាន
- ថាតើទ្រព្យដាក់ធានាគឺជាទ្រព្យទាំងអស់ដែលអតិថិជនមាន ឬជាផ្នែកមួយនៃទ្រព្យសកម្មផ្សេងៗទៀតរបស់អតិថិជន និង
- ថាតើធនាគារទទួលបានអត្ថប្រយោជន៍ពីទ្រព្យសកម្មនេះ ឬទេ។

ទ្រព្យសកម្មហិរញ្ញវត្ថុ - ការចាត់ចំណាត់ថ្នាក់ឡើងវិញ

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ បន្ទាប់ពីការទទួលស្គាល់តម្លៃដំបូងឡើយ លើកលែង តែក្នុងអំឡុងពេលដែលធនាគារផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

បំណុលហិរញ្ញវត្ថុ – ការចាត់ថ្នាក់ ការវាស់វែងបន្ទាប់ និងចំណេញ និងខាត

ធនាគារចាត់ថ្នាក់បំណុលហិរញ្ញវត្ថុរបស់ខ្លួនដូចបានវាស់វែងតាមរំលស់ថ្លៃដើម ឬ FVTPL ។ បំណុលហិរញ្ញវត្ថុ ត្រូវបានចាត់ថ្នាក់តាម FVTPL ប្រសិនបើត្រូវចាត់ថ្នាក់សម្រាប់ការជួញដូរ ជានិស្សន្ទ ឬបំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានចាត់ថ្នាក់ដំបូងតាមតម្លៃសមស្រប ។ បំណុលហិរញ្ញវត្ថុតាម FVTPL ត្រូវបានវាស់វែងតាមតម្លៃសមស្រប ហើយចំណេញ ឬខាតសុទ្ធរួមទាំងការប្រាក់ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង បំណុលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ ចំណាយការប្រាក់ ប្រាក់ចំណេញ និងខាតលើការប្តូរប្រាក់បរទេស ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត។ ប្រាក់ចំណេញ ឬខាតណាមួយលើការឈប់ទទួលស្គាល់ ត្រូវបានទទួលស្គាល់ផងដែរនៅក្នុងប្រាក់ចំណេញ ឬខាត។

(iii). ការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុ

ធនាគារឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬការផ្ទេរសិទ្ធិទទួលលំហូរទឹកប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលហានិភ័យទាំងអស់ និងភាពជាកម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាកម្មសិទ្ធិ ហើយវាមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ។

ចំពោះការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i). តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលទទួលយក) និង (ii). ចំណេញ ឬខាតដែលបានទទួលស្គាល់ក្នុង OCI ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត។

បំណុលហិរញ្ញវត្ថុ

ធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតអាណត្តិ ។

(iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះធនាគារវាយតម្លៃថាតើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែនោះមានភាពខុសគ្នាខ្លាំង ឬទេ ។

ប្រសិនបើលំហូរទឹកប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរទឹកប្រាក់ពីទ្រព្យសកម្ម ហិរញ្ញវត្ថុដើម ត្រូវបានចាត់ទុកថាផុតអាណត្តិ ។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវឈប់ទទួលស្គាល់ (សូមមើល(iii)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្របបូកនឹងថ្លៃចំណាយប្រតិបត្តិការ ។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានរាប់បញ្ចូលដូចខាងក្រោម៖

- ថ្លៃសេវា ដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែល ទទួលបានមកវិញលើថ្លៃចំណាយប្រតិបត្តិការ ដែលកើតឡើង ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម និង
- ថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងចំណេញ និងខាត ដែលជាផ្នែកមួយនៃការចំណេញ ឬខាតលើទ្រព្យសកម្មដែលឈប់ទទួលស្គាល់។
- ប្រសិនបើលំហូរទឹកប្រាក់ត្រូវបានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញជាអតិបរមាលើលក្ខខណ្ឌនៃកិច្ចសន្យាដើម ជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង ។ ប្រសិនបើធនាគារមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំឲ្យមានការលើកលែងចំពោះលំហូរទឹកប្រាក់ ទ្រព្យសកម្ម នោះ ត្រូវបានយកមកពិចារណាជាមុន ថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជីមុនពេលធ្វើការកែប្រែ ឬទេ (សូមមើលខាងក្រោមសម្រាប់គោលនយោបាយ ការលុបចេញពីបញ្ជី) ។ វិធីសាស្ត្រនេះជះ ឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃបរិមាណ ហើយក្នុងករណីនេះមានន័យថាលក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ទ្រព្យ ជាទូទៅមិនអាចអនុវត្តបាននោះទេ។
- ប្រសិនបើការកែតម្រូវទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ឬ FVOCI មិនបណ្តាលឲ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេនោះ នោះធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវ ជាចំណេញ ឬខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាថេរអត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបាន ដែលជាផ្នែកមួយនៃការកែតម្រូវទាក់ទងនឹងតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានធ្វើការកែតម្រូវ ត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់ នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវនោះ។
- ប្រសិនបើការកែតម្រូវនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពនៃតម្លៃ នៃទ្រព្យសកម្ម ។ ក្នុងករណីផ្សេងទៀត វាត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព ។

បំណុលហិរញ្ញវត្ថុ

ធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែតម្រូវ ហើយលំហូរទឹកប្រាក់នៃបំណុលដែលបានកែតម្រូវនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលមិនត្រូវបានទទួលស្គាល់ និងតម្លៃតបស្នង ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត។ តម្លៃតបស្នងរួមមានទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុលរួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវថ្មី។

ប្រសិនបើការកែតម្រូវបំណុលហិរញ្ញវត្ថុនេះមិនធ្វើឲ្យមានការឈប់ទទួលស្គាល់ទេ នោះរំលស់ថ្លៃដើមនៃ បំណុល ត្រូវគណនាឡើងវិញដោយធ្វើអប្បហារលំហូរទឹកប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលនៃការចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត ។ សម្រាប់បំណុលហិរញ្ញវត្ថុមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ ។ រាល់ការចំណាយ និងថ្លៃសេវាដែលកើតមានត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុលនិងរំលស់តាមរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវដោយគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញលើឧបករណ៍ហិរញ្ញវត្ថុ។

(v). ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចត្រូវកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែធនាគារមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

(vi). ការវាស់វែងតម្លៃសមស្រប

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតារវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលធនាគារអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យការមិនអនុវត្តកាតព្វកិច្ច។

ធនាគារវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន ។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់ ។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះធនាគារត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន ។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឲ្យ ឬបានទទួល ។ ប្រសិនបើធនាគារកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដែលក្នុងនោះទិន្នន័យដែលមិនអាចអង្កេតបានពាក់ព័ន្ធនឹងការវាស់វែង ត្រូវបានសន្មតថាមិនសារវន្ត ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ ។ បន្ទាប់មកទៀត ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត ផ្អែកលើអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឲ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ ។

ប្រសិនបើទ្រព្យសកម្ម ឬបំណុលដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប មានតម្លៃលក់ និងតម្លៃទិញនោះ ធនាគារវាស់វែងទ្រព្យសកម្មនិងស្ថានភាពវែងតាមតម្លៃលក់ ហើយវាស់វែងបំណុល និងស្ថានភាពខ្លីតាមតម្លៃទិញ ។

សំណុំទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលមានហានិភ័យទីផ្សារ និងហានិភ័យឥណទាន ដែលត្រូវបានចាត់ចែងដោយធនាគារតាមមូលដ្ឋានចំនួនសុទ្ធដែលមានហានិភ័យទីផ្សារ ឬហានិភ័យឥណទាន ត្រូវបានវាស់វែងតាមមូលដ្ឋាននៃតម្លៃ ដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្មដែលមាន ស្ថានភាពវែង (ឬការទូទាត់សងក្នុងការផ្ទេរទ្រព្យសកម្មសុទ្ធដែលមានស្ថានភាពខ្លី) សម្រាប់ហានិភ័យជាក់លាក់ ។ ការកែតម្រូវត្រឹមកម្រិតទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ មានន័យថា ការកែតម្រូវតម្លៃលក់-ទិញ ឬការកែតម្រូវហានិភ័យឥណទាន ដែលឆ្លុះបញ្ចាំងពីការវាស់វែងតាមមូលដ្ឋានតម្លៃសុទ្ធ គឺត្រូវបានបែងចែកតាមទ្រព្យសកម្ម និងបំណុលនីមួយៗ តាមមូលដ្ឋានការកែតម្រូវហានិភ័យដែលពាក់ព័ន្ធនៃឧបករណ៍ហិរញ្ញវត្ថុនីមួយៗ នៃទ្រព្យសកម្ម និងបំណុលនោះ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈអាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍ ប្រាក់បញ្ញើចរន្ត) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចត្រូវបានបង់ ។

ធនាគារទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទនៃរបាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង ។

(vii). ឱនភាពនៃតម្លៃ

ធនាគារទទួលស្គាល់សំវិធានធនលើការរំពឹងទុកលើការខាតបង់ឥណទាន ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាឧបករណ៍បំណុល និង
- កិច្ចសន្យាឥណទានដែលបានចោះផ្សាយ ។

ពុំមានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងការវិនិយោគមូលធនឡើយ ។

ធនាគារវាស់វែងសំវិធានធនលើការខាតបង់ តាមចំនួនដែលស្មើនឹងការរំពឹងទុកលើការខាតបង់ឥណទាន ពេញអាយុកាល លើកលែងគណនីខាងក្រោមដែលត្រូវវាស់វែងតាមការរំពឹងទុកលើការខាតបង់ឥណទានរយៈពេល 12 ខែ៖

- ការវិនិយោគលើមូលបត្របំណុល ដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាប នាកាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីភតិសន្យាត្រូវទទួល) ដែលហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ។

ការរំពឹងទុកលើការខាតបង់ឥណទាន 12 ខែ គឺជាផ្នែកនៃការរំពឹងទុកលើការខាតបង់ឥណទាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល 12 ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាមការរំពឹងទុកលើការខាតបង់ឥណទាន 12 ខែ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី1"។

ការរំពឹងទុកលើការខាតបង់ឥណទានមួយអាយុកាល (Life-time ECL) គឺជាការរំពឹងទុកលើការខាតបង់ឥណទាន ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ ក្នុងរយៈពេលនៃអាយុកាលរំពឹងទុក (expected life) នៃឧបករណ៍ហិរញ្ញវត្ថុ ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាមការរំពឹងទុកលើការខាតបង់ឥណទាន ពេញមួយអាយុកាល ប៉ុន្តែមិនមែនជាឥណទានដែលមានឱនភាពនៃតម្លៃ (credit-impaired) ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី 2" ។

នៅកាលបរិច្ឆេទនៃរបាយការណ៍ ធនាគារវាយតម្លៃថាតើហានិភ័យឥណទាននៃឧបករណ៍ហិរញ្ញវត្ថុ បានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។ នៅពេលដែលហានិភ័យឥណទានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង សំវិធានធនលើការបាត់បង់ត្រូវបានវាស់វែងតាមតម្លៃស្មើនឹងអាយុកាលនៃការរំពឹងទុកលើការខាតបង់ឥណទាន។

នៅពេលកំណត់ថាតើហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង និងនៅពេលប៉ាន់ស្មានការរំពឹងទុកលើការខាតបង់ឥណទាន នោះធនាគារពិចារណាលើព័ត៌មានដែលសមហេតុសមផល និងព័ត៌មានគាំទ្រ ដែលពាក់ព័ន្ធ និងអាចរកបាន ដោយមិនចាំបាច់ចំណាយ ឬប្រឹងប្រែងខ្ពស់។ ព័ត៌មានទាំងនេះរួមបញ្ចូលព័ត៌មានបរិមាណ និងព័ត៌មានគុណភាព និងការវិភាគ ដោយផ្អែកលើបទពិសោធន៍របស់ធនាគារ និងការវាយតម្លៃឥណទានព្រមទាំងបញ្ចូលព័ត៌មានប្រមើលអនាគត។

ប្រសិនបើហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬប្រសិនបើគុណភាពឥណទាននៃឧបករណ៍ហិរញ្ញវត្ថុមានភាពប្រសើរឡើង ដែលបណ្តាលឲ្យគ្មានការកើនឡើងជាសារវន្ត នៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់លើកដំបូង សំវិធានធនលើការបាត់បង់ត្រូវបានវាស់វែងតាមតម្លៃស្មើនឹងការរំពឹងទុកលើការខាតបង់ឥណទាន 12 ខែ។

រយៈពេលអតិបរមាដែលត្រូវយកមកពិចារណា ពេលធ្វើការប៉ាន់ស្មានការរំពឹងទុកលើការខាតបង់ឥណទាន គឺជារយៈពេលកិច្ចសន្យាអតិបរមា ដែលធនាគារប្រឈមនឹងហានិភ័យឥណទាន ។

ការកំណត់នៃការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន

ធនាគារវាយតម្លៃថាតើមានហានិភ័យឥណទានបានកើនឡើងជាសារវន្ត ឬទេ ចាប់តាំងពីការទទួលស្គាល់លើកដំបូង នៅកាលបរិច្ឆេទរាយការណ៍ ។ ការកំណត់ពីការកើនឡើងនៃហានិភ័យឥណទានផ្អែកជាសំខាន់លើចរិតលក្ខណៈនៃឧបករណ៍ហិរញ្ញវត្ថុ និងអតិថិជន និងតំបន់ភូមិសាស្ត្រ ។

ធនាគារពិចារណាថាការកើនឡើងនៃហានិភ័យឥណទានជាសារវន្ត កើតឡើងនៅពេលទ្រព្យសកម្មមានការខកខានសងមិនតិចជាងរយៈពេលចំនួន 30 ថ្ងៃ ។ ចំនួនថ្ងៃខកខានសងត្រូវបានកំណត់ដោយការរាប់ចំនួនថ្ងៃ ចាប់តាំងពីកាលបរិច្ឆេទផុតកំណត់ដំបូងបង្អស់ ដែលការបង់សងទាំងអស់មិនទាន់បានទទួល ។ កាលបរិច្ឆេទផុតកំណត់សង ត្រូវបានកំណត់ដោយមិនពិចារណាទៅលើរយៈពេលអនុគ្រោះណាមួយដែលអាចមានសម្រាប់អតិថិជនឡើយ ។

ប្រសិនបើ មានភស្តុតាងបញ្ជាក់ថាមិនមានការកើនឡើងលើហានិភ័យឥណទានជាសារវន្ត ទាក់ទងនឹងការទទួលស្គាល់លើកដំបូងទេនោះ សំវិធានធននៃការបាត់បង់លើឧបករណ៍ហិរញ្ញវត្ថុនឹងត្រូវវាស់វែងតាមការរំពឹងទុកលើការខាតបង់ឥណទាន 12 ខែ។

និយមន័យនៃការខកខានសង

ធនាគារចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចីមិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទាំងស្រុង ដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- អ្នកខ្ចីមានថ្ងៃដែលហួសការកំណត់សងលើសពី ឬស្មើនឹង 90 ថ្ងៃ សម្រាប់កម្ចីរយៈពេលវែង ឬមានថ្ងៃដែលហួសកាលកំណត់សងលើសពី ឬស្មើនឹង 31 ថ្ងៃ សម្រាប់កម្ចីរយៈពេលខ្លីទៅលើកាតព្វកិច្ចជាសារវន្តណាមួយរបស់ធនាគារ ឬ
- នៅពេលអ្នកខ្ចីនិងរៀបចំឡើងវិញនូវកម្ចី ដែលជាលទ្ធផលនៃការក្ស័យធន ដោយសារតែអសមត្ថភាពសង ក្នុងកាតព្វកិច្ចឥណទាន ។

ការវាស់វែងការរំពឹងទុកលើការខាតបង់ឥណទាន

ការរំពឹងទុកលើការខាតបង់ឥណទាន គឺជាការប៉ាន់ស្មានប្រូបាប៊ីលីតេមធ្យមនៃការបាត់បង់ឥណទាន ។ ការរំពឹងទុកលើការខាតបង់ឥណទានត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរទឹកប្រាក់ដែលជំពាក់ ធនាគារស្របតាមកិច្ចសន្យា និងលំហូរទឹកប្រាក់ដែលធនាគាររំពឹងទុកថានឹងទទួលបាន) ។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលរំពឹងទុកនាពេលអនាគត ។
- កិច្ចសន្យាឥណទានដែលនៅសល់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរទឹកប្រាក់តាមកិច្ចសន្យាដែលជំពាក់ ធនាគារ ប្រសិនបើអ្នកកាន់កាប់កិច្ចសន្យាឥណទានបានដកឥណទានប្រើ និងលំហូរទឹកប្រាក់ដែលធនាគារ រំពឹងទុកថានឹងទទួលបាន ប្រសិនបើឥណទានត្រូវបានដកប្រើ។

ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ

សមាសធាតុសំខាន់ៗ ក្នុងការវាស់វែងការរំពឹងទុកលើការខាតបង់ឥណទាន គឺបានមកពីអថេរដូចខាងក្រោម៖

- ប្រូបាប៊ីលីតេនៃការខកខានសង (“PD”);
- ការបាត់បង់ដែលបណ្តាលមកពីការខកខានសង (“LGD”) និង
- ទំហំនៃការខកខានសង (“EAD”)

ECL សម្រាប់សមតុល្យក្នុងដំណាក់កាលទី 1 ត្រូវបានគណនាដោយផលគុណនៃ PD 12 ខែ នឹង LGD នឹង EAD ។ ECL ពេញអាយុកាលត្រូវបានគណនាដោយផលគុណនៃ PD ពេញអាយុកាល នឹង LGD នឹង EAD ។

គំរូស្ថិតិត្រូវបានប្រើប្រាស់ដើម្បីវិភាគទិន្នន័យប្រមូលបាន រួចបង្កើតនូវការប៉ាន់ស្មាន PD ពេញអាយុកាល ដែលនៅសល់ និងថាតើសមតុល្យទាំងនោះរំពឹងថាប្រែប្រួលយ៉ាងណាលើរយៈពេលនោះ ។

LGD គឺជាតំរិយាបទនៃភាពអាចបាត់បង់ប្រសិនបើមានការខកខានសង ។ ធនាគារប៉ាន់ស្មានលក្ខខណ្ឌ LGD យោងតាមប្រវត្តិនៃអត្រាការប្រមូលត្រលប់ពីអតិថិជនខកខានសង ។ គំរូ LGD ត្រូវបានពិចារណាលើរចនាសម្ព័ន្ធអចិភាពនៃការទាមទារសំណង វិស័យដែលអតិថិជនស្ថិតនៅ ចំណាយលើការប្រមូលពីទ្រព្យបញ្ចាំ ដែលជាផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ ។ សម្រាប់ឥណទានដែលការពារដោយទ្រព្យអនុបាតឥណទានធៀបនឹងតម្លៃទ្រព្យបញ្ចាំ (“LTV”) គឺជាលក្ខខណ្ឌមួយក្នុងការកំណត់ LGD ។ ការប៉ាន់ស្មាន LGD ត្រូវបានវាស់វែងសម្រាប់វិស័យផ្សេងៗគ្នា ហើយសម្រាប់ឥណទានគេហដ្ឋាន គឺអាស្រ័យលើការប្រែប្រួលតម្លៃអចល ទ្រព្យ ។ តម្លៃទាំងនោះនឹងត្រូវបានគណនាដោយអប្បហារ ដោយផ្អែកលើអត្រាការប្រាក់ប្រសិទ្ធភាព ។ EAD តំណាងឲ្យតម្លៃសមតុល្យនៅពេលមានការខកខានសង ។ ធនាគារទាញយក EAD ពីសមតុល្យបច្ចុប្បន្នរបស់អតិថិជន និងភាពអាចប្រែប្រួលលើសមតុល្យបច្ចុប្បន្នពីការបង់សង ដែលអនុញ្ញាតតាមកិច្ចសន្យា និងកើតចេញពីការបង់រំលស់ ។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺតម្លៃយោងដុលនៅពេលមានការខកខានសង ។

សម្រាប់កាតព្វកិច្ចឲ្យខ្ចី EAD គឺសមតុល្យអនាគតដែលអាចដកប្រើប្រាស់តាមកិច្ចសន្យា ដែលត្រូវបានប៉ាន់ស្មានតាមការសង្កេតពីប្រវត្តិ និងការព្យាករណ៍នាពេលខាងមុខ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុខ្លះ EAD ត្រូវបានកំណត់ដោយគំរូនៃសមតុល្យដែលអាចកើតឡើងនៅពេលវេលាផ្សេងគ្នាដោយប្រើបច្ចេកទេសស្ថិតិ ។

ដូចការរៀបរាប់ខាងលើ ដោយផ្អែកលើការប្រើប្រាស់ PD 12 ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី1 ធនាគារវាស់វែងការរំពឹងទុកលើការខាតបង់ឥណទាន ដោយពិចារណាលើហានិភ័យនៃការខូចខាតលើរយៈពេលពេញលេញនៃកិច្ចសន្យា (រួមបញ្ចូលទាំងរយៈពេលពន្យាប្រសិនបើមាន) ដែលមានហានិភ័យលើឥណទាន ទោះបីជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទានក៏ដោយ ធនាគារពិចារណាលើរយៈពេលដែលវែងជាង។ រយៈពេល ដែលវែងបំផុត គឺគិតត្រឹមថ្ងៃ ដែលធនាគារមានសិទ្ធិដើម្បីទាមទារការសងត្រឡប់នៃឥណទាន ឬបញ្ចប់កិច្ចសន្យាផ្តល់ឥណទាន ឬការធានា ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែតម្រូវ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ ត្រូវបានជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជន នោះការវាយតម្លៃត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរ

តែត្រូវឈប់ទទួលស្គាល់ ឬទេ ហើយ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើការរៀបចំឡើងវិញ មិននាំឲ្យឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ទេ នោះលំហូរ ទឹកប្រាក់ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវ ត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់ ។
- ប្រសិនបើការរៀបចំឡើងវិញ នាំឲ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្របរំពឹងទុកនៃទ្រព្យសកម្មថ្មីនោះ ត្រូវបានចាត់ទុកជាលំហូរទឹកប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន នៅពេលដែលឈប់ទទួលស្គាល់។ ចំនួនទឹកប្រាក់នេះត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់ ទៅកាលបរិច្ឆេទរាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមរំលស់ថ្លៃដើម និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រាតាម FVOCI មានឱនភាពនៃតម្លៃ ឬទេ (ដែលត្រូវបានកំណត់ជា "ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី 3")។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ នៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើនបានកើតឡើង ដែលនាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគតដែលរំពឹងទុក នៃទ្រព្យសកម្មហិរញ្ញវត្ថុ ។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់ឥណទានដល់អតិថិជន ដែលធនាគារមិនយល់ព្រម
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ ។

ឥណទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារតែភាពមិនប្រក្រតីនៅក្នុងលក្ខខណ្ឌរបស់អតិថិជន ត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ លុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរទឹកប្រាក់តាមកិច្ចសន្យាបានថយចុះជាសារវន្ត និងមិនមានសុចនាករណ៍ផ្សេងទៀតដែលនាំឲ្យមានឱនភាពនៃតម្លៃ ។ បន្ថែមលើនេះ ឥណទានដែលហួសកាលកំណត់សង 90 ថ្ងៃ ឬលើសពីនេះ ត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ ទោះបីជានិយមន័យនៃការហួសកាលកំណត់សងដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ ។

សំវិធានធនសម្រាប់ការរំពឹងទុកលើការខាតបង់ឥណទាន នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

សំវិធានធននៃការរំពឹងទុកលើការខាតបង់ឥណទាន ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមរំលស់ថ្លៃដើម ដោយធ្វើការកាត់កងពីតម្លៃយោងដុលនៃទ្រព្យសកម្ម។

ការលុបចោល

ឥណទានផ្តល់ដល់អតិថិជនត្រូវបានលុបចេញពីបញ្ជី (មួយផ្នែក ឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង ។ ករណីនេះមានជាទូទៅ នៅពេល ធនាគារកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរទឹកប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី ។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមកម្រិតទ្រព្យសកម្មនីមួយៗ។

ទឹកប្រាក់ប្រមូលបានមកវិញលើចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលទៅក្នុងខ្ទង់ "ការខាតបង់សុទ្ធពីឱនភាពនៃតម្លៃ ឧបករណ៍ហិរញ្ញវត្ថុ" នៅក្នុងចំណេញ ឬខាត និង OCI ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជី នៅតែត្រូវឲ្យមានសកម្មភាពទាមទារសងមកវិញ ដើម្បីអនុលោមតាមនីតិវិធីរបស់ធនាគារក្នុងការប្រមូលទឹកប្រាក់ដែលនៅជំពាក់ ។

ឃ. ដើមទុន

ភាគហ៊ុនធម្មតា ត្រូវបានចាត់ថ្នាក់ជាមូលធន ។ ថ្លៃដើមផ្ទាល់ក្នុងការបញ្ចេញភាគហ៊ុន ត្រូវបានទទួលស្គាល់ដោយកាត់ចេញពីមូលធនបន្ទាប់ពីដកពន្ធរួច។ ភាគហ៊ុនដទៃទៀតត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬ បំណុល ផ្អែកលើសមាសធាតុសេដ្ឋកិច្ចនៃឧបករណ៍ទាំងនោះ ។ ការបែងចែកទៅអ្នកកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់ជាឧបករណ៍មូលធន ត្រូវបានទូទាត់ដោយផ្ទាល់ពីមូលធន។

ង. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានបង្កើតលើភាពខុសគ្នា រវាងសំវិធានធន ស្របតាម ស.រ.ទ.ហ.អ.ក និងសំវិធានធនតាមបទប្បញ្ញត្តិ ស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-017-344 ចុះថ្ងៃទី 1 ខែ ធ្នូ ឆ្នាំ 2017 និងសារាចរណែនាំ លេខ ធ7-018-001 ស.រ.ឆ.ណ ចុះថ្ងៃទី 16 ខែ កុម្ភៈ ឆ្នាំ 2018 ស្តីពីចំណាត់ថ្នាក់ ។ ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពនៃតម្លៃ សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។ ស្របតាមប្រការ 73 គ្រឹះស្ថានត្រូវប្រៀបធៀបសំវិធានធន ដែលគណនាតាមប្រការ 49 ដល់ ប្រការ 71 ជាមួយនឹងសំវិធានធនដែលគណនាតាមប្រការ 72 និងត្រូវកត់ត្រាដូចខាងក្រោម៖

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ 72 ទាបជាងសំវិធានធនដែលគណនាតាមប្រការ 49 ដល់ ប្រការ 71 នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាអនុលោមតាម ស.រ.ទ.ហ.អ.ក និង

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ 72 ខ្ពស់ជាងសំវិធានធនដែលគណនាតាមប្រការ 49 ដល់ ប្រការ 71 នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាម ស.រ.ទ.ហ.អ.ក និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬគណនីខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងមូលធននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ទុនបម្រុងតាមបទប្បញ្ញត្តិមិនត្រូវបានបញ្ចូលក្នុងការគណនាមូលធនថ្នាល់សុទ្ធរបស់ធនាគារឡើយ ។

ច. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យសាច់ប្រាក់ក្នុងធនាគារ ប្រាក់បញ្ញើ និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវិភាគនៅពេលតម្កល់ដំបូងមានរយៈពេល 3 ខែ ឬតិចជាង ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួច ចំពោះការផ្លាស់ប្តូរតម្លៃ។

ឆ. ប្រាក់បញ្ញើនៅធនាគារនានា

ប្រាក់បញ្ញើនៅធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃដើម ដកឱនភាពនៃតម្លៃដែលមិនអាចប្រមូលមកវិញបាន ។

ជ. ប្រាក់តម្កល់តាមច្បាប់

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមា និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

ឈ. ឥណទាន និងបុរេប្រទាន

"ឥណទាន និងបុរេប្រទាន" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមបញ្ចូលឥណទាន និងបុរេប្រទាន ដែលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម។ ឥណទាន និងបុរេប្រទានត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព ។

ញ. ការវិនិយោគផ្សេងទៀត

ការវិនិយោគផ្សេងទៀត ត្រូវបានកត់ត្រាតាមតម្លៃដើម ដកឱនភាពនៃតម្លៃដែលមិនអាចប្រមូលមកវិញបាន ។

ដ. ទ្រព្យសកម្មផ្សេងទៀត

ទ្រព្យសកម្មផ្សេងទៀតត្រូវបានកត់ត្រាតាមតម្លៃដើម ដកឱនភាពនៃតម្លៃ ប្រសិនបើមាន។

ឋ. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានថ្លៃដើមអាជ្ញាប័ណ្ណកុំព្យូទ័រដែលបានទិញ និងថ្លៃដើមពាក់ព័ន្ធផ្សេងទៀត ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន ។ អាជ្ញាប័ណ្ណកុំព្យូទ័រដែលបានទិញត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់ ។

ទ្រព្យសកម្មអរូបីត្រូវបានដករំលស់ទៅតាមការប៉ាន់ស្មានអាយុកាលប្រើប្រាស់ពី 3 ឆ្នាំ តាមវិធីសាស្ត្ររំលស់ថេរ ។

ថ្លៃដើមពាក់ព័ន្ធនឹងការបង្កើត ឬថែទាំកុំព្យូទ័រសូហ្វវែរ ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលកើតឡើង។

ឧ. ទ្រព្យ និងបរិក្ខារ

(i). ការទទួលស្គាល់ និងការវាស់វែង

ផ្នែកនៃទ្រព្យ និងបរិក្ខារត្រូវបានវាស់វែងតាមតម្លៃដើម ដកវិលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ។

ចំណាយថ្លៃដើមរួមបញ្ចូលទាំងការចំណាយដោយផ្ទាល់ទៅលើការទិញទ្រព្យ និងការចំណាយដោយផ្ទាល់ផ្សេងៗទៀត ក្នុងការនាំយកទ្រព្យសកម្មទៅក្នុងលក្ខខណ្ឌដែលអាចប្រើប្រាស់ដែលបានគ្រោងទុក និងថ្លៃដើមនៃការរុះរើ និងផ្លាស់ប្តូរទីកន្លែង និងការស្តារទីតាំងដែលពួកគេស្ថិតនៅ។ ថ្លៃដើមនៃទ្រព្យកម្មដែលបានសាងសង់ដោយខ្លួនឯង ត្រូវរួមបញ្ចូលទាំងថ្លៃដើមសម្ភារៈ និងកម្លាំងពលកម្មផ្ទាល់ផងដែរ។ ចំពោះទ្រព្យសកម្មដែលមានលក្ខណៈគ្រប់គ្រាន់ ការចំណាយលើប្រាក់កម្ចីត្រូវបានធ្វើមូលធនកម្មស្របតាមគោលនយោបាយគណនេយ្យលើថ្លៃដើមប្រាក់កម្ចី។ ថ្លៃដើមក៏អាចរួមបញ្ចូលទាំងការផ្ទេរមូលធន ដែលជាចំណេញ ឬខាតណាមួយផងដែរ លើការការពារហានិភ័យលំហូរសាច់ប្រាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះ រូបិយប័ណ្ណបរទេសទាក់ទងនឹងការទិញទ្រព្យ និងបរិក្ខារ ។

ការទិញសូហ្វវែរដែលមានសារៈសំខាន់ចំពោះមុខងារដែលទាក់ទងនឹងបរិក្ខារ ត្រូវបានធ្វើមូលធនកម្មជាផ្នែកមួយនៃបរិក្ខារនោះ។

ប្រសិនបើផ្នែកជាសារវន្តណាមួយនៃទ្រព្យ និងបរិក្ខារទាំងនោះ មានអាយុកាលប្រើប្រាស់ខុសពីគ្នា ផ្នែកទាំងនោះត្រូវបានដាក់ជាផ្នែកដោយឡែក (សមាសភាពចម្បង) នៃទ្រព្យ និងបរិក្ខារ។

(ii). ចំណាយបន្ទាប់

ចំណេញ ឬខាតពីការលក់នៃទ្រព្យ និងបរិក្ខារណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់ជាចំណូលផ្សេងៗ "ចំណូល ផ្សេងៗ" និង "ចំណាយផ្សេងៗ" នៅក្នុងចំណេញ ឬខាត ។

ថ្លៃដើមនៃការផ្លាស់ប្តូរធាតុមួយផ្នែកនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូល នៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតដល់ធនាគារ ហើយតម្លៃរបស់វាអាចធ្វើការវាស់វែងបានដោយភាពអាចជឿជាក់បាន ។ តម្លៃយោង នៃធាតុដែលបានជំនួសនោះ ត្រូវឈប់ទទួលស្គាល់ជាចំណេញ ឬខាត ។ រាល់ចំណាយក្នុងការថែទាំប្រចាំថ្ងៃ ផ្សេងៗ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត នៅក្នុងរបាយការណ៍លទ្ធផលក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

(iii). វិលស់

វិលស់ គឺផ្អែកទៅលើថ្លៃដើមនៃទ្រព្យសកម្ម ដកតម្លៃសំណល់របស់វា ។ សមាសធាតុសំខាន់ៗ នៃទ្រព្យសកម្មនីមួយៗ ត្រូវបានវាយតម្លៃ ហើយប្រសិនបើសមាសធាតុមួយមានអាយុកាលប្រើប្រាស់ខុសគ្នាពីទ្រព្យសកម្មដែលនៅសល់ សមាសធាតុនោះត្រូវបានធ្វើឡើងដាច់ដោយឡែក ។

វិលស់ ត្រូវបានទទួលស្គាល់ថាជាការចំណាយនៅក្នុងរបាយការណ៍ចំណេញ ឬខាតដោយប្រើវិធីសាស្ត្រវិលស់ថេរលើអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មាននៃសមាសធាតុនីមួយៗ នៃទ្រព្យ និងបរិក្ខារ ។

ទ្រព្យសកម្មដែលបានជួល ត្រូវបានវិលស់រយៈពេលជួល ឬអាយុកាលប្រើប្រាស់របស់វាមួយណាដែលខ្លីជាងលើកលែងតែមានហេតុផលច្បាស់លាស់ថា ធនាគារនឹងទទួលបានកម្មសិទ្ធិនៅចុងបញ្ចប់នៃរយៈពេលនៃការជួល ។ ដីទំនេរមិនត្រូវបានវិលស់នោះទេ ។

វិលស់ ត្រូវបានទទួលស្គាល់ចាប់ពីកាលបរិច្ឆេទដែលទ្រព្យ និងបរិក្ខារត្រូវបានតម្លើង និងអាចប្រើប្រាស់បាន ឬទ្រព្យសកម្មដែលបានសាងសង់ចាប់ពីការិយបរិច្ឆេទដែលទ្រព្យសកម្មនោះត្រូវបានបញ្ចប់ និងអាចប្រើប្រាស់បាន ។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្នមានដូចខាងក្រោម៖

	ឆ្នាំ
ការកែលម្អលើដី	5 - 20
គ្រឿងសង្ហារឹមនិងគ្រឿងបរិក្ខារ	5
បរិក្ខារការិយាល័យ	5
បរិក្ខារកុំព្យូទ័រ និងព័ត៌មានវិទ្យា	3
យានយន្ត	5

វិធីសាស្ត្ររំលស់ លើអាយុកាលប្រើប្រាស់ និងតម្លៃសំណល់ ត្រូវបានវាយតម្លៃនាចុងការិយបរិច្ឆេទនៃរបាយការណ៍ និងនិយ័តភាព ប្រសិនបើសមស្រប ។

ឈ. ភតិសន្យា

នៅពេលចាប់ផ្តើមកិច្ចសន្យា ធនាគារធ្វើការវាយតម្លៃថាតើកិច្ចសន្យាមួយមានទម្រង់ជាភតិសន្យាដែរ ឬទេ ។ កិច្ចសន្យាជាទម្រង់មានភតិសន្យា ប្រសិនបើកិច្ចសន្យាផ្តល់សិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់មួយក្នុងរយៈពេលកំណត់មួយ ជាថ្នូរនឹងតម្លៃតបស្នង។

ដើម្បីវាយតម្លៃថាតើកិច្ចសន្យាផ្តល់សិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់ ធនាគារធ្វើការវាយតម្លៃ ថាតើ៖

- កិច្ចសន្យាមានជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់ ឬទេ ដែលនេះអាចបញ្ជាក់យ៉ាងជាក់លាក់ ឬប្រយោល ហើយគួរមានលក្ខណៈរូបវន្តដោយឡែក ឬតំណាងសមត្ថភាពផលិតសារវន្ត របស់ ទ្រព្យសកម្មនោះ ។ ប្រសិនបើអ្នកផ្គត់ផ្គង់មានសិទ្ធិផ្តល់ទ្រព្យសកម្មជំនួសជាសារវន្តក្នុងរយៈពេលប្រើប្រាស់ នោះទ្រព្យសកម្មមិនមែនមានលក្ខណៈជាទ្រព្យសកម្មជាក់លាក់នោះទេ
- ធនាគារ មានសិទ្ធិទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចជាសារវន្ត ពីការប្រើប្រាស់ទ្រព្យសកម្ម ក្នុងរយៈពេលនៃការប្រើប្រាស់ និង
- ធនាគារមានសិទ្ធិបញ្ជាការប្រើប្រាស់ទ្រព្យសកម្ម ។ ធនាគារមានសិទ្ធិនេះ នៅពេលដែលធនាគារមានសិទ្ធិសម្រេចចិត្តដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរអំពីរបៀប និងគោលបំណងក្នុងការប្រើប្រាស់ទ្រព្យសកម្ម ។ ក្នុងករណីដែលការសម្រេចចិត្តទាំងអស់អំពីរបៀប និងគោលបំណងនៃការប្រើប្រាស់ ទ្រព្យសកម្មត្រូវបានកំណត់ជាមុន នោះ ធនាគារមានសិទ្ធិបញ្ជាការប្រើប្រាស់ទ្រព្យសកម្ម ប្រសិនបើ៖
  - ធនាគារមានសិទ្ធិធ្វើប្រតិបត្តិការលើទ្រព្យសកម្ម ឬ
  - ធនាគារបានរៀបចំទ្រព្យសកម្មទៅតាមវិធីដែលកំណត់ជាមុនពីរបៀប និងគោលបំណងដែលទ្រព្យសកម្ម នោះនឹងត្រូវបានប្រើប្រាស់ ។

គោលនយោបាយនេះអនុវត្តចំពោះកិច្ចសន្យាដែលបានព្រមព្រៀង ឬបានធ្វើការផ្លាស់ប្តូរ ចាប់ពីថ្ងៃទី1 ខែ មករា ឆ្នាំ 2018 មកប៉ុណ្ណោះ ។

នៅពេលចាប់ផ្តើមកិច្ចសន្យា ឬវាយតម្លៃឡើងវិញលើកិច្ចសន្យាដែលមានទម្រង់ជាភតិសន្យា និងសមាសធាតុ ដែលមិនមែនភតិសន្យា ធនាគារបែងចែកតម្លៃតបស្នងនៅក្នុងកិច្ចសន្យាចំពោះសមាសធាតុនៃភតិសន្យា នីមួយៗ និងសមាសធាតុដែលមិនមែនភតិសន្យាដោយផ្អែកតាមតម្លៃឯកតានីមួយៗ ។ ក៏ប៉ុន្តែ ចំពោះការជួលដី និងអគារដែលធនាគារជាអ្នកជួល ធនាគារមិនបែងចែកសមាសធាតុមិនមែនភតិសន្យានោះទេ ហើយសមាសធាតុភតិសន្យា និងមិនមែនភតិសន្យាត្រូវបានចាត់ទុកថាជាសមាសធាតុភតិសន្យា។

ភតិសន្យាក្នុងករណីដែលធនាគារជាអ្នកជួល

ការរៀបចំឲ្យមានសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ប្រសិនបើបំពេញតាមលក្ខខណ្ឌមួយក្នុងចំណោមខាងក្រោម៖

- អ្នកទិញមានសមត្ថភាព ឬសិទ្ធិធ្វើប្រតិបត្តិការលើទ្រព្យសកម្ម ខណៈពេលដែលទទួលបាន ឬគ្រប់គ្រងលើសពីបរិមាណដែលមិនសារវន្ត
- អ្នកទិញមានសមត្ថភាព ឬសិទ្ធិក្នុងការគ្រប់គ្រងលើការចូលទៅដល់ទ្រព្យសកម្ម ខណៈដែលទទួលបាន ឬគ្រប់គ្រងលើសពីបរិមាណដែលមិនសារវន្ត ឬ
- ដំណើរហេតុ និងកាលៈទេសៈបានបង្ហាញថា វាមានលក្ខណៈតិចតួចដែលភាគីដទៃទៀតនឹងទទួលបានច្រើនជាងបរិមាណដែលមិនសារវន្ត ហើយតម្លៃក្នុងមួយឯកតាមិនត្រូវបានកំណត់ក្នុងមួយឯកតានៃទិន្នផលទេហើយក៏មិនស្មើនឹងតម្លៃទីផ្សារបច្ចុប្បន្ន ក្នុងមួយឯកតានៃលទ្ធផលដែរ។

ធនាគារទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យា នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានវាស់វែងតាមថ្លៃដើម រួមមានថ្លៃដើមដំបូងនៃបំណុលភតិសន្យា និងនិយ័តភាពសម្រាប់ការចំណាយភតិសន្យាដែលធ្វើឡើងនៅថ្ងៃចាប់ផ្តើមភតិសន្យា ឬមុនថ្ងៃចាប់ផ្តើមភតិសន្យា បូកថ្លៃដើមផ្ទាល់ដំបូងដែលបានកើតឡើង និងការប៉ាន់ស្មានចំណាយក្នុងការរុះរើ និងដកចេញនូវទ្រព្យសកម្ម ឬស្តារឡើងវិញនូវទ្រព្យសកម្ម ឬទីតាំង ដកប្រាក់លើកទឹកចិត្តភតិសន្យាដែលទទួលបាន។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានដករំលស់នាពេល តាមវិធីសាស្ត្ររំលស់ថេរ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា រហូតដល់ចុងបញ្ចប់នៃអាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬនៅចុងកាលបរិច្ឆេទនៃភតិសន្យាមួយណាកើតមុន ។ អាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកំណត់តាមមូលដ្ឋានដូចគ្នានឹងទ្រព្យ និងបរិក្ខារ។ បន្ថែមលើនេះ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកាត់បន្ថយជាប្រចាំទៅតាមការខាតបង់ឱនភាពនៃតម្លៃ និងកែតម្រូវសម្រាប់ការវាស់វែងឡើងវិញលើបំណុលភតិសន្យា ។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់សម្រាប់អំឡុងការិយបរិច្ឆេទបច្ចុប្បន្ន មានដូចខាងក្រោម៖

- អគារ និងការិយាល័យ 5 – 15 ឆ្នាំ

បំណុលភតិសន្យា ត្រូវបានវាស់វែងដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនទាន់បានបង់ នៅពេលចាប់ផ្តើមភតិសន្យា និងត្រូវបានធ្វើអប្បហារដោយប្រើអត្រាការប្រាក់ជាក់ស្តែងនៅក្នុងភតិសន្យា ឬករណីដែលអត្រាការប្រាក់នោះមិនអាចកំណត់បានភ្លាមៗ ត្រូវធ្វើទៅតាមអត្រាការប្រាក់កម្ចីបន្ថែមរបស់អ្នកជួល ។

ការទូទាត់ភតិសន្យាដែលបញ្ចូលនៅក្នុងការវាស់វែងបំណុលភតិសន្យារួមមាន៖

- ការទូទាត់ភតិសន្យាថេរ រួមទាំងការទូទាត់ក្នុងទម្រង់ថេរ
- ការប្រែប្រួលនៃការទូទាត់ភតិសន្យាអថេរ ដោយផ្អែកលើសន្ទស្សន៍ ឬអត្រា នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា
- ចំនួនដែលរំពឹងថានឹងត្រូវទូទាត់ ក្រោមការធានាតម្លៃនៅសល់ និង
- តម្លៃទិញក្រោមជម្រើសនៃការទិញ ដែលធនាគារមានហេតុផលជាក់លាក់ក្នុងការអនុវត្ត ។ ការទូទាត់ភតិសន្យានៅក្នុងអំឡុងពេលដែលមានជម្រើសក្នុងការបន្ត ប្រសិនបើធនាគារមានហេតុផលជាក់លាក់ក្នុងការបន្ត និងការពិន័យលើការបញ្ចប់ភតិសន្យាមុនកាលកំណត់ លើកលែងតែធនាគារមានហេតុផលច្បាស់លាស់ថានឹងមិនបញ្ចប់ភតិសន្យាមុនកាលកំណត់។

បំណុលភតិសន្យាត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។ បំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញនៅពេលមានការកែប្រែរយៈពេលនៃភតិសន្យា ការផ្លាស់ប្តូរលើការវាយតម្លៃសម្រាប់ជម្រើសក្នុងការទិញទ្រព្យសកម្ម ការប្រែប្រួលការទូទាត់ភតិសន្យានាពេលអនាគត ដែលកើតឡើងពីការប្រែប្រួលនៃសន្ទស្សន៍ ឬអត្រាណាមួយ ឬប្រសិនបើមានការកែប្រែចំនួនប៉ាន់ស្មានដែលរំពឹងថានឹងត្រូវទូទាត់លើការធានាតម្លៃដែលនៅសល់ ។

នៅពេលដែលបំណុលភតិសន្យាត្រូវបានវាស់វែងតាមវិធីសាស្ត្រនេះ ការកែតម្រូវ ត្រូវបានធ្វើឡើងលើតម្លៃយោងនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬក៏ទទួលស្គាល់ក្នុងចំណេញ ឬខាត បើសិនជាសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានបញ្ចុះរហូតដល់មានតម្លៃសូន្យ ។

ភតិសន្យាមានរយៈពេលខ្លី និងភតិសន្យាលើទ្រព្យសកម្មដែលមានតម្លៃទាប

ធនាគារ មិនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យារយៈពេលខ្លីដូចជា ការជួលម៉ាស៊ីនដែលមានរយៈពេលតិចជាង 12 ខែ និងភតិសន្យាលើទ្រព្យសកម្មដែលមានតម្លៃទាប ដែលរួមមានបរិក្ខារព័ត៌មានវិទ្យា ។ ធនាគារទទួលស្គាល់ចំណាយលើការជួលទាំងនេះតាមមូលដ្ឋានរំលស់ថេរ ទៅតាមរយៈពេលនៃភតិសន្យា ។

ណ. ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដកថ្លៃដើមប្រតិបត្តិការបន្ថែមដោយផ្ទាល់ និងវាស់វែង បន្ទាប់តាមរំលស់ថ្លៃដើមដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

ត. អត្ថប្រយោជន៍និយោជិត

(i). អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លីត្រូវបានចំណាយ នៅពេលដែលសេវាកម្មត្រូវបានផ្តល់ជូន ។ ចំនួនដែលរំពឹងទុកថានឹងត្រូវចំណាយត្រូវបានទទួលស្គាល់ជាបំណុល ប្រសិនបើធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ក្នុងការទូទាត់ចំណាយ ដែលជាលទ្ធផលនៃការងារដែលបានបំពេញរួចមកហើយដោយនិយោជិត ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានបានដោយភាពជឿជាក់។

(ii). អត្ថប្រយោជន៍និយោជិតរយៈពេលវែង

កាតព្វកិច្ចរបស់ធនាគារចំពោះអត្ថប្រយោជន៍និយោជិតរយៈពេលវែង គឺជាចំណាយលើអត្ថប្រយោជន៍ ដែលនិយោជិតត្រូវទទួលបាន ពីការបំពេញការងារក្នុងការិយបរិច្ឆេទកន្លងផុតទៅ និងបច្ចុប្បន្ន ។ អត្ថប្រយោជន៍ និយោជិតរយៈពេលវែង ត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន ។ ការវាស់វែងសារជាថ្មីត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ដែលចំណាយនេះបានកើតឡើង ។

ថ. សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ ។ អប្បហារនៅសល់ត្រូវបានទទួលស្គាល់ជាថ្លៃដើមហិរញ្ញប្បទាន ។

ទ. ការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាព

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុនោះ ឲ្យមកស្មើនឹង៖

- តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- រំលស់តម្លៃដើមរបស់បំណុលហិរញ្ញវត្ថុ ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យដែលបានទិញ ឬទ្រព្យសកម្ម ដែលមានឱនភាពនៃតម្លៃនៅពេលទិញ ធនាគារធ្វើការប៉ាន់ស្មានលើលំហូរទឹកប្រាក់នាពេលអនាគតដោយពិចារណារាល់លក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ឥណទាន ដែលរំពឹងទុកនោះទេ (ECL) ។ សម្រាប់ទ្រព្យសកម្មដែលទិញ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនៅពេលទិញ អត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវហានិភ័យឥណទាន ត្រូវបានគណនា ដោយប្រើលំហូរទឹកប្រាក់ប៉ាន់ស្មាននាពេលអនាគត រួមបញ្ចូលទាំងការខាតបង់ឥណទានដែលរំពឹងទុក (ECL)។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព ។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

រំលស់ថ្លៃដើម និងតម្លៃយោងដុល

រំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់ជាលើកដំបូង ដកការទូទាត់សងប្រាក់ដើម បូក ឬដករំលស់បង្គរ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ចំពោះភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់ជាលើកដំបូង និងចំនួននៅពេលដល់កាលកំណត់ និងត្រូវធ្វើនិយ័តភាពចំពោះសំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ។

តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជារំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលកែតម្រូវសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក ។

ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាលើកដំបូង ។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានប្រើផ្អែកលើតម្លៃយោងដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យសកម្មមិនត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ) ឬរំលស់ថ្លៃដើមនៃបំណុល។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវធ្វើការកែប្រែឡើងវិញ ដោយការប៉ាន់ស្មានឡើងវិញនូវលំហូរទឹកប្រាក់របស់ឧបករណ៍ ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ប្រែប្រួល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររបស់អត្រាការប្រាក់ទីផ្សារ ។ អត្រាការប្រាក់ប្រសិទ្ធភាពក៏ត្រូវធ្វើការកែប្រែឡើងវិញ សម្រាប់ការកែតម្រូវតម្លៃសមស្របនៃឧបករណ៍ការពារនៅកាលបរិច្ឆេទដែលរំលស់ត្រូវបានចាប់ផ្តើមកែតម្រូវ ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ បន្ទាប់ពីបានទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ផ្អែកលើរំលស់ថ្លៃដើម របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពនៃតម្លៃ នោះការគណនាការប្រាក់ត្រូវផ្អែកលើមូលដ្ឋានតម្លៃដុលវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ ចាប់តាំងពីទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលត្រូវបានកែតម្រូវនូវហានិភ័យ ផ្អែកលើរំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ ។ ការគណនាចំណូលការប្រាក់នេះ មិនត្រូវប្តូរទៅមូលដ្ឋានតម្លៃដុលវិញនោះទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរក៏ដោយ ។

ការបង្ហាញ

ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងចំណេញ ឬខាត និង លទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម។

ចំណាយការប្រាក់ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលបំណុលហិរញ្ញវត្ថុ ដែលបានវាស់វែងតាមរំលស់ថ្លៃដើម។

ធ. កម្រៃ និងជើងសារ

ចំណូល និងចំណាយកម្រៃ និងជើងសារ ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព ។

ចំណូលកម្រៃ និងជើងសារផ្សេងទៀត ត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម ។

កិច្ចសន្យាជាមួយអតិថិជនដែលទទួលស្គាល់ជាឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ អាចមានវិសាលភាពដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក 9 និងដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក 15។ ក្នុងករណីនេះ ជាដំបូងធនាគារត្រូវអនុវត្ត ស.រ.ហ.អ.ក 9 ដើម្បីបែងចែកនិងវាស់វែងផ្នែកនៃកិច្ចសន្យា ដែលចាត់ចូលនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក 9 ហើយបន្ទាប់មកអនុវត្ត ស.រ.ហ.អ.ក 15 ចំពោះផ្នែកដែលនៅសេសសល់។

ន. ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ធនាគារ ក្រៅពីសន្និធិ ទ្រព្យសកម្មជាប់កិច្ចសន្យា និងពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់ការិយបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ ឬទេ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង នោះការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង។ ចំពោះទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់មិនកំណត់ ឬមិនទាន់អាចប្រើប្រាស់បាន តម្លៃដែលអាចប្រមូលមកវិញបានត្រូវធ្វើការប៉ាន់ស្មានជារៀងរាល់ឆ្នាំក្នុងពេលតែមួយ ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ ធំជាងការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបាន។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្របដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ ការប៉ាន់ស្មានលំហូរទឹកប្រាក់នាពេលអនាគត ត្រូវបានធ្វើអប្បហារទៅនឹងតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់។

សម្រាប់គោលបំណងនៃការធ្វើតេស្តលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្មឬឯកតាបង្កើតសាច់ប្រាក់។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ។ ការខាតបង់លើឱនភាពនៃតម្លៃ នៃ ឯកតាបង្កើតសាច់ប្រាក់ ត្រូវបានបែងចែកដោយ កាត់បន្ថយតម្លៃយោងនៃតម្លៃកេរ្តិ៍ឈ្មោះរបស់ឯកតាបង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) ជាមុន ហើយបន្ទាប់មកដើម្បីកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្ម ដទៃទៀតនៅក្នុងឯកតាបង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) លើមូលដ្ឋានសមាមាត្រ។

ការខាតបង់លើឱនភាពនៃតម្លៃ ដែលទទួលស្គាល់ក្នុងពេលកន្លងផុតទៅ ត្រូវបានប៉ាន់ប្រមាណរាល់កាលបរិច្ឆេទនៃការរាយការណ៍ ថាតើមានសញ្ញាណណាមួយដែលការខាតបង់បានថយចុះ ឬលែងមានការខាតបង់តទៅទៀត។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវកត់ត្រាបញ្ច្រាសមកវិញប្រសិនបើមានការប្រែប្រួលតម្លៃប៉ាន់ស្មានដែលប្រើប្រាស់ដើម្បីកំណត់តម្លៃដែលអាចប្រមូលមកវិញបាន ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានកត់ត្រាបញ្ច្រាសមកវិញ ត្រឹមកម្រិតមួយដែលមិនធ្វើឲ្យតម្លៃយោងរបស់ទ្រព្យសកម្មនេះ មិនលើសពីតម្លៃយោងដែលត្រូវកំណត់ (ដករំលស់) ក្នុងករណីពុំមានការទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃ។

ប. ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត លើកលែងតែពន្ធនេះទាក់ទងទៅនឹងធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬលទ្ធផលលម្អិតផ្សេងៗ។

ធនាគារបានកំណត់ថា ការប្រាក់ និងការដាក់ពិន័យទាក់ទងនឹងពន្ធលើប្រាក់ចំណេញ រួមបញ្ចូលបំណកស្រាយពន្ធមិនច្បាស់លាស់ មិនបំពេញទៅនឹងនិយមន័យនៃពន្ធលើប្រាក់ចំណេញ ដូច្នេះហើយវាត្រូវបានកត់ត្រាក្រោមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា (ស.គ.អ.ក) 37 សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្មយថាភាព ហើយត្រូវបានទទួលស្គាល់ថាជាការចំណាយដែលពាក់ព័ន្ធ "ការចំណាយផ្សេងទៀត"។

(i). ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ រួមមានពន្ធដែលត្រូវបង់ ឬទទួល លើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

(ii). ពន្ធពន្យារ

ពន្ធពន្យារត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ចំពោះការខាតបង់ពន្ធមិនទាន់បានប្រើប្រាស់ និងភាពលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបានត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត អាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន។ ការកាត់បន្ថយនោះត្រូវកត់ត្រាបញ្ច្រាសមកវិញនៅពេលដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមានលក្ខណៈប្រសើរឡើង ។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ន នៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបាន ដោយប្រើអត្រាពន្ធនៅកាលបរិច្ឆេទរាយការណ៍ ។

ការវាស់វែងពន្ធពន្យារ ឆ្លុះបញ្ចាំងនូវពន្ធដែលធនាគារំពឹងថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល។

ពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធពន្យារជាបំណុល អាចកាត់កងបានតែក្នុងករណីវាបានបំពេញលក្ខខណ្ឌជាក់លាក់ណាមួយ ។

ផ. បំណុលយថាភាព

ក្នុងករណីដែលមិនតម្រូវឲ្យមានការហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានបាន នោះកាតព្វកិច្ចមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនោះទេ ហើយវា ត្រូវបានបង្ហាញថាជាបំណុលយថាភាព លើកលែងតែប្រូបាប៊ីលីតេនៃលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើរតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមាន ដែលអស្ថិរភាពនៃកាតព្វកិច្ចនឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ រឺច្រើន ក៏ត្រូវបានបង្ហាញថាជាបំណុលយថាភាពដែលអាចកើតមានឡើង លុះត្រាតែប្រូបាប៊ីលីតេនៃការហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើរតែគ្មាន។

ព. ទ្រព្យសកម្មយថាភាព

ក្នុងករណីដែលមិនមានលទ្ធភាពហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានបាន នោះទ្រព្យសកម្មមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុឡើយ ហើយវាត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាភាព លើកលែងតែប្រូបាប៊ីលីតេនៃលំហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ចគឺស្ទើរតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមាន ដែលអស្ថិរភាពនៃទ្រព្យសកម្មនឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើន ក៏ត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាភាពដែលអាចកើតមានឡើង លុះត្រាតែប្រូបាប៊ីលីតេនៃការហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើរតែគ្មាន។

33. ការពន្យល់អំពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក

ការអនុវត្តក្របខណ្ឌស្តង់ដារ ស.រ.ទ.ហ.អ.ក

ធនាគារបានអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”) ដែលដូចគ្នានឹងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលចេញដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (“IASB”) នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 ។ របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទ 31 ខែ ធ្នូ ឆ្នាំ 2019 នេះ ជារបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើងស្របតាម ស.រ.ទ.ហ.អ.ក រួមទាំងការអនុវត្តស.រ.ហ.អ.ក 1 ការអនុវត្តជាលើកដំបូង ស.រ.ទ.ហ.អ.ក ។

ហេតុដូច្នេះ ធនាគារបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម ស.រ.ទ.ហ.អ.ក ដែលមានប្រសិទ្ធភាពអនុវត្តសម្រាប់ការិយបរិច្ឆេទចាប់ផ្តើមនៅ ឬនៅក្រោយថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 រួមជាមួយនឹងព័ត៌មានប្រៀបធៀប នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ដូចដែលបានរៀបរាប់នៅក្នុងគោលនយោបាយគណនេយ្យសំខាន់ៗ នៅក្នុងកំណត់សម្គាល់ 32។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ ធនាគារត្រូវបានរៀបចំឡើងដំបូង នៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ដែលជាការិយបរិច្ឆេទនៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក។ ក៏ប៉ុន្តែ ធនាគារ ពុំទាន់មានប្រតិបត្តិការកើតឡើងមុនថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 នៅឡើយទេ។ ហេតុនេះការពន្យល់ និងនិយ័តភាពសំខាន់ៗខាងក្រោម ដែលបានធ្វើឡើងដោយធនាគារក្នុងការកត់ត្រាឡើងវិញនូវរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានបោះផ្សាយពីមុន ដែលត្រូវបានរៀបចំឡើងដោយស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ហៅកាត់ថា (“ស្តង់ដារពីមុន”) គឺបង្ហាញតែលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ប៉ុណ្ណោះ។

ការអនុវត្តការលើកលែងដែលអាចជ្រើសរើសបាន

ស.រ.ហ.អ.ក 1 អនុញ្ញាតឲ្យអ្នកអនុវត្តជាលើកដំបូង នូវការលើកលែងមួយចំនួនពីការអនុវត្តតាមវិធីសាស្ត្រប្រតិសកម្ម នូវតម្រូវការ ស.រ.ទ.ហ.អ.ក។ ធនាគារបានអនុវត្តការលើកលែងដូចខាងក្រោម:

តម្លៃសមស្រប ឬការវាយតម្លៃឡើងវិញដោយចាត់ទុកជាថ្លៃដើម - ទ្រព្យ និងបរិក្ខារ

ធនាគារបានជ្រើសរើសដើម្បីវាស់វែងធាតុនីមួយៗ នៃទ្រព្យ និងបរិក្ខារ ដោយប្រើប្រាស់ស្តង់ដារពីមុន ដែលអាចប្រៀបធៀបបានទៅនឹងតម្លៃដើមដកតំលៃ ស្របតាម ស.រ.ទ.ហ.អ.ក នៅការិយបរិច្ឆេទផ្លាស់ប្តូរទៅស.រ.ទ.ហ.អ.ក ។

ភតិសន្យា

ស.រ.ហ.អ.ក 16 ណែនាំអំពីការធ្វើវិសោធនកម្មដែលមានសារៈសំខាន់ចំពោះ ស.រ.ហ.អ.ក 1 ដែលរួមមានជម្រើសសម្រាប់អ្នកអនុវត្តជាលើកដំបូង ដើម្បីអនុវត្តនិយមន័យភតិសន្យាថ្មីចំពោះកិច្ចសន្យាដែលមានស្រាប់នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរដោយ ផ្អែកលើដំណើរហេតុ និងកាលៈទេសៈនៅការិយបរិច្ឆេទនោះ ។

ជម្រើសនៃការលើកលែងផ្សេងៗទៀត ដែលមាននៅក្នុង ស.រ.ហ.អ.ក 1 ដែលមិនត្រូវបានពិភាក្សានៅទីនេះ គឺមិនមានផលប៉ះពាល់ជាសារវន្តដល់ធនាគារឡើយ។

ការលើកលែងដែលមិនអាចជ្រើសរើសបាន

ការប៉ាន់ស្មាន

ការប៉ាន់ស្មាននៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 គឺស្របគ្នានឹងការប៉ាន់ស្មានដែលមានការិយបរិច្ឆេទដូចគ្នាដោយស្របតាមស្តង់ដារពីមុន។ ការប៉ាន់ស្មានដែលធនាគារបានប្រើដើម្បីបង្ហាញចំនួនទឹកប្រាក់ទាំងនេះដោយអនុលោមទៅតាម ស.រ.ទ.ហ.អ.ក គឺឆ្លុះបញ្ចាំងពីលក្ខខណ្ឌដែលមាននៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ។

ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

អ្នកអនុវត្តជាលើកដំបូង ត្រូវតែអនុវត្តការឈប់ទទួលស្គាល់តាមតម្រូវការរបស់ ស.រ.ទ.ហ.អ.ក សម្រាប់ប្រតិបត្តិការដែលបានកើតឡើងនៅថ្ងៃ ឬនៅក្រោយថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ជាការិយបរិច្ឆេទនៃការផ្លាស់ប្តូរទៅស.រ.ទ.ហ.អ.ក តាមវិធីសាស្ត្រទស្សនវិស័យ។ ទោះជាយ៉ាងណាក៏ដោយ អង្គភាពមួយអាចអនុវត្តការឈប់ទទួលស្គាល់តាមតម្រូវការរបស់ ស.រ.ទ.ហ.អ.ក ចាប់ពីការិយបរិច្ឆេទប្រតិសកម្មដែល អង្គភាពបានជ្រើសរើសប្រសិនបើ ព័ត៌មានដែលតម្រូវឲ្យធ្វើបែបនេះ គឺទទួលបាននៅពេលចាប់ផ្តើមធ្វើប្រតិបត្តិការគណនេយ្យ ទាំងនោះ ។

ធនាគារបានអនុវត្តតាមតម្រូវការនៃការឈប់ទទួលស្គាល់របស់ ស.រ.ទ.ហ.អ.ក តាមវិធីសាស្ត្រទស្សនវិស័យសម្រាប់ប្រតិបត្តិការដែលកើតឡើងនៅថ្ងៃ ឬនៅក្រោយថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។

ការផ្ទៀងផ្ទាត់

ការផ្ទៀងផ្ទាត់រួមមានជួរឈរពីរសម្រាប់ការិយបរិច្ឆេទនីមួយៗ ក៏ដូចជាលទ្ធផលនៃស្តង់ដារពីមុន និងស.រ.ទ.ហ.អ.ក ។ ជួរឈរនៃ " ការធ្វើចំណាត់ថ្នាក់ឡើងវិញ" រួមមានការធ្វើចំណាត់ថ្នាក់ឡើងវិញ និងការវិភាគចំនួនទឹកប្រាក់ឡើងវិញ តាមស្តង់ដារពីមុន និង ស.រ.ទ.ហ.អ.ក សម្រាប់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ជួរឈរនៃ "ផលប៉ះពាល់នៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក" បានបង្ហាញពីផលប៉ះពាល់នៃការផ្លាស់ប្តូរការទទួលស្គាល់ និងការវាស់វែងដែលតម្រូវដោយការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក"។ ជួរឈរនៃ "ផលប៉ះពាល់ពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក" ត្រូវបានវិភាគបន្ថែមទៀតលើប្រភេទនៃនិយ័តភាព ។

ការពន្យល់ពីរបៀបនៃការផ្លាស់ប្តូរពីស្តង់ដារពីមុន ទៅ ស.រ.ទ.ហ.អ.ក និងការអនុវត្ត ស.រ.ហ.អ.ក 9 និង ស.រ.ហ.អ.ក 15 បានជះឥទ្ធិពលដល់ស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារ ត្រូវបានកំណត់ដោយការសង្ខេបពីបរិមាណនៃការប៉ះពាល់ និងកំណត់សម្គាល់ដែលភ្ជាប់មកជាមួយ។

ការផ្ទៀងផ្ទាត់មូលធន

ការផ្ទៀងផ្ទាត់ខាងក្រោមនេះ សង្ខេបពីផលប៉ះពាល់នៃការអនុវត្តដំបូង ស.រ.ទ.ហ.អ.ក ទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ។

		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018			
	កំណត់សម្គាល់	ស្តង់ដារពីមុន ដុល្លារអាមេរិក	ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក ការចាត់ថ្នាក់ឡើងវិញ ដុល្លារអាមេរិក	ការវាស់វែងឡើងវិញ ដុល្លារអាមេរិក	ស.រ.ទ.ហ.អ.ក ដុល្លារអាមេរិក
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	ក (i)	4,518,232	(4,518,232)	-	-
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	ក (i)	26,920,658	(26,920,658)	-	-
សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	ក (i)	658,056	(658,056)	-	-
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	ក (i)	-	22,195,702	4,948	22,200,650
ប្រាក់តម្កល់តាមច្បាប់		-	9,901,244	-	9,901,244
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន – សុទ្ធ	ក (i)	35,689,496	58,402	324,659	36,072,557
ការវិនិយោគផ្សេងៗ		22,275,000	78,248	90,006	22,443,254
ទ្រព្យសកម្មអរូបី		119,352	-	-	119,352
ទ្រព្យ និងបរិក្ខារ		612,119	-	-	612,119
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	ខ	-	-	341,686	341,686
ពន្ធពន្យារជាទ្រព្យសកម្ម – សុទ្ធ	គ	-	-	175,160	175,160
ទ្រព្យសកម្មផ្សេងៗ		834,035	(136,650)	-	697,385
ទ្រព្យសកម្មសរុប		91,626,948	-	936,459	92,563,407
ទ្រព្យសកម្មសរុប (ពាន់រៀល - កំណត់សម្គាល់ 5)		**368,157,077**	**-**	**3,762,692**	**371,919,769**

		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018			
			ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក		
	កំណត់សម្គាល់	ស្តង់ដារពីមុន ដុល្លារអាមេរិក	ការចាត់ថ្នាក់ឡើងវិញ ដុល្លារអាមេរិក	ការវាស់វែងឡើងវិញ ដុល្លារអាមេរិក	ស.រ.ទ.ហ.អ.ក ដុល្លារអាមេរិក
បំណុល និងមូលធន					
បំណុល					
ប្រាក់បញ្ញើរបស់អតិថិជន	ក (i)	16,749,064	-	590	16,749,654
ប្រាក់បញ្ញើរបស់ធនាគារនានា	ក (i)	1,224,100	-	-	1,224,100
បំណុលភតិសន្យា	ខ	-	-	348,277	348,277
បំណុលផ្សេងៗ	ក (i)	112,607	-	(590)	112,017
ចំណាយពន្ធអប្បរមា		3,658	-	-	3,658
បំណុលសរុប		18,089,429	-	348,277	18,437,706
មូលធន					
ដើមទុន		75,000,000	-	-	75,000,000
ទុនបម្រុងតាមបទប្បញ្ញត្តិ		-	-	420,139	420,139
ប្រាក់ខាតបង្គរ		(1,462,481)	-	168,043	(1,294,438)
មូលធនសរុប		73,537,519	-	588,182	74,125,701
បំណុល និងមូលធនសរុប (ដុល្លារអាមេរិក)		91,626,948	-	936,459	92,563,407
បំណុល និងមូលធនសរុប ពាន់រៀល - កំណត់សម្គាល់ 5)		**368,157,077**	**-**	**3,762,692**	**371,919,769**

ការផ្សៀងផ្គាត់របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

			ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក		
		ស្តង់ដារពីមុន	ការចាត់ថ្នាក់ឡើងវិញ	ការវាស់វែងឡើងវិញ	ស.រ.ទ.ហ.អ.ក
	កំណត់សម្គាល់	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ចំណូលពីប្រតិបត្តិការ					
ចំណូលពីការប្រាក់	ក(iii)	555,862	-	2,547	558,409
ចំណាយលើការប្រាក់	ខ	(9,326)	-	(15,098)	(24,424)
ចំណូលពីការប្រាក់សុទ្ធ		546,536	-	(12,551)	533,985
ចំណូលកម្រៃ និងជើងសារ - សុទ្ធ	ក(iii)	-	2,782	-	2,782
ចំណូលផ្សេងៗ		3,618	(2,782)	-	836
ចំណេញពីប្រតិបត្តិការសរុប		550,154	-	(12,551)	537,603

		ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក			
		ស្តង់ដារពីមុន	ការចាត់ថ្នាក់ឡើងវិញ	ការវាស់វែងឡើងវិញ	ស.រ.ទ.ហ.អ.ក
	កំណត់សម្គាល់	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ចំណាយលើបុគ្គលិក		-	(282,835)	-	(282,835)
ការរំលស់		-	(78,952)	(58,159)	(137,111)
ចំណាយប្រតិបត្តិការផ្សេងៗ	ខ	(1,414,958)	361,787	64,119	(989,052)
ការខាតបង់លើឱនភាពនៃតម្លៃនៃ ឧបករណ៍ហិរញ្ញវត្ថុ	ក(iii)	-	(592,147)	419,613	(172,534)
ចំណាយពន្ធអប្បបរមា		(5,530)	-	-	(5,530)
ចំណាយលើប្រតិបត្តិការសរុប		(1,420,488)	(592,147)	425,573	(1,587,062)
ចំណេញពីប្រតិបត្តិការមុនឱនភាពនៃតម្លៃ		(870,334)	(592,147)	413,022	(1,049,459)
ការខាតបង់លើឱនភាពនៃតម្លៃនៃ ឧបករណ៍ហិរញ្ញវត្ថុ	ក(iii)	(592,147)	592,147	-	-
ប្រាក់ចំណេញមុនដកពន្ធ		(1,462,481)	-	413,022	(1,049,459)
ចំណាយពន្ធលើប្រាក់ចំណេញ	គ	-		175,160	175,160
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ		(1,462,481)	-	588,182	(874,299)
លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ		**(1,462,481)**	**-**	**588,182**	**(874,299)**

កំណត់សម្គាល់ទៅលើការផ្ទៀងផ្ទាត់

ក. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ស.រ.ហ.អ.ក 9 ឧបករណ៍ហិរញ្ញវត្ថុ បង្ហាញនូវតម្រូវការសម្រាប់ការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងកិច្ចសន្យាមួយចំនួនដើម្បីទិញ ឬលក់ធាតុដែលមិនមែនជាហិរញ្ញវត្ថុ ។ វាក៏ណែនាំផងដែរនូវគំរូថ្មី "ការរំពឹងទុកឥណទានខាតបង់" (ECL) និងគំរូគណនេយ្យការពារហានិភ័យទូទៅថ្មី ។ ធនាគារបានអនុវត្ត ស.រ.ហ.អ.ក 9 ចាប់ពីថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។

ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យដែលបណ្តាលមកពីការអនុវត្ត ស.រ.ហ.អ.ក 9 ត្រូវបានអនុវត្តជាទូទៅដោយធនាគារនាពេលក្រោយលើកលែងតែចំណុចដែលបានពិពណ៌នាខាងក្រោម។

- ការវាយតម្លៃខាងក្រោម ត្រូវបានធ្វើឡើងដោយផ្អែកលើដំណើរហេតុ និងកាល:ទេស:ដែលមានស្រាប់នៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018។
  - ការកំណត់ចំពោះគំរូអាជីវកម្មដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកាន់កាប់
  - ការកំណត់ថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ បង្កើតឲ្យមានលំហូរទឹកប្រាក់ដែលជាការទូទាត់សងប្រាក់ដើម និងការប្រាក់ទៅលើចំនួនទឹកប្រាក់ដែលនៅសល់
  - ការកំណត់នូវការវិនិយោគមូលធន ដែលមិនសម្រាប់យកមកធ្វើការជួញដូរជា FVOCI និង
- ប្រសិនបើការវិនិយោគបំណុលមានហានិភ័យឥណទានទាបនៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ធនាគារបានសន្មតថាហានិភ័យឥណទានលើទ្រព្យសកម្មមិនមានការកើនឡើងជាសារវន្តទេ ចាប់តាំងពីការទទួលស្គាល់ដំបូង ។

ផលប៉ះពាល់ដែលកើតឡើងពីការអនុវត្ត ស.រ.ហ.អ.ក 9 រួមទាំងផលប៉ះពាល់លើពន្ធ ត្រូវបានពិពណ៌នាដូចខាងក្រោម ។

(i). ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងចំណុលហិរញ្ញវត្ថុ

ក្រោម ស.រ.ហ.អ.ក 9 ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមប្រភេទដូចខាងក្រោម: វាស់វែងតាមរំលស់ថ្លៃដើម, FVOCI - ឧបករណ៍បំណុល, FVOCI - ឧបករណ៍មូលធន; ឬ FVTPL ។ ការចាត់ចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុក្រោម ស.រ.ហ.អ.ក 9 ដែលជាទូទៅគឺផ្អែកលើគំរូអាជីវកម្មដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគ្រប់គ្រង និងលក្ខណៈនៃលំហូរទឹកប្រាក់តាមកិច្ចសន្យា ។

សម្រាប់ការពន្យល់អំពីវិធីដែលធនាគារធ្វើការចាត់ថ្នាក់ និងវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ និងចំណេញនិងខាតដែលពាក់ព័ន្ធក្រោម ស.រ.ហ.អ.ក 9។

តារាងខាងក្រោម និងកំណត់សម្គាល់ដែលភ្ជាប់មកជាមួយខាងក្រោមពន្យល់ពីប្រភេទនៃការវាស់វែងដំបូងនៅក្រោមស្តង់ដារពីមុន និងប្រភេទប្រភេទនៃការវាស់វែងថ្មីក្រោម ស.រ.ហ.អ.ក 9 សម្រាប់ថ្នាក់នីមួយៗ នៃទ្រព្យសកម្មហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018។

		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018			
	កំណត់សម្គាល់	ការធ្វើចំណាត់ថ្នាក់ដំបូងក្រោមស្តង់ដារពីមុន	ការធ្វើចំណាត់ថ្នាក់ថ្មីក្រោម ស.រ.ហ.អ.ក 9	តម្លៃយោងដំបូងក្រោមស្តង់ដារពីមុន	តម្លៃយោងថ្មីក្រោម ស.រ.ហ.អ.ក 9
				ដុល្លារអាមេរិក	ដុល្លារអាមេរិក
ទ្រព្យសកម្មហិរញ្ញវត្ថុ					
សាច់ប្រាក់ និងសាច់ប្រាក់សមមូល (ចាត់ថ្នាក់ឡើងវិញ)	(ក)	ថ្លៃដើម	រំលស់ថ្លៃដើម	22,202,346	22,200,650
ការវិនិយោគផ្សេងៗ		ថ្លៃដើម	រំលស់ថ្លៃដើម	22,275,000	22,443,254
តណាទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	(ខ)	តម្លៃយោង	រំលស់ថ្លៃដើម	35,689,496	36,072,557
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប				80,166,842	80,716,461
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប (ពាន់រៀល - កំណត់សម្គាល់ 5)				**322,110,371**	**324,407,213**
បំណុលហិរញ្ញវត្ថុ					
ប្រាក់បញ្ញើរបស់អតិថិជន	(គ)	ថ្លៃដើម	រំលស់ថ្លៃដើម	16,749,064	16,749,654
ប្រាក់បញ្ញើរបស់ធនាគារនានា	(គ)	ថ្លៃដើម	រំលស់ថ្លៃដើម	1,224,100	1,224,100
បំណុលផ្សេងៗ	(គ)	ថ្លៃដើម	រំលស់ថ្លៃដើម	112,607	112,017
បំណុលហិរញ្ញវត្ថុសរុប				18,085,771	18,085,771
បំណុលហិរញ្ញវត្ថុសរុប (ពាន់រៀល - កំណត់សម្គាល់ 5)				**72,668,628**	**72,668,628**

(ក) សាច់ប្រាក់ក្នុងដៃ សមតុល្យនៅធនាគារជាតិនៃកម្ពុជា និងសមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ដែលបានធ្វើចំណាត់ថ្នាក់ឡើងវិញទៅជាសាច់ប្រាក់ និងសាច់ប្រាក់សមមូល និងប្រាក់តម្កល់តាមច្បាប់ ដើម្បីសម្របតាមការបង្ហាញបច្ចុប្បន្នដែលបានវាស់វែងពីមុនតាមថ្លៃដើម ដោយបានផ្លាស់ប្តូរមកវាស់វែងតាមការរំលស់ថ្លៃដើម វិញ ។

(ខ) តណាទាន និងបុរេប្រទានផ្តល់ដល់អតិថិជន ត្រូវបានចាត់ថ្នាក់ជាតណាទាន និងគណនីត្រូវទទួល នៅក្រោមស្តង់ដារពីមុន ហើយត្រូវបានចាត់ថ្នាក់តាមរំលស់ថ្លៃដើម ។ សំដៅទៅលើនិយ័តភាពនៅក្នុងក(ii) និង ក(iii) នៅខាងក្រោម ។

(គ) នៅក្រោមស្តង់ដារពីមុន បំណុលហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់តាមថ្លៃដើម តម្លៃត្រូវបានចាត់ថ្នាក់តាមរំលស់ថ្លៃដើមដំនួសវិញ ។ សំដៅទៅលើនិយ័តភាពនៅក្នុង ក(iii) នៅខាងក្រោម ។

(ii). ឱនភាពនៃតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ស.រ.ហ.អ.ក 9 ជំនួសឲ្យគំរូស្តង់ដារពីមុន "ការខាតបង់ដែលបានកើតឡើង" ជាមួយនឹងគំរូ" ការរំពឹងទុកឥណទានខាតបង់" (ECL) ។ គំរូនៃឱភាពនៃតម្លៃថ្មី អនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ការវិនិយោគបំណុលនៅ FVOCI និងកិច្ចសន្យាធានាលើក្រុមហិរញ្ញវត្ថុ ប៉ុន្តែមិនត្រូវបានសម្រាប់ធ្វើការវិនិយោគមូលធនទេ។

ការអនុវត្តនូវតម្រូវការឱនភាពនៃតម្លៃតាម ស.រ.ហ.អ.ក 9 នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 បង្កើតឲ្យមានសំវិធានធនសម្រាប់ឱនភាពនៃតម្លៃដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018
	ដុល្លារអាមេរិក
សំវិធានធនខាតបង់ ក្រោមស្តង់ដារពីមុន	360,500
តំហយសំវិធានធនបានទទួលស្គាល់នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 លើ:	
ឥណទាន និងបុរេប្រទាន	(324,658)
សំវិធានធនខាតបង់ ក្រោម ស.រ.ទ.ហ.អ.ក	35,842
សំវិធានធនខាតបង់ ក្រោម ស.រ.ទ.ហ.អ.ក(ពាន់រៀល - កំណត់សម្គាល់ 5)	**144,013**

ដើម្បីការអនុវត្តតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ក្រុមហ៊ុនបានផ្ទេរប្រាក់ខាតបង្គរ ទៅជាទុនបម្រុងតាមបទប្បញ្ញត្តិ ចំនួន 420,139 ដុល្លារអាមេរិក នៅថ្ងៃទី31 ខែ ធ្នូ ឆ្នាំ 2018 ។ មើលកំណត់សម្គាល់ 32 (ង) ។

សំវិធានធនខាតបង់លើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានវាស់វែងតាមរំលស់ថ្លៃដើម ត្រូវបានកាត់កងពីតម្លៃយោងដុលនៃទ្រព្យសកម្មនោះ ។

ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រដែលធនាគារប្រើសម្រាប់វាស់វែង ឱនភាពនៃតម្លៃលើសំវិធានធន ត្រូវបានពិពណ៌នានៅក្នុងកំណត់សម្គាល់ 30ខ។

(iii). ការប្រាក់

នៅក្រោមស្តង់ដារពីមុន កម្រៃដែលជាផ្នែកមួយនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ មិនត្រូវបានបញ្ចូលជាអត្រាការប្រាក់ប្រសិទ្ធភាពនោះទេ ហើយត្រូវបានទទួលស្គាល់ថាជា ចំណូលនៅពេលប្រតិបត្តិការកើតឡើង ។ ការទទួលស្គាល់ចំណូលការប្រាក់ ត្រូវបានផ្អាកនៅពេលដែលឥណទានមិនដំណើរការ ។

នៅក្រោម ស.រ.ទ.ហ.អ.ក ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប (សម្រាប់ឧបករណ៍ដែលមិនមែនវាស់វែងតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL") បូកនឹងថ្លៃដើមប្រតិបត្តិការ ដែលកើតមកពីការទិញ ឬលក់ ទ្រព្យ និងបំណុលទាំងនោះ ។ ការទទួលស្គាល់ចំណូលការប្រាក់ មិនត្រូវបានផ្អាកនៅពេលដែលឥណទានមិនដំណើរការនោះទេ ។

ផលប៉ះពាល់ដែលកើតឡើងពីការផ្លាស់ប្តូរត្រូវបានសង្ខេបដូចខាងក្រោម:

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018
	ដុល្លារអាមេរិក
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ	
ការកើនឡើងនៃឥណទាន និងបុរេប្រទាន	58,402
ផលប៉ះពាល់នៃពន្ធដែលពាក់ព័ន្ធ	11,680
និយ័តភាពទៅលើប្រាក់ខាតបង្គរ	70,082
និយ័តភាពទៅលើប្រាក់ខាតបង្គរ (ពាន់រៀល - កំណត់សម្គាល់ 5)	281,589

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018
	ដុល្លារអាមេរិក
របាយការណ៍ចំណេញ ឬខាត និង លទ្ធផលលម្អិតផ្សេងៗ	
ការកើនឡើងនៃចំណូលការប្រាក់	2,547
ការថយចុះនៃចំណូលពីកម្រៃ និងជើងសារ	-
និយ័តភាពទៅលើប្រាក់ខាតមុនដកពន្ធ	2,547
និយ័តភាពទៅលើប្រាក់ខាតមុនដកពន្ធ (ពាន់រៀល - កំណត់សម្គាល់ 5)	**10,234**

(iv). ផលប៉ះពាល់នៃអន្តរកាលលើមូលធន

តារាងខាងក្រោមសង្ខេបអំពីផលប៉ះពាល់ (ដកពន្ធ) នៃការផ្លាស់ប្តូរទៅ ស.រ.ហ.អ.ក 9 ប្រាក់ចំណេញរក្សាទុក ប្រាក់ខាតបង្គរនៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 ។

	ផលប៉ះពាល់នៃការអនុវត្ត ស.រ.ហ.អ.ក 9 ថ្ងៃទី 1 ខែ មករា ឆ្នាំ 2019	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 5)
ប្រាក់ខាតបង្គរ		
សមតុល្យចុងគ្រាក្រោមស្តង់ដារពីមុន (ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018)	(1,462,481)	(5,876,249)
ការវាស់វែងឡើងវិញតាមរំលស់ថ្លៃដើមក្រោម ស.រ.ហ.អ.ក 9	(427,256)	(1,716,715)
ការទទួលស្គាល់តំណាងទានរំពឹងថានឹងបាត់បង់ក្រោមស.រ.ហ.អ.ក 9	420,139	1,688,119
ពន្ធដែលពាក់ព័ន្ធ	175,160	703,793
សមតុល្យដើមគ្រាក្រោម ស.រ.ហ.អ.ក 9 (ថ្ងៃទី 1 ខែ មករា ឆ្នាំ 2019)	**(1,294,438)**	**(5,201,052)**

ខ. ភតិសន្យា

ធនាគារពីមុនបានធ្វើការចាត់ថ្នាក់ភតិសន្យាក្រោម CAS 17 ដោយយោងទៅលើការវាយតម្លៃថាតើភតិសន្យាបានធ្វើការផ្ទេររាល់ហានិភ័យមានលក្ខណៈធំនិង បាក់រង្វាន់ពីកម្មសិទ្ធិនៃទ្រព្យសកម្មក្រុមហ៊ុនទាំងមូលក្រោម ស.រ.ហ.អ.ក 16 ធនាគារទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្មនិងបំណុលភតិសន្យាសម្រាប់ភតិសន្យារបស់និងបរិវេណការិយាល័យ– ឧទាហរណ៍:ភតិសន្យាទាំងអស់គឺនៅតារាងតុល្យការ ។

ផលប៉ះពាល់ដែលបង្កដោយការប្រែប្រួលត្រូវបានសង្ខេបដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018
	ដុល្លារអាមេរិក
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ	
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	341,686
ពន្ធពន្យារជាទ្រព្យសកម្ម	1,318
បំណុលភតិសន្យា	(348,277)
និយ័តភាពទៅលើប្រាក់ខាតបង្គរ	(5,273)
និយ័តភាពទៅលើប្រាក់ខាតបង្គរ (ពាន់រៀល - កំណត់សម្គាល់ 5)	**(21,187)**

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018
	ដុល្លារអាមេរិក
រចាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ	
ការរំលស់លើសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	58,159
ចំណាយការប្រាក់នៃបំណុលភតិសន្យា	15,098
ចំណាយលើការជួល	(66,666)
និយ័តភាពទៅលើប្រាក់ខាតមុនដកពន្ធ	6,591
និយ័តភាពទៅលើប្រាក់ខាតមុនដកពន្ធ (ពាន់រៀល - កំណត់សម្គាល់ 5)	**26,483**

គ. ពន្ធលើប្រាក់ចំណេញ

ការផ្លាស់ប្តូរខាងលើដែលបាន(ចយចុះ)/កើនឡើង លើពន្ធពន្យារជាទ្រព្យសកម្ម / បំណុលមានដូចខាងក្រោម:

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018
	ដុល្លារអាមេរិក
ឱនភាពនៃតម្លៃលើឥណទាន	34,507
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	(68,337)
បំណុលភតិសន្យា	69,655
ផ្សេងៗ	139,335
ការកើនឡើងនៃពន្ធពន្យាជាទ្រព្យសកម្ម	175,160
ការកើនឡើងនៃពន្ធពន្យាជាទ្រព្យសកម្ម (ពាន់រៀល - កំណត់សម្គាល់ 5)	**703,793**

34. ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍

ការរំពឹងលើការបាត់បង់ឥណទាននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2019 ត្រូវបានប៉ាន់ស្មានដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ចដែលបានព្យាករណ៍នាកាលបរិច្ឆេទនោះ ។ នាកាលបរិច្ឆេទបន្ទាប់ មានការផ្ទុះឡើងនៃវីរុសកូរ៉ូណា បានរីករាលដាលនៅប្រទេសចិនដីគោកកម្ពុជា និងបណ្តាប្រទេសដ៏ទៃទៀត ដែលបង្កឱ្យមានការរំខានដល់សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច ។ ផលប៉ះពាល់លើកំណើនផលិតផលក្នុងស្រុកដុល (GDP) និងសូចនាករសំខាន់ផ្សេងៗ នឹងត្រូវបានពិចារណា ក្នុងការកំណត់ភាពធ្ងន់ធ្ងរ និងភាពដែលអាចទៅរួចនៃការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ចដែលនឹងត្រូវបានប្រើប្រាស់ក្នុងការប៉ាន់ប្រមាណការរំពឹងទុកលើការខាតបង់ឥណទានក្រោម ស.រ.ហ.អ.ក 9 ក្នុងឆ្នាំ 2020។

អគារលេខ ៤៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក
www.bicbank.com.kh


BIC Bank